ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Jun-2017, 11:13
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពិរ
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៣០៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក រ៉ូស្សែល ហប់គីនស៍
*(Mr. Russell HOPKINS)*
លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជៀន
*(Mr. Nicolas KOUMJIAN)*
លោក សេង លាង
លោក ត្រាវីស ហ្វារ (Mr. Travis FARR)
លោក ឌេល លីសាក់ (Mr. Dale Lysak)
លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរលក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ពេជ អង្គ

លោក ហុង គឹមសួន

លោក វ៉ែន ពៅ

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ទី ស្រ៊ីនណា

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក សេង លាង | ខ្មែរ |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ហុង គីមសួន | ខ្មែរ |
| លោក សែន សុផុន (2-CCP-220) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី÷ លោក សែន សុផុន** (2-CCP-220)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ..........ទំព័រ ២៧
សួរដោយលោក ហុង គីមសួន ផ្តើមពី ..........ទំព័រ ២៩
សួរដោយលោក សេង លាង ផ្តើមពី ..........ទំព័រ ៤៤
សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី ផ្តើមពី ..........ទំព័រ ៥៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីពិនិត្យភស្តុតាងលើសំណុំរឿង០០២/០២។ តាមកាលវិភាគសវនាការដែលបានកំណត់ និងជម្រាបជូនភាគី និងសាធារណជនកន្លងមកហើយ នៅថ្ងៃនេះអង្គជំនុំជម្រះចាប់ផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីសាក្សី ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ការដ្ឋានទំនប់ត្រពាំងថ្ម ដែលនៅថ្ងៃនេះអង្គជំនុំជម្រះនឹងធ្វើ សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-220 ក៏ប៉ុន្តែដោយមានសំណើថ្មីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលបាន អង្គជំនុំជម្រះបានទទួលកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ដែលបានដាក់សុំបង្ហាញកំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពីសំណុំរឿង០០៤ ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្មមកដាក់នៅក្នុងសំណុំរឿង ០០២/០២។ ដូចនេះ អង្គជំនុំជម្រះត្រូវស្តាប់សារណាផ្ទាល់មាត់របស់ភាគីម្ចាស់សំណើសហព្រះ រាជអាជ្ញា និងសារណាផ្តល់មាត់ពីភាគីពាក់ព័ន្ធដទៃទៀតជាមុនសិន មុននឹងសម្រេចស្តាប់ ឬមិនស្តាប់ សក្ខីកម្មដើម្បីបណ្តឹងរដ្ឋប្បវេណី 2-TCCP-220 នៅថ្ងៃនេះ។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបផងដែរថា នៅក្នុងកិច្ចពិភាក្សាស្តាប់សក្ខីកម្មនៅសវនាការនៅថ្ងៃនេះ និងថ្ងៃបន្តបន្ទាប់ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីនៃរឿងក្តីនេះថា នៅក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ និងអាចថ្ងៃបន្តបន្ទាប់ដែលទំនងរហូតដល់ពីសប្តាហ៍ លោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដែលជាចៅក្រមអន្តរជាតិអវត្តមានដោយមូលហេតុគាត់មានធុរៈចាំបាច់ផ្ទាល់ខ្លួន គាត់មិនអាចចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះបាន។ បន្ទាប់ពីយើងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹង បណ្តាចៅក្រមពេញសិទ្ធិនៃអង្គជំនុំជម្រះសាលាដំបូង យើងសម្រេចតែងតាំងលោកចៅក្រម ម៉ាទីន ខារ៉ុបគីន ដែលជាចៅក្រមបម្រុងភាគីអន្តរជាតិ ជំនួសកន្លែងលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដែលអវត្តមានរហូតដល់ពេលណាលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ មានវត្តមាន និងអាចមានលទ្ធភាព បំពេញការងារក្នុងការចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនៅអង្គជំនុំជម្រះសាលាដំបូងវិញបាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការសម្រេចនេះ ដោយផ្អែកលើតាមបទបញ្ញត្តិនៃវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

[០៩:០៥:៥៨]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែក លោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCCP-220 ។ ដើមបណ្តឹងរូបនេះ មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកស្រី សែ កុលវុឌ្ឍី។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើរសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះ បានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាច ផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខ ឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួន បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬសិទ្ធិក្នុងការ ជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ

ការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា មានអាការឈឺចង្កេះជាប្រចាំ មិនអាចអង្គុយ និងផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ ដោយផ្អែកលើមូលដ្ឋាននេះ និងតាមបទប្បញ្ញត្តិនៃវិធាន៨១ (៥) នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។ ហើយមុននឹងដំណើរការនីតិវិធីសវនាការពិនិត្យភស្តុតាង អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញ ជម្រាបជូនដល់ភាគី និងសាធារណជនថា កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានទទួលសំណើសុំពីការិយាល័យសហព្រះរាជអាជ្ញា ក្នុងការដាក់បង្ហាញកំណត់ហេតុស្តាប់ចម្លើយ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារពាក់ព័ន្ធមួយចំនួនទៀត សរុបចំនួន៥៤ ពីសំណុំរឿង០០៤ ពាក់ព័ន្ធនឹងអង្គហេតុទំនប់ត្រពាំងថ្ម មកក្នុងសំណុំរឿងបច្ចុប្បន្ន ០០២/០២ គឺឯកសារ E319/25.2 ដោយសារតែឯកសារទាំងនេះ ពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះគ្រោងនឹងធ្វើសវនាការនៅថ្ងៃនេះ ហើយនិងអាច នឹងប៉ះពាល់ដល់កាលវិភាគសវនាការដែលអង្គជំនុំជម្រះបានកំណត់រួចហើយនោះ ហេតុដូច្នេះ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីកាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ នេះថា អង្គជំនុំជម្រះ នឹងស្តាប់សេចក្តីសន្និដ្ឋាន របស់ភាគីថា តើឯកសារទាំងនេះនឹងនាំឲ្យប៉ះពាល់ដល់លទ្ធភាពនៃ -- របស់អង្គជំនុំជម្រះត្រូវធ្វើសវនាការលើអង្គហេតុពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្មនោះដែរឬយ៉ាងណា។

[០៩:០៩:៤៩]

នៅថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ ទី២៩ និងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ នៅក្នុងសប្តាហ៍នេះ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទរួចហើយ ក្នុងការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូបដែលមិនទាន់ -- មិនពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម ហើយដែលការស្តាប់សក្ខីកម្មសាក្សីទាំងនេះ មានផល ប៉ះពាល់តិចតួចចំពោះការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា។ នៅថ្ងៃពុធ ទី២៩ កក្កដា ឆ្នាំ

២០១៥ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-866 ពាក់ព័ន្ធនឹង អង្គហេតុការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយបន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្ម 2-TCW-866 អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-926 ពាក់ព័ន្ធនឹងអង្គហេតុ ការដ្ឋានទំនប់ ១មករា។

ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ -- ជម្រាបសួរទៅតំណាងសហព្រះរាជអាជ្ញាថាតើឯកសារណា -- ថាតើពេលណាឯកសារទាំងនោះនឹងត្រូវដាក់បង្ហាញ ហើយថាតើការដាក់ឯកសារនេះនឹងនាំឲ្យប៉ះពាល់ដល់ការផ្តើមសវនាការរបស់អង្គជំនុំជម្រះនៅថ្ងៃនេះដែរឬយ៉ាងណា? ហើយនៅក្នុងបញ្ហាអង្គជំនុំជម្រះជម្រាបថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តីទាំងពីរក្រុម អង្គជំនុំជម្រះនឹងផ្តល់ឱកាសឲ្យធ្វើសារណារផ្ទាល់មាត់តបនឹងការលើកឡើងរបស់សហព្រះរាជអាជ្ញា ហើយភាគីនីមួយៗមានរយៈពេល១០នាទី ដើម្បីលើកឡើង និងឆ្លើយតបអំពីការដាក់បង្ហាញឯកសារថ្មីនេះរបស់សហព្រះរាជអាជ្ញា។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីអាចធ្វើការបញ្ជាក់បង្ហាញដោយផ្ទាល់មាត់នូវបញ្ហាសំណើសុំរបស់ខ្លួន ហើយនិងផលប៉ះពាល់ផ្សេងៗទៀតដែលពាក់ព័ន្ធជាមួយនឹងបញ្ហាការដាក់ឯកសារនេះធៀបជាមួយនឹងការដំណើរការការកំណត់កាលបរិច្ឆេទការរៀបចំសវនាការរបស់តុលាការថ្ងៃនេះ ហើយនិងថ្ងៃបន្តបន្ទាប់សម្រាប់អង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម។

បាទសូមអញ្ជើញសហព្រះរាជអាជ្ញា!

[០៩:១២:១២]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម <និងភាគីទាំងអស់>។ ជាដំបូងខ្ញុំសូមឆ្លើយតបទៅនឹងបញ្ហាទី១ ដែលលើកឡើងនៅក្នុងសារអេឡិចត្រូនិកដែលបានផ្សព្វផ្សាយកាលពីថ្ងៃសុក្រ <ស្តីអំពីខ្លឹមសារ និង>ពេលវេលានៃការដាក់បង្ហាញឯកសារ។<>យើងមានឯកសារពីរប្រភេទដែលយើងដាក់បង្ហាញនៅក្នុងសំណុំរឿង។ ឯកសារទី១ គឺកិច្ចសម្ភាសន៍ប្រាំរបស់ ក.ស.ច.ស <ពីសំណុំរឿង០០៤ >ដែល<ពាក់ព័ន្ធនឹង>មានព័ត៌មានទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម។ ដូចដែលតុលាការបានជ្រាបរួចទៅហើយ មានសាក្សីជាច្រើនត្រូវបានគេស្តាប់នៅក្នុងសំណុំរឿង០០៤ ពាក់ព័ន្ធទៅនឹងស្រុកព្រះនេត្រព្រះ និងទំនប់ត្រពាំងថ្ម។ ហើយមានឯកសារស្តាប់ជាងហុកសិប ត្រូវបានគេដាក់បង្ហាញនៅ

<ដើមឆ្នាំនេះ>ក្នុងខែមីនា និងខែមេសា។ ចាប់តាំងពេលនោះមក គឺមានកិច្ចសម្ភាសន៍ ក.ស.ច.ស ប្រាំទៀតពាក់ព័ន្ធទៅនឹងប្រធានបទនេះត្រូវបានជូនដំណឹងមកយើង ហើយយើងទទួលបានការប្រែរួចទៅហើយ នៅក្នុងចន្លោះខែមិថុនា -- ចន្លោះខែឧសភា ដល់ខែកក្កដា។ <ដូច្នេះ>នោះគឺជាកិច្ចសម្ភាសន៍ថ្មីប្រាំរបស់ ក.ស.ច.ស។ ការដាក់បង្ហាញភាគច្រើនគឺទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន<សរុប៤៧>មកពីសំណុំរឿង០០៤<ដោយ>ពាក្យសុំតាំងខ្លួងទាំងអស់នោះមានព័ត៌មួយចំនួនទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម ហើយខ្ញុំសូមលើកយក<ពីរ>ចំណុច<>ទាក់ទងនឹងពាក្យសុំតាំងខ្លួននោះ។ ទី១ គឺពាក់ព័ន្ធទៅនឹងទំព័រនៃការដាក់បង្ហាញឯកសារនោះ។ ប្រសិនបើយើងសរុបទាំងគ្នាទៅលើទំព័រនៃពាក្យសុំតាំងខ្លួន គឺយើងមើលទៅឃើញថាវាច្រើន។ គឺមានប្រហែលជាង៥០០<>ទំព័រ ប៉ុន្តែដូចដែលតុលាការបានជ្រាបរួចទៅហើយ ទំព័រភាគច្រើននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេ-ណីនោះ<>គឺជា<បញ្ហា>ទម្រង់ <ដោយ>ខ្លឹមសារនៃនីតិវិធី<ដែលដើមបណ្តឹងរដ្ឋប្បវេណីបាន> គូស<ក្នុងប្រអប់ ដូចជាព័ត៌មានប្រវត្តិរូប អាសយដ្ឋាន លិខិតថត>ចម្លងអត្តសញ្ញាណប័ណ្ណ<អី>ជាដើម។ ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ <ជាទូទៅ> នៅចុង<ទម្រង់នោះ មានចន្លោះឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចពិពណ៌នាអំពី>ព័ត៌មាន<បទពិសោធន៍របស់ខ្លួនដែលឆ្លងកាត់របបនោះ>។ ដូច្នេះហើយគឺថាយើងបានពិនិត្យមើលទៅលើចំនួនទំព័រជាក់ស្តែងនៅក្នុងពាក្យសុំតាំងខ្លួនទាំង៤៧ ទាំងអស់នោះគឺមានតែ៩៤ទំព័រប៉ុណ្ណោះដែលពាក់ព័ន្ធ។ ចំពោះកិច្ចសម្ភាសន៍របស់ ក.ស.ច.ស ទាំងប្រាំថ្មីៗនោះគឺជាកិច្ចសម្ភាសន៍ខ្លីៗទេ។ ដូច្នេះ ជាសរុបទៅ គឺមានប្រហែលជា៩៤ទំព័រប៉ុណ្ណោះ។

[០៩:១៥:៣៤]

ខ្ញុំក៏សូមកត់សម្គាល់ផងដែរថា មានតែមួយផ្នែកនៃការដាក់ចូលទៅក្នុងសំណុំរឿងប៉ុណ្ណោះ ដែលពាក់ព័ន្ធទៅនឹងត្រពាំងថ្ម ហើយ<បើយើងពិនិត្យមើលក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ យើង>ប្រហែលជា<ឃើញមាន>មួយកថាខណ្ឌនៅក្នុងមួយ ឬក៏ពីរទំព័រប៉ុណ្ណោះ ដែលពាក់ព័ន្ធទៅនឹងត្រពាំងថ្ម។ ដូច្នេះ អ្វីដែលខ្ញុំចង់បញ្ជាក់ គឺថាយើងមិនមានឯកសារច្រើន ដើម្បីពិនិត្យមើលនោះឡើយ គឺមានតែប៉ុន្មានទំព័រប៉ុណ្ណោះ។ ខ្ញុំខ្លួនឯងក្នុងពេលបីសប្តាហ៍កន្លងមក ក៏ខ្ញុំអត់នៅភ្នំពេញដែរ ខ្ញុំនៅប្រទេសកាណាដា ហើយខ្ញុំបានទទួលឯកសារនេះកាលពីថ្ងៃសុក្រ ទោះបីថាខ្ញុំមានបញ្ហាខុសពេលវេលាខុសម៉ោងពេលសម្រាកក៏ដោយ ក៏ខ្ញុំនៅតែអាចពិនិត្យបានឯកសារ<ទាំងនេះអស់>ដែរ<ក្នុងពេលរសៀលហ្នឹង>។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ចំណុចមួយទៀត ដែលខ្ញុំចង់បញ្ជាក់ ហើយចង់ឲ្យអ្នកទាំងអស់គ្នាយល់អំពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺថាកាលបរិច្ឆេទដែលយើងបង្ហាញនៅក្នុងឧបសម្ព័ន្ធដែលយើងបានដាក់ គឺជាកាលបរិច្ឆេទដែល<រៀបចំ និងចុះហត្ថលេខាដោយ>ដើមបណ្ដឹងរដ្ឋប្បវេណី<។ វា>មិនមែនជាកាលបរិច្ឆេទនៃការជូនដំណឹងមកការិយាល័យ ក.ស.ព <ឬដាក់ចូលទៅក្នុងសំណុំរឿងនោះទេ>។ ដូច្នេះហើយយើងយល់ គួរតែដឹងថា ដំណើរការទាំងអស់នេះ គឺឯកសារទាំងអស់នេះចូលទៅក្នុងអង្គភាពគាំពារជនរងគ្រោះ <ជាអ្នកដាក់ព័ត៌មាន>បញ្ចូលទៅក្នុងទិន្នន័យ ហើយ<ធ្វើការងារផ្សេងៗទៀត ដែលខ្ញុំមិនបានដឹងច្បាស់ មុនពេលគេបញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះទៅក្នុង>សំណុំរឿង។<ខ្ញុំសូមលើកឧទាហរណ៍មួយ>អំពីពេលវេលានៃ<ពាក្យ>សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើយើងមើលទៅក្នុងពាក្យសុំតាំងខ្លួន<ដំបូង>នៅក្នុងឧសម្ព័ន្ធ គឺលេខ២ នៅក្នុងតារាងគឺឯកសារ<នេះត្រូវដាក់លេខ> E319/25.3.2 ប្រសិនបើយើងមើល<ក្នុងឧបសម្ព័ន្ធវិញ> គឺថ្ងៃទី០១ មិថុនា ២០១៣ ប៉ុន្តែនេះគឺជាកាលបរិច្ឆេទដែលដើមបណ្ដឹងគាត់ចុះហត្ថលេខាតែប៉ុណ្ណោះ។ <>អង្គភាពគាំពារជនរងគ្រោះ<បានរៀបចំឯកសារទាំងនេះរហូតដល់>ថ្ងៃ២៧ មិថុនា ២០១៤ គឺមួយឆ្នាំក្រោយនោះ។<>ប្រសិនបើយើងមើលទៅ<ក្នុងពាក្យសុំតាំងខ្លួនទាំងនោះ យើងនឹងឃើញមាន>ត្រា<>បោះនៅលើ<គម្រប>ទំព័រដំបូង គឺមិនមែនជាថ្ងៃដែលគេដាក់ចូលក្នុងសំណុំរឿងទេ ប៉ុន្តែគឺជាថ្ងៃខែដែលអង្គភាពគាំពារសាក្សីបានទទួល។ ដូច្នេះ <ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ត្រូវបានចុះហត្ថលេខានៅក្នុងខែមិថុនា ឆ្នាំ២០១៣> បន្ទាប់មកខាងអង្គភាពគាំពារជនរងគ្រោះ<បានរៀបចំឯកសារនៅខែ>មិថុនា ឆ្នាំ២០១៤ <ហើយគេជូនដំណឹងឯកសារដើមជាភាសាខ្មែរ និងដាក់បញ្ចូលទៅក្នុងសំណុំរឿង>នៅក្នុងថ្ងៃ១១ មីនា ២០១៥។

[០៩:១៨:៤៩]

ចំណុចមួយទៀត ដែលខ្ញុំចង់ឲ្យតុលាការចាប់អារម្មណ៍ផងដែរ គឺថាការបរិច្ឆេទមួយចំនួនដែលដាក់នៅក្នុងឧសម្ព័ន្ធនោះ គឺថាតាមរយៈទិន្នន័យរបស់ *ខេស-ម៉េប* គឺបង្ហាញថាវាមិនត្រឹមត្រូវនោះឡើយ។ ខ្ញុំពិនិត្យមើលទៅលើឯកសារនេះ ព្រោះថានៅពេលដែលខ្ញុំមើលឯកសារកាលពីថ្ងៃសុក្រហ្នឹង ខ្ញុំឃើញឯកសារខ្លះតាំង២០០៩, ២០១១ គឺវាហាក់ដូចជាឆាប់រហ័សពេក។ ប៉ុន្តែនៅពេលដែលខ្ញុំពិនិត្យមើលទៅលើការបរិច្ឆេទជាក់ស្ដែង គឺមានឯកសារចំនួន១៧ ដែល<មានក្នុងបញ្ជី ព្រីនចេញពី>*ខេស-ម៉េប* <នៅឆ្នាំ>ឆ្នាំ២០០៩, ២០១១នោះ ការពិតទៅគឺជាកាលបរិច្ឆេទដែលអ្នកតាំងខ្លួនបានចុះហត្ថលេខា<ក្នុងឆ្នាំ

២០១៣។ មានតែពាក្យសុំតាំងខ្លួនពីរប៉ុណ្ណោះ ដែលមានកាលបរិច្ឆេទមុនហ្នឹង។ ជាថ្មីម្តងទៀត ដើម្បីឲ្យភាគីយល់ពីពេលវេលាឯកសារហ្នឹងច្បាស់ ខ្ញុំសូមព្រីនមួយច្បាប់មកពិនិត្យមើល។>

<នៅ>លេខ៣៣ នៅក្នុងឧបសម្ព័ន្ធ គឺជាពាក្យសុំតាំងខ្លួនមួយក្នុងចំណោមពាក្យសុំពីរ ដែលដាក់តាំងពី២០១១ ហើយ<បានចុះហត្ថលេខាដោយអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី>ចុះហត្ថ-លេខាថ្ងៃ១៤ មិថុនា ២០១១ ហើយ<មេធាវីរបស់គាត់បានបញ្ជូននៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១។ បន្ទាប់មក>អង្គភាព<>គាំពារជនរងគ្រោះគឺធ្វើឯកសារនៅថ្ងៃ១៣ វិច្ឆិកា ២០១២ <ប៉ុន្តែ>អង្គភាពជនរងគ្រោះ<មិនទាន់បានដាក់ចូលទៅក្នុងសំណុំរឿងនៅឡើយទេ ហើយក៏មិនទាន់បាន>ជូនដំណឹងមក<ភាគីនោះដែរ រួមទាំងយើងខ្ញុំផងដែរ ទាល់តែរហូតដល់ថ្ងៃទី០៨ ខែឧសភា ២០១៣ ទើបគាត់ជូនដំណឹង>។ <ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានដាក់បកប្រែនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ ឯណោះ។> ហើយដូច្នេះពាក់ព័ន្ធទៅនឹង<សំណួរអំពី>ពេលវេលា ខ្ញុំគិតថាការបរិច្ឆេទនៅក្នុងឧបសម្ព័ន្ធគឺថា មានការបរិច្ឆេទមួយចំនួនមិនត្រឹមត្រូវ ហើយវាមិនមែនជាការបញ្ជាក់អំពីកាលបរិច្ឆេទដែល<ការិយាល័យ>ក.ស.ព បានទទួលនោះឡើយ។ យើងយល់ទាំងអស់គ្នាថា វាជាការមិនល្អនោះឡើយដែលយើងដាក់ឯកសារនេះនៅមួយសប្តាហ៍មុនសវនាការ<ចាប់ផ្តើម>នោះ ហើយយើងក៏មិនចង់ធ្វើដូច្នេះដែរ។ យើងព្យាយាមជៀសវាងអំពីបញ្ហាទាំងអស់នេះ។ យើងដឹងថា គ្រប់ភាគីទាំងអស់<ដែលធ្វើការនៅក្នុងតុលាការនេះ>មានធនធានមានកម្រិត<នៅឡើយ>រួមបញ្ចូលទាំងអ្នកដែលដំណើរការឯកសារពាក្យសុំតាំងខ្លួន និងដាក់បញ្ចូលឯកសារពាក្យសុំតាំងខ្លួនទៅក្នុងសំណុំរឿងទាំងអស់ <ខ្ញុំគិតថា ដោយសារមានកម្រិតបែបនេះហើយ ទើបវាត្រូវស៊ីពេលខ្លះសម្រាប់រៀបចំដាក់ឯកសារទាំងនោះពីទម្រង់សុំតាំងខ្លួនជាដើមបណ្តឹងទៅជាឯកសារបញ្ចូលក្នុងសំណុំរឿង។>

[០៩:២១:៤៥]

ដូច្នេះហើយប្រសិនបើពិនិត្យមើលទៅលើការបរិច្ឆេទជាក់ស្តែង ក៏ដូចជាការបកប្រែជាភាសាអង់គ្លេសរបស់ឯកសារទាំងអស់នេះ គឺយើងទទួលបាននៅក្នុងចន្លោះឆ្នាំ២០១៤ ទៅ ២០១៥។ ទោះជាយ៉ាងនេះក្តី <ការិយាល័យរបស់យើង គឺ>ក.ស.ព បានកំណត់អត្ថិភាពសម្រាប់ឯកសារទាំងអស់នេះ ហើយអត្ថិភាពទី១របស់យើងគឺផ្តោតទៅលើសំណុំរឿង០០៣ សំណុំរឿង០០៤ ដែលផ្តោតជាសំខាន់ទៅលើ<បញ្ហាបើកសំណុំរឿង ជា>ការស្តាប់ចម្លើយសាក្សីដោយ ក.ស.ច.ស។ រឿងនេះ<បានទាញចំណាប់អារម្មណ៍របស់យើងតាំងពីដើមទីមកម្ល៉េះ ថាវា>ជាប្រភព<ភស្តុតាង>ដ៏សំខាន់ ហើយយើង

ព្យាយាមឲ្យអស់ពីលទ្ធភាពដើម្បីធានាថា កិច្ចសម្ភាសន៍ស្តាប់ចម្លើយសាក្សីត្រូវបានដាក់បង្ហាញ<ត្រង់កន្លែងណា/ផ្នែកណា>ដែលពាក់ព័ន្ធ។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺជាអត្ថិភាពទី២របស់យើង ហើយនេះគឺជាហេតុផលមួយផងដែរ ដែលថាយើងដាក់នៅពេលនេះជាជាង -- ដែលមិនអាចដាក់ពីដើមឆ្នាំកន្លងមក។ យើង<សង្ឃឹម>ថា យើងមានធនធាន ក៏ដូចជា<លទ្ធភាពពិនិត្យឯកសារទាំងនេះឲ្យអស់ភ្លាមៗនៅពេលឯកសារទាំងនោះមកដល់។ ប៉ុន្តែនេះ នេះមិនមែនជារឿងស្រួលធ្វើនោះទេ។ បើសិនណា យើង>បែកចែកធនធាន<>ទៅ<ពិនិត្យមើល>ពាក្យសុំតាំងខ្លួន<ជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន>១០០០<ច្បាប់>នៅក្នុងសំណុំរឿង០០៤ <អ៊ីចឹង យើងក៏ត្រូវដកធនធានចេញពីការងារមួយចំនួនផងដែរ>។ ដូច្នេះ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងអាចឆ្លើយទៅនឹងសំណួររបស់លោកប្រធានទាក់ទងទៅនឹង<ខ្លឹមសារ និងពេលវេលានៃ>ឯកសារដែលយើងបាន<ដាក់>បង្ហាញ។

[០៩:២៣:២២]

ឥឡូវនេះ ខ្ញុំសូមឆ្លើយទៅនឹងសំណួរ<មួយទៀត> ថាតើវាប៉ះពាល់ទៅនឹងលទ្ធភាពក្នុងការបន្តដំណើរការទៅមុខទៀតឬអត់? ខ្ញុំសូមឆ្លើយថាមិនប៉ះពាល់ទេ។ ហេតុផលគឺថា មាន -- ព្រោះថាយើងមានកំណត់ហេតុស្តាប់ចម្លើយសាក្សីប្រហែលជិត១០០ ដោយ ក.ស.ច.ស ពាក់ព័ន្ធទៅនឹងទំនប់ត្រពាំងថ្ម។ ទាំងអស់នោះគឺភាគច្រើននៅក្នុងសំណុំរឿង០០២ ហើយសំណុំរឿង០០២ នេះគឺមានតាំងពីយូរណាស់មកហើយ<ចាប់តាំងពីដំណាក់កាលចុះស៊ើបអង្កេតឯណោះ។> ចំណែក<ចម្លើយ>ទាក់ទងទៅនឹងសំណុំរឿង០០៤ គឺមានតាំងពីខែមីនា មេសា មកម្ល៉េះ។ <មានចម្លើយសាក្សី៨៤នាក់>ហើយភាគច្រើននៃ<ចម្លើយទាំង>ហ្នឹងគឺជាកំណត់<ហេតុ>ស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ<មានខ្លះចេះញពីសំណុំរឿង០០២ ហើយខ្លះទៀតជាផ្នែកនៃ>ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាយើងដាក់<បញ្ចូល>នៅក្នុងបញ្ជី<សវនាការនៅ>ខែមិថុនា ឆ្នាំ២០១៤ របស់យើងមកម្ល៉េះ។ មានដើមបណ្តឹងរដ្ឋប្បវេណី<៩៩នាក់>បានដាក់នូវព័ត៌មានបន្ថែម ក៏ដូចជាពាក្យសុំតាំងខ្លួនទាក់ទងទៅនឹងទំនប់ត្រពាំងថ្ម<ក្នុងសំណុំរឿង០០២នេះដែរ>។ ហេតុអ្វីបានជាខ្ញុំជម្រាបអស់លោកទាំងអស់នេះ ព្រោះថាព័ត៌មានទាំងអស់នោះ គឺថាត្រូវបានផ្តល់ដល់ភាគីតាំងពីយូរយារណាស់មកហើយ។ ដូច្នេះ<ដោយហេតុផលនោះ>ហើយគឺថា វាមិនមាន ឬក៏សឹងតែមិនមាននូវព័ត៌មាន<ថ្មីៗ>ដែលយើងទើបតែដឹង<ក្នុង>ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី<ទាំងនេះទេ។>

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ដូច្នេះ ខ្ញុំគិតថា<> ក.ស.ព ក៏ដូចជាភាគីដទៃទៀតអាចមានលទ្ធភាព<ពិនិត្យមើល>ទៅលើឯកសារពាក់ព័ន្ធទៅនឹង<អាង>ត្រពាំងថ្ម។ យើង<ដឹងថា>មាន<ចម្លើយ>សាក្សីប្រហែល ២០០ ហើយនិងដើមបណ្តឹងប្រហែល១០០ ដែលពាក់ព័ន្ធទៅនឹងទំនប់ត្រពាំងថ្មនេះ <ហើយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងក្នុងសំណុំរឿង០០៤ ក៏គ្របដណ្តប់លើ>មូលដ្ឋាន<ថ្មីនេះដែរ>។ <ខ្ញុំបានពិនិត្យឯកសារទាំងនោះដោយខ្លួនខ្ញុំផ្ទាល់ ហើយពិតណាស់ ខ្ញុំអាចពិពណ៌នាដូចអ្វីដែលភាគីបានគិត។ ឯកសារទាំងនោះ វាត្រូវនឹងចម្លើយរបស់ជនរងគ្រោះរាប់រយនាក់ដែលបានផ្តល់នៅក្នុងតុលាការនេះ ដែលបានលើកឡើងអំពីលក្ខខណ្ឌទូទៅនៅឯទំនប់នោះ។> ដូច្នេះ <តើវា>ប៉ះពាល់អ្វីទៅ<នឹង>នីតិវិធី<ដែលយើងខ្ញុំត្រូវបន្តនៅសប្តាហ៍>នេះ<ទេ? អត់ទេ។> ខ្ញុំ<សូម>បញ្ជាក់ថា ឯកសារដែលយើងប្រហែលជាអាចនឹងប្រើប្រាស់នៅក្នុងរយៈពេលពីរបីសប្តាហ៍ទៅមុខទៀតនេះ គឺពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពី 2-TCW-908។<ឯកសារនេះមាន>លេខ៤៨ ក្នុងឧបសម្ព័ន្ធ <ហើយបុគ្គលនៅក្នុងឯកសារហ្នឹង>គ្រោងមកផ្តល់សក្ខីកម្ម<។ គាត់គឺជា>ជាសាក្សីចុងក្រោយបំផុតនៅក្នុង<អង្គហេតុ>អាងទំនប់ត្រពាំងថ្ម។ <តែយ៉ាងណាមិញ គាត់មានលេខរៀង១១នៅក្នុងបញ្ជី។ អ៊ីចឹង> ខ្ញុំគិតថា គាត់ប្រហែលជាមកផ្តល់សក្ខីកម្ម<មិនដល់>បីសប្តាហ៍<ទេ>។ សង្ឃឹមថា ខ្ញុំអាច ខ្ញុំបានឆ្លើយតបទៅនឹងសំណួររបស់លោកប្រធានក៏ដូចជា សំណួររបស់ភាគីនានាដែលចង់ដឹងដែរ។ <ហើយខ្ញុំត្រៀមនឹងឆ្លើយសំណួរផ្សេងៗទៀតផងដែរ។>

[០៩:២៦:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធានដែលផ្តល់វេទិកានេះជូនខ្ញុំ។ សូមអរគុណលោកសហព្រះរាជអាជ្ញាចំពោះការពន្យល់បំភ្លឺនេះ ខ្លួនខ្ញុំផ្ទាល់ខ្ញុំមានសំណួរមួយ ខ្ញុំបានអានឧបសម្ព័ន្ធដែលបានភ្ជាប់ទៅនឹងសំណើរបស់លោករួចហើយ ខ្ញុំកត់សម្គាល់ឃើញថា <ឯកសារ>មួយចំនួននោះ មិនបានបញ្ជាក់លេខ ERN ជាភាសាខ្មែរ ឬក៏ជាភាសាអង់គ្លេស ឬក៏ជាភាសាបារាំងទេ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ពាក់ព័ន្ធទៅនឹងសំណៅផ្សេងៗនៃឯកសារទាំងអស់ហ្នឹង ថាតើមានជាភាសាខ្មែរ បារាំង ឬក៏អង់គ្លេសយ៉ាងម៉េច? ខ្ញុំគិតថាឯកសារទាំងអស់ហ្នឹងប្រហែលជាមានជាភាសាខ្មែរ ក៏ប៉ុន្តែខ្ញុំសួរនេះដើម្បីឲ្យបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ច្បាស់។ តើលោកអាចបញ្ជាក់បានទេថាតើឯកសារប៉ុន្មានដែលមានជាភាសាអង់គ្លេស ហើយនិងជាភាសាបារាំងនោះ ព្រោះថាអម្បាញ់មិញនេះ លោកបានបញ្ជាក់ថាពាក់ព័ន្ធទៅនឹងពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង គឺមានប្រហែល<តិចជាង> ៩៤ទំព័រ ដែលវាពាក់ព័ន្ធ។ ដូច្នេះខ្ញុំគិតថា ៩៤ទំព័រហ្នឹង ប្រហែល<ព័ត៌មានសុទ្ធតែ>ភាសាអង់គ្លេស។ នេះជាសំណួរទី១ របស់ខ្ញុំ។

[០៩:២៨:១៦]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកចៅក្រម ឡាវែន៍។ ខ្ញុំមិនប្រាកដថាលោកចៅក្រមចង់យោងទៅលើឯកសារណាមួយដែលថាខ្វះនូវលេខ ERN នោះឡើយ ប៉ុន្តែ<>នៅក្នុងឧបសម្ព័ន្ធ<ដែលខ្ញុំកំពុងតែមើលនេះ>គឺមានលេខ ERN។ <ប្រហែលជាមានបញ្ហាខ្លះហើយ។> ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា <ប្រហែល>មានតែឯក-សារ<មួយ ឬ>ពីរប៉ុណ្ណោះដែលមានជាភាសាខ្មែរ <ហើយមាន>ឯកសារ<តែមួយប៉ុណ្ណោះដែលអាចរកបាន>ជាភាសាអង់គ្លេស។ <ក៏ប៉ុន្តែចំពោះ>ឯកសារដទៃទៀត គឺមានទាំង<អស់>លេខ ERN ខ្មែរ និង ERN អង់គ្លេស ប៉ុន្តែខ្ញុំ<ចាំបាច់>ត្រូវពិនិត្យឡើងវិញ។ <>ខ្ញុំ<កំពុងតែបើកមើលហើយ ហើយខ្ញុំឃើញ>ថាឯកសារស្ទើរតែទាំងអស់មានលេខ ERN ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ហើយមានឯកសារមួយចំនួនតូច<មានការបកប្រែ>ជាភាសាបារាំងផង។ <នេះជាការកត់សម្គាល់របស់ខ្ញុំគឺថា> ទាំងពាក្យសុំតាំងខ្លួន<ជាដើមបណ្តឹងរដ្ឋប្បវេណី> ទាំងកំណត់ហេតុស្តាប់ចម្លើយ <ក្នុងសំណុំរឿង ០០៤> ជាដំបូងត្រូវបកប្រែទៅជាភាសាអង់គ្លេសជាដំបូងសិន បន្ទាប់មកទៀតទើបបកប្រែទៅជាភាសាបារាំង។ ដូច្នេះ ខ្ញុំមិនដឹងច្បាស់ថាតើឯកសារណាមួយនៅក្នុងឧបសម្ព័ន្ធដែលមានបញ្ហាមុនពេលដាក់ចូលទៅក្នុងសំណុំរឿងទាក់ទងទៅនឹងលេខ ERN នេះឡើយ។ <ប៉ុន្តែឧបសម្ព័ន្ធដែលខ្ញុំមាននេះ គឺប្រាកដមានលេខ ERN ហើយ។>

[០៩:២៨:៤៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ឯកសារដែលខ្ញុំនិយាយអម្បាញ់មិញនេះ គឺឯកសារ E319/25.3 ខ្ញុំកត់សម្គាល់ឃើញថាឯកសារ គឺ ៤, ទី៦, ទី៨, ទី៩ ឯកសារទី១១, ១៤ គឺជាចំនួនឯកសារ សំខាន់ ដូចជា ១៧, ១៨, <១៩,> ២២ ឯកសារលេខរៀងទី ២៨, ២៩, ៣៦ គឺមានឯកសារមួយចំនួនធំ ដែលមិនបានបញ្ជាក់អំពីលេខ ERN ទេ។ អ៊ីចឹងហើយបានជាខ្ញុំសួរលោកនោះ។ ឧទាហរណ៍ <ខ្ញុំរកឃើញ>ដូចជា ឯកសារ លេខ ៤០,

៤២, ៤៣, ៤៥, ៤៦, ៤៩, ៥២ គឺមានចំនួនឯកសារច្រើនដែលមិនមានបញ្ជាក់អំពីលេខ ERN។ អ៊ីចឹងហើយបានជាខ្ញុំចោទសួរលោកពាក់ព័ន្ធទៅនឹង ថាតើឯកសារទាំងអស់ហ្នឹងមានជាភាសាផ្សេងៗទៀតដែរឬក៏អត់?

**លោក ឌេល លីសាក់៖**

លោកចៅក្រម <ឯកសារទាំងនោះប្រាកដជាមានមែន។> ខ្ញុំត្រូវពិនិត្យមើលឡើងវិញ<ថាយ៉ាងម៉េចវាទៅអ៊ីចឹង។ ខ្ញុំសូមធានាថា យើងបានរៀបចំ>ឧបសម្ព័ន្ធនេះ <ហើយខ្ញុំជឿថាវា>ជាឧបសម្ព័ន្ធដើម<ដែលយើងបានដាក់>លេខ ERN <នៅ>គ្រប់<ទំព័រ>ទាំងអស់។ ខ្ញុំមិនដឹងថា ហេតុអ្វីបានជាលោកចៅក្រមមានឧបសម្ព័ន្ធដែលមិនមានលេខ ERN នោះឡើយ<។> ខ្ញុំនឹងពិនិត្យមើលឡើងវិញ។ យើងនឹងពិនិត្យមើល <ហើយបញ្ជាក់ឲ្យច្បាស់ថា សំណៅដែលបានផ្ញើជូន មានដាក់លេខ ERN។ ខ្ញុំមិនដឹងថា យ៉ាងម៉េចទេបានទៅជាអ៊ីចឹងទេ> ព្រោះថា ឯកសារ<ចម្លង>ដែលខ្ញុំកំពុងតែកាន់នៅក្នុងដៃនេះ គឺមានគ្រប់លេខ ERN ទាំងអស់សម្រាប់ឯកសារលេខនីមួយៗ <លើកលែងតែឯកសារចំនួនបីប៉ុណ្ណោះ គឺឯកសារពីរជា>ភាសាខ្មែរ និង<មួយទៀត គឺជា>ភាសាអង់គ្លេស។<ប៉ុន្តែ> ខ្ញុំនឹងពិនិត្យមើលឡើងវិញ ហើយបន្ទាប់មកទៀត <ធានាថាឲ្យមានលេខ ERN ក្នុងឯកសារទាំងនោះ។>

លោកចៅក្រម ខ្ញុំ<អាចធានាអះអាងបានថា ឯកសារដែលនឹងត្រូវ>ដាក់បញ្ចូលទៅក្នុងបណ្ដុំឯកសារអេឡិចត្រូនិកដើម្បីបញ្ជាក់ឲ្យច្បាស់ថា វាមានទាំង<ឯកសារបកប្រែជាភាសាខ្មែរ និងភាសាអង់គ្លេស លើកលែងតែឯកសារចំនួនបីប៉ុណ្ណោះ ដែលមានតែមួយភាសា។>

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកសហព្រះរាជអាជ្ញាដែលបានឆ្លើយបញ្ជាក់។

ខ្ញុំអស់សំណួរហើយលោកប្រធាន។

[០៩:៣២:២២]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការធ្វើសារណាពាក់ព័ន្ធនឹងបញ្ហានេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកប្រធាន តើយើងអាច<មានមតិយោបល់>ក្រោយពី<យើងបានស្ដាប់មតិយោបល់>របស់មេធាវីការពារក្ដីបានទេ ដើម្បីឲ្យយើងអាចឆ្លើយតបទៅនឹងសំណើជាក់លាក់របស់ពួកគាត់ជាមុនសិន លោកប្រធាន ហើយបានខ្ញុំធ្វើតាមក្រោយ។ តើអាចអនុញ្ញាតទេលោកប្រធាន?

ប្រសិនបើមិនអីចឹងទេ ខ្ញុំអាចធ្វើការកត់សម្គាល់ជាទូទៅ<សិនក៏បានដែរ> ហើយនិងបន្ទាប់មកទៀត ខ្ញុំអាចនឹងស្នើសុំនៅពេលក្រោយដើម្បីឆ្លើយតបទៅនឹងមេធាវីការពារក្ដីតាមតែការសម្រេចរបស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះតម្រូវឲ្យលោកស្រីធ្វើនាពេលនេះតែម្ដងដើម្បីបង្កើនល្បឿននីតិវិធីនៃការពិភាក្សារបស់យើង ពីព្រោះមេធាវីការពារក្ដីត្រូវនិយាយចុងក្រោយគេ។

[០៩:៣៣:៥២]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ <បើអីចឹង> យើងខ្ញុំមានការកត់សម្គាល់ខ្លីទេ។ <ជាដំបូង> យើងខ្ញុំសូមរំឭកថា ខ្ញុំនិង ពេជ អង្គ គឺស្ថិតក្នុងស្ថានភាពតែមួយជាមួយនឹងមេធាវីការពារក្ដី។ យើងមិនអាចចូលមើលសំណុំរឿង ០៣, ០៤ បានទេ ហើយយើងបានឃើញឯកសារហ្នឹងកាលពីថ្ងៃសុក្រដូចជាភាគីផ្សេងទៀតដែរ នៅក្នុងបាច់ឯកសារដែលគេបានប្រគល់ឲ្យយើង។ យើងឃើញថា មានឯកសារ៥៤ ជាភាសាខ្មែរ, ៥៤ ជាភាសាអង់គ្លេស។ យើងគិតថាឯកសារទាំងអស់ ប្រហែលបកប្រែទៅជាអង់គ្លេស ហើយមានតែ<ឯកសារ>២០ តែប៉ុណ្ណោះដែលបកប្រែជាភាសាបារាំង។ យើងបានដឹងអំពីឯកសារទាំងអស់នេះ កាលពីរសៀលថ្ងៃសុក្រ។ យើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះថាតើ អាចមានការ<ពន្យារពេល>ការស្ដាប់ចម្លើយ សាក្សីពាក់ព័ន្ធនឹងត្រពាំងថ្ម ឬក៏យ៉ាងម៉េច? យើងខ្ញុំធ្វើការថ្លឹងថ្លែង<សង្កេត>ពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារទាំងអស់នេះ។ យើងដឹង<យ៉ាងពេញលេញ>អំពីការជំទាស់នឹងសំណើររបស់មេធាវីការពារក្ដី ពីព្រោះថាភាគីនីមួយៗ អាចមានលទ្ធភាពសម្រេចដោយខ្លួនឯងផ្ទាល់<ថា>ឯកសារ<ណាខ្លះ> ហើយនិងព័ត៌មាន<អ្វីខ្លះដែលចាំបាច់ សម្រាប់>សវនាការវគ្គថ្មី<នេះ>។ ដូច្នេះ យើងគិតថាធ្វើយ៉ាងម៉េចឲ្យសវនាការឈានទៅមុខបានលឿនបំផុតតាមដែលអាចធ្វើទៅបាន។ ដូច្នេះ យើងទុកចិត្តទៅលើអង្គជំនុំជម្រះដើម្បីអាចធ្វើការថ្លឹងថ្លែងទៅលើសិទ្ធិផ្សេងៗរបស់ភាគីនៅក្នុងសំណុំរឿង។ <យើងជឿថា នៅក្នុង>សប្ដាហ៍នេះត្រូវតែដំណើរការទៅមុខ ពីព្រោះថាយើង

មានសាក្សីមួយពាក់ព័ន្ធទៅនឹងព្រលានយន្តហោះកំពង់ឆ្នាំង ហើយនិងមានសាក្សីមួយទៀតពាក់ព័ន្ធទៅនឹងទំនប់១មករា ក៏ប៉ុន្តែទោះជាយ៉ាងណាក្តីគឺអង្គជំនុំជម្រះជាអ្នកសម្រេច ហើយយើងនឹងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ<ចំពោះចំណុចនេះ។ យើងក៏ដឹងដែរថា អាចនឹងមាន>ការជំទាស់<លើកឡើងដោយ>ភាគីផ្សេងៗទៀតផងដែរ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ជាដំបូងគឺក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសធ្វើសារណាតបទៅនឹងការលើកឡើងដាក់បង្ហាញឯកសារថ្មីរបស់សហព្រះរាជអាជ្ញា។

សូមអញ្ជើញលោកមេធាវី!

[០៩:៣៦:៣៥]

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរភាគីទាំងអស់។ ខ្ញុំគិតថាវាជាការសំខាន់<ក្នុងការពិនិត្យមើល>ការបង្ហាញ<ឯកសារ>ចុងក្រោយ<នេះ>។ យើងបានធ្វើការគណនាបែបគណិតវិទ្យា ហើយឥឡូវនេះ យើងឃើញថាមានការដាក់បង្ហាញ ១៣<លើក ចាប់តាំងលើកទី១ នៅក្នុង>ខែវិច្ឆិកា ឆ្នាំ២០១៤មកម្ល៉េះ។ ការដាក់បង្ហាញទាំង១៣លើកនេះ គឺធ្វើឱ្យយើងទទួលបាននូវឯកសារសរុបចំនួន ៧.៧៤៤ទំព័រ រួមបញ្ចូលជាមួយនឹងឯកសារ <៦០០>ទំព័រទៀត<គឺសរុបទៅ>មានឯកសារទាំងអស់<>៨.៣៤៤ទំព័រ <ដូច្នេះវាមានចំនួនជិត ៨.៥០០ទំព័រ។ ដើម្បីជាការរំឭកជូនទៅដល់អង្គជំនុំជម្រះ ចំពោះការដាក់បង្ហាញឯកសារនាពេលមុនៗនេះ គឺខ្ញុំយោងឧទាហរណ៍មួយនៅថ្ងៃទី២០> ខែមីនា <ឆ្នាំ២០១៥> យើងទទួលបានប្រហែលជា ២៦០០<ទំព័រ។> ហើយការដាក់បង្ហាញ<ឯកសារ លើកទី>១០ <គឺនៅថ្ងៃទី២៨> ខែមេសា ២០១៥ គឺយើងទទួលបានប្រហែល<១.០៥៧>ទំព័រ ហើយឥឡូវនេះ យើងទទួលបាន ៦០០ទំព័រទៀត គឺ<ដូចអ្វីដែលខ្ញុំបាននិយាយអ៊ីចឹង ជាសរុបគឺ>យើងទទួលបានប្រហែលជា ៨.៥០០ទំព័រ។

នៅពេលដែលយើងនិយាយអំពីធនធានរបស់មេធាវីការពារក្តី <ថាតើ>មេធាវីការពារក្តី<អាចមានលទ្ធភាពក្នុងការអាន>ឯកសារ<ថ្មីទាំងអស់>ពីសំណុំរឿង០៣, ០៤<បានដែរឬទេ? មានចម្លើយតែមួយគត់>ដែលយើងអាចផ្តល់ជូនបាននៅពេលនេះ <គឺមានលទ្ធភាពតិចណាស់។> យើងមានកាល

<វិភាគ>សវនាការ<ដែលទាមទារពេលវេលាច្រើនក្នុងប៉ុន្មានខែចុងក្រោយនេះ នៅមុនពេលសម្រាកសវនាការ។ ជាក់ស្តែង> យើងក៏ត្រូវត្រៀមសម្រាប់សវនាការបីរបស់អង្គជំនុំជម្រះតុលាការកំពូលសម្រាប់បណ្តឹងសាទុក្ខរបស់យើង <នៅ>ដើមខែកក្កដា<។ អ៊ីចឹង តើ>យើង<អាចទេ ទៅ>ពិនិត្យមើលឯកសារទាំងអស់នេះ<ឲ្យបានត្រឹមត្រូវ ក្នុងន័យវិភាគ>ឯកសារទាំងអស់នេះជាភស្តុតាង<? មិនអាចទេ។> គឺថាចម្លើយ<ចំពោះសំណួរនេះគឺមិនអាចតែម្តង។>

[០៩:៣៩:១២]

<តើយើង>អាចពិភាក្សាខ្លឹមសារនៃឯកសារដែលដាក់បង្ហាញ<ទាំងអស់នេះ>ជាមួយកូនក្តីរបស់យើងបាន<ដែរឬទេ? ចម្លើយគឺ អត់ទេ>។ ឥឡូវនេះ មួយថ្ងៃមុនយើងចាប់ផ្តើមផ្នែកថ្មីនៃសវនាការ គឺយើងត្រូវប្រឈមជាមួយនឹងឯកសារ ៦០០ទំព័រថ្មីបន្ថែមទៀត។ ដូច្នេះ យើងគឺថាយើងមិនអាចធ្វើពុតជាថាយើងអាចអានឯកសារនេះចប់គ្រប់នោះឡើយ ហើយខ្ញុំក៏មិនដឹងថា តើលោកចៅក្រមអង្គជំនុំជម្រះសាលាដំបូងធ្វើយ៉ាង<ម៉េច>អាចអានឯកសារនេះឲ្យបានចប់សព្វគ្រប់<បាន>។ ហើយយើងត្រូវគិតផងដែរ អំពីធនធានរបស់យើងជាមួយនឹងធនធានរបស់សហព្រះរាជអាជ្ញា <គឺយើងមិនអាចមើលចប់>។ នេះជាចំណុចទី១ របស់ខ្ញុំ។ ចំណុចទី២ ដែលខ្ញុំចង់លើក គឺថាខ្ញុំនៅតែឆ្ងល់ទាក់ទងទៅនឹងពេលវេលា ខ្ញុំបានស្តាប់ដោយយកចិត្តទុកដាក់ទៅលើព្រះរាជអាជ្ញាអន្តរជាតិ ដែលបាននិយាយអំពីកាលបរិច្ឆេទនៃ<>ការដាក់ឯកសារពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី<ទាំងអស់នេះ>។ ទោះៗបីថា ខ្ញុំពិនិត្យមើលទៅលើ<កាលបរិច្ឆេទហ្នឹងក្តី> ឧទាហរណ៍ដូចជា លេខ៣ គឺពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ D5857 <ប្រសិនបើមិនមែនដាក់តាំងពីឆ្នាំ២០០៩ទេ និយាយអ៊ីចេះវិញ ដាក់តាំងពីឆ្នាំ២០១៣ ហេតុអ្វីបានជាយើងត្រូវ ប្រើរយៈពេលដល់ទៅ>ពីរឆ្នាំ<ដើម្បីដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមណ្តឹងរដ្ឋប្បវេណី របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទៅវិញ?> ហេតុអ្វីបានជា គេរង់ចាំទើបតែមកបង្ហាញនៅពេលនេះទៅវិញ? <ខ្ញុំមិនយល់សោះ ម៉េចបានត្រូវ>ពន្យារពេលដល់ទៅពីរឆ្នាំបែបនេះ? មានឯកសារ<មួយចំនួនផ្សេង>ទៀត ដែលមិនមែនជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសូម្បីតែកាលបរិច្ឆេទក៏ធ្វើឲ្យយើងឆ្ងល់ថា ហេតុអ្វីបានជាវាយ៉ាងដូច្នេះ។ ឧទាហរណ៍ដូចជា <ឯកសារទី១ គឺជាកិច្ចសម្ភាសន៍មួយពីខាងការិយាល័យសហព្រះរាជអាជ្ញា របស់បុគ្គលម្នាក់>ដែល<ខ្ញុំសូមមិនបញ្ចេញ>ឈ្មោះ<របស់គាត់ទេ ប៉ុន្តែចុះកាលបរិច្ឆេទ>ថ្ងៃ០៥ ខែសីហា ២០០៨។ ហេតុអ្វីបានទើបមកដាក់<នៅ>រយៈពេលប្រាំពីរឆ្នាំក្រោយមកនេះទៅវិញ។ <ខ្ញុំមិនយល់សោះ។>

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៤១:៣២]

<មានរបាយការណ៍ទីតាំងឧក្រិដ្ឋកម្មមួយនៃ>ដីកាចាត់បង្គាប់ឱ្យស៊ើបជំនួស <ចុះខែកញ្ញា> ឆ្នាំ២០១១ ប៉ុន្តែហេតុអ្វីទើបយកមក<ដាក់នៅពេលនេះ។ នេះក៏ជារឿងមួយទៀតខ្ញុំមិនយល់ដែរ>។<> ដូចគ្នាចំពោះកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅក្នុងសំណុំរឿង០០៤ ខ្ញុំពិនិត្យទៅលើឯកសារមួយចំនួន <គឺមាន>ឯកសារមួយ<>មកពីខែមីនា ២០១៥ ឯកសារ<មួយពីខែមេសា ឆ្នាំ២០១៥, ឯកសារមួយ> មកពីខែឧសភា <ឆ្នាំ២០១៥ ហើយ>ឯកសារ<មួយ>មកពីថ្ងៃ១០ មិថុនា <ឆ្នាំ២០១៥>។ យើងដឹង <ច្បាស់ហើយថា>ផ្នែកនៃសវនាការនេះ ត្រូវបានគ្រោងតាំងពីមុនពេលដែលយើងឈប់សម្រាក<មក ម៉្លេះ។ ចុះ>ហេតុអ្វីបានជាយើងត្រូវមកប្រឈមជាមួយកំណត់ហេតុស្តាប់ចម្លើយនៅដំណាក់កាលបែប នេះទៅវិញ។

ដូច្នេះ ខ្ញុំគិតថាការចាត់ចំណាត់ថ្នាក់ ឬក៏ការរៀបចំបែបនេះ គឺវាមិន<ត្រូវនឹងរយៈពេលនៃឆ្នាំ កន្លងមក តែវាពិតជាតិចជាងជ្រុលហើយ>។ <សរុបទៅ> យើងមិនមានលទ្ធភាព ឬក៏យើងមិនអាច សាកសួរសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែល<នឹង>ត្រូវមកបង្ហាញ<នាពេលខាងមុខ>នេះឡើយ។ <ពិតណាស់ យើងត្រូវពិនិត្យ>មើល<ឯកសារទាំងនោះ តែយើងមើល>ដោយត្រួសៗ<ប៉ុណ្ណោះ> ទៅ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹង<ថ្មីទាំងអស់នេះ ថាតើពួកគេមានផលប៉ះពាល់ចំពោះសាក្សីដែលនឹង ត្រូវមកនាពេលខាងមុខនេះ ឬក៏អត់>។ ដូច្នេះ <សំណួរចម្បងរបស់យើងគឺថា> ហេតុអ្វីបានជាយើង អនុញ្ញាតឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ ចូលទៅក្នុងសំណុំរឿងរបស់យើង ទៅវិញ? ថាតើឯកសារនេះ វាសំខាន់នៅត្រង់ចំណុចណាខ្លះ? តើហេតុអ្វីទើបធ្វើឱ្យឯកសារនេះអាច ទទួលបញ្ចូលទៅក្នុងសំណុំរឿងបាន? ហេតុអ្វីក៏មិនទុកឱ្យចៅក្រម ហើយនិងមេធាវីសំណុំរឿង០០៣, ០០៤ ដោះស្រាយ<រឿងពាក្យសុំតាំងខ្លួន>ដើមបណ្តឹងរដ្ឋប្បវេណី<ទាំងអស់>នេះទៅ? ហេតុអ្វីបាន ជាវាជាការចាំបាច់ឱ្យសំណុំរឿង០០២ <ពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជា>ដើមបណ្តឹងរដ្ឋប្បវេណី<ទាំង អស់>នេះទៅវិញ<?> ខ្ញុំ<>ដឹងថាមានអ្វីនៅពីក្រោយខ្នងនោះ <តែខ្ញុំគ្រាន់តែ>ស្មាន<ប៉ុណ្ណោះ។> ប៉ុន្តែអ្វីដែលខ្ញុំអាចប៉ាន់ស្មានបាន គឺថាសំណុំរឿង០០៣, ០០៤ ប្រហែលជានឹងមិនមាន ឬក៏នឹងប្រហែល ជានឹងមិនកើតឡើង។ ហេតុដូច្នេះហើយ ទើបយើងដាក់បញ្ចូលឯកសារជាច្រើនភស្តុតាងជាច្រើនពី សំណុំរឿង០០៣, ០០៤ មកចូលនៅក្នុងសំណុំរឿង០០២ ទៅវិញ។ ប៉ុន្តែ<ត្រឡប់ទៅនិយាយអំពីការ កត់សម្គាល់ដែលខ្ញុំលើកឡើងខាងដើម យកមកគិតលើ>ចំនួនឯកសារ ៨.៥០០ទំព័រជាងនោះ <ខ្ញុំគិតថា

យើងនឹងឈានដល់ពេលមួយ ខ្ញុំហៅថា> “វាល្មមគ្រប់គ្រាន់ហើយ”<>។ <គួរតែទុកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ នៅកន្លែងដើមរបស់វាទៅ គឺក្នុង>សំណុំរឿង០០៣ <និង> ០០៤ <ហើយ>ទុកឱ្យមេធាវី និងចៅក្រមសំណុំរឿង០០៣, ០០៤ ជាអ្នកដោះស្រាយទៅវិញទៅ។ ដូច្នេះ<បើសិនជាអង្គជំនុំជម្រះ គិតថាវាមិនមែនជា>ស្ថានភាពនេះ<ទេ> គឺ<ប្រាកដណាស់>យើងត្រូវការពេលវេលាបន្ថែមដើម្បីពិនិត្យមើលទៅលើឯកសារទាំងអស់នេះ។

[០៩:៤៤:៥៩]

<យើងមិនទាន់បានទទួលនូវឯកសារទាំងអស់នោះទេ គឺ>អាចនិយាយថា យើងស្ថិតនៅក្នុងស្ថានភាពសំណាងមួយដោយសារតែថ្ងៃពុធ ថ្ងៃព្រហស្បតិ៍ គឺយើងមានសាក្សី<ចំនួនពីរ> ដែលមិនពាក់ព័ន្ធទៅនឹងផ្នែកនេះ។ ដូច្នេះ ការដែលយើង<ពន្យារពេលស្តាប់សក្ខីកម្ម>ដើមបណ្តឹងរដ្ឋប្បវេណីនៅថ្ងៃនេះ និង<សាក្សីម្នាក់នៅ>ថ្ងៃស្អែក គឺអាចផ្តល់ពេលវេលាមួយអាទិត្យបន្ថែមដល់យើងទៀត។ តែទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថាវាមិនអាចជៀសវាងបានឡើយដែលថាយើងត្រូវការពេលវេលា ក៏ដូចជាធនធានគ្រប់គ្រាន់ដើម្បីអានទៅលើពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណី<>ទាំងអស់នេះ។ <ខ្ញុំគិតថាវាមិនមែនជាបញ្ហានោះទេ។> មតិចុងក្រោយរបស់ខ្ញុំៗសុំបន្ថែមថា ពាក្យសុំតាំងខ្លួនទាំងអស់នេះ មិនមែនគ្រាន់តែជាពាក្យសុំតាំងខ្លួននោះ<ទេ។>សុំណុំរឿង០០២/០១ ពាក្យសុំតាំងខ្លួន<ទាំង>នេះត្រូវបានប្រើប្រាស់ជាភស្តុតាងយ៉ាងសំខាន់។ ដូច្នេះ ផ្អែកទៅតាមបទពិសោធន៍របស់យើងនៅក្នុងសំណុំរឿង ០០២/០១ <>ពាក្យសុំតាំងខ្លួននេះចាំបាច់<ក៏ត្រូវគេយកមក>ពិចារណា<ដែរ ហើយផ្តល់ទម្ងន់ជាតម្លៃ>ភស្តុតាង<ឱ្យដូចគ្នាទៅនឹងសក្ខីកម្មដែលផ្តល់ដោយសាក្សីផងដែរ>។ <>បន្ថែមពីលើនេះទៀតយើងបានឃើញថាសំណុំរឿង ០០២/០២ <ក្នុងការជំនុំជម្រះបច្ចុប្បន្ន> គឺមានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន<មានភាពខ្វះចន្លោះគ្រប់បែបគ្រប់>យ៉ាង<។ ពេលខ្លះ សាក្សីមកផ្តល់សក្ខី-កម្មនៅទីនេះ ហើយនិយាយថា “គាត់មិនដែលនិយាយដូច្នេះទេ។” មានគេសរសេរឱ្យ តែមិនស្គាល់ឈ្មោះ> ហើយអ្នកនោះជួនកាល មិនទាំងដឹងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីចង់និយាយអ្វីឱ្យពិតប្រាកដផង។>។ ដូច្នេះ យើងត្រូវតែប្រុងប្រយ័ត្នអំពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី<ទាំងអស់នេះ>។ ដូច្នេះ ខ្ញុំគិតថានេះជាបញ្ហាមួយ។ យើងមិនគួរធ្វើ<ការ>បំបែកឱ្យខុសគ្នារវាងពាក្យសុំតាំងខ្លួន<ជាដើមបណ្តឹងរដ្ឋប្បវេណី> ជាមួយនិងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី<នោះ>ឡើយ។ ដូច្នេះលោកប្រធាន ខ្ញុំសូមស្នើថា ទី១ បដិសេធសំណើនេះ។ ទី២ ប្រសិនបើលោកប្រធានមិនបដិសេធសំណើនេះទេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្ទបកប្រែ និងខ្ទបកប្រែបន្ត។*

គឺថាគួរតែផ្តល់ពេលវេលាថ្ងៃនេះ និងថ្ងៃស្អែកដល់<យើង>ដើម្បីពិនិត្យមើលទៅលើការដាក់ឯកសារថ្មីនេះ<ផង>។ សូមលោកប្រធានអនុញ្ញាត។

[០៩:៤៧:១១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

<ចាស> សូមអរគុណលោកប្រធាន ជម្រាបសួរអស់លោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ <>លោកប្រធានខ្ញុំចង់និយាយថា <តាមទស្សនទានរបស់ក្រុមមេធាវីការពារក្តីរបស់លោក ខៀវ សំផន យើងយល់ថា បញ្ហា>ខ្វះការបញ្ជូនឯកសារពីសំណុំរឿង០០៣, ០០៤ មកនេះ គឺវាមានកាន់តែថាធំឡើងៗ ហើយបង្កើតឱ្យមានភាពអយុត្តិធម៌ក្នុងការកាត់សេចក្តី។ ខ្ញុំយល់ឃើញថា ខាងសហព្រះរាជអាជ្ញានោះ ដូចជាមើលស្រាលការងារនេះ <ត្រង់ថា> គាត់និយាយថាតែមួយ<>រសៀលហ្នឹង <គាត់>អាចអានឯកសារ<ថ្មីទាំង៥៤នេះចប់>។ <នេះគឺជាអ្វីដែលគាត់បានផ្តល់យោបល់កាលពីព្រឹកមិញនេះ។> ខ្ញុំថាការគិតដូច្នេះ ជាការមើលស្រាលការងារ<ខាងក្រុមការពារក្តី> ព្រោះថាកាលណាយើងផ្តល់ឯកសារមកនោះ យើងមិនត្រឹមតែអាន<ត្រួសៗ>តែប៉ុណ្ណឹងទេ គឺយើងត្រូវធ្វើការការពារកូនក្តីរបស់យើង<ឱ្យបានត្រឹមត្រូវ គឺ>ត្រូវវិភាគឯកសារ ផ្ទៀបឯកសារទៅនឹងឯកសារផ្សេងៗទៀត។ ដូច្នេះត្រូវការវិភាគល្អិតល្អន់ណាស់<> អ៊ីចឹងព្រះរាជអាជ្ញា យកការងារដែលធ្វើ<រួចរាល់ហើយ> ដោយសហការីរបស់ខ្លួនពីមុនមកហើយហ្នឹង។ <ដូច្នេះគាត់អាចអានឯកសារទាំងអស់ហ្នឹងបានឆាប់។ នេះគឺជាជម្រើសរបស់គាត់> នេះជារបៀបការងាររបស់គាត់ៗធ្វើអ៊ីចឹង។ ក៏ប៉ុន្តែកុំ<រំពឹង>ឱ្យខាងការពារក្តីធ្វើការងារដូចគាត់នោះ <ធ្វើតាមរបៀបបន្ទាន់បែបហ្នឹងនោះ។ នេះជាចំណុចទី១ ដែលខ្ញុំចង់លើកឡើង>។ ចំណុចសំខាន់មួយទៀតនោះដែលខ្ញុំចង់លើកឡើងគឺ ការធ្វើការផ្ទេសប្រហែសរយៈពេល <ប៉ុន្មានសប្តាហ៍ ឬ>ប៉ុន្មានខែចុងក្រោយនេះ គឺការបញ្ជូលនៅក្នុងសំណុំរឿង០០២ នូវឯកសារជាច្រើនដែលចេញពីការស៊ើបអង្កេតដែលកំពុងធ្វើ។ ខ្ញុំសូមសង្កត់ធ្ងន់លើចំណុចនេះ ពីព្រោះថា នៅពេលដែលមេធាវី នួន ជា បានលើកឡើងអម្បាញ់អ៊ីចឹង គឺថាមាន មេធាវីការពាក្តីនៅក្នុងសំណុំរឿង០០៣, ០០៤ គឺមានមេធាវីដែរ ហើយមានច្បាប់ ក្របខ័ណ្ឌច្បាប់ដែរនៅក្នុងសំណុំរឿងទាំងអស់ហ្នឹង ដែលសង្កត់ទៅលើអ្នក ជនសង្ស័យ ឬជនជាប់ចោទសំណុំរឿង០០៣, ០០៤ <ហើយ>នោះវាមិនពាក់ព័ន្ធនឹងសំណុំរឿង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

០០២ យើងនេះទេ។ អ៊ីចឹង<មានសំណើសុំ>ដាក់បញ្ចូលឯកសារ<ថ្មីៗ>មក<កើនឡើង>រហូតនោះ <ដូចសហភាតារបស់ខ្ញុំបានលើកឡើងចំនួនច្បាស់លាស់ហើយ> គឺថា<>យើងអត់ក្តាប់ឯកសារទាំងនេះបានទេ។ អ៊ីចឹង ឥឡូវនេះយើងត្រូវដឹងថា តើគោលបំណងនៃការបញ្ចូលឯកសារទាំងអស់នេះជាអ្វី វាជាឯកសារដោះបន្ទុកឬយ៉ាងណា<?> បើសិនជាឯកសារដោះបន្ទុក យើងចាប់អារម្មណ៍ ហើយយើងចង់ដឹងថាកន្លែងណាដែលអាចដោះបន្ទុកបាន ឬក៏គ្រាន់តែដាក់ភស្តុតាងបន្ថែម។ ចង់និយាយថាឯកសារដែលមាននៅក្នុងសំណុំរឿង០០២ហ្នឹង មិនគ្រប់គ្រាន់ទេឬក៏យ៉ាងណា<? អ្វីដែលខ្ញុំបានឮ> ព្រះរាជអាជ្ញាកាលពីព្រឹកមិញនេះ និយាយទៅដោយសង្ខេបទៅថា ឯកសារទាំងអស់នេះស្រួលអានទេ អានមួយភ្លែតទៅវាចប់ទៅហើយ គ្មានឯកសារអ្វីពិបាកទេ មិនមានព័ត៌មានថ្មីអ្វីនោះទេ។ <ប៉ុន្តែ>បើសិនជាអ៊ីចឹងមែននោះ <ហេតុអ្វី>ចាំបាច់បញ្ជូនដាក់បន្ថែមមក<ក្នុងសវនាការនេះ>ធ្វើអ្វី<?> បើដាក់មក មិនចប់មិនហើយ ហើយយើងមិន ក្តាប់ឯកសារនេះមិនបាន<ផង? ខ្ញុំសូមរំឭកផងដែរថា យើងមិនមែនជាភាគីមួយក្នុងកិច្ចដំណើរស៊ើបអង្កេតក្នុង>សំណុំរឿង០០៣, ០០៤ <នោះទេ>។ អ៊ីចឹង <ប្រតិកម្មដំបូងរបស់ខ្ញុំគឺ>បើសិនជាឯកសារទាំងអស់នេះមិនសូវសំខាន់ទេ ដូចដែលព្រះរាជអាជ្ញាបានលើកឡើងកាលពីព្រឹកមិញនោះ អ៊ីចឹង<យើងមិនគួរទទួលយកវាទេ គឺ>យើងជំទាស់តែម្តង<ទៅ> ព្រោះថាវាអត់មានបញ្ហាអីទេ វាអត់សំខាន់តែម្តង ហើយមិនបាច់ពន្យារពេលអ្វីទេ។ <នេះជាចំណុចទី៣ ដែលខ្ញុំទទូច។>

[០៩:៥១:០៧]

ប៉ុន្មានខែចុងក្រោយនេះ<>គឺយើងដូចជាអ្នកសុំទាន សុំពន្យារពេលវេលាអ៊ីចឹងរាល់ថ្ងៃ បើធ្វើទៅតែកូនក្តីយើងមានជាប់ពាក់ព័ន្ធ ព្រោះថាលក្ខខណ្ឌការងារកាន់តែយ៉ាប់ទៅៗ ការងារ បន្ទុកការងារកាន់តែច្រើនក្នុងពេលតែមួយ ហើយយើងត្រូវតែមានភាពបត់បែនភាគច្រើន ហើយធ្វើការមិនខ្លាចហត់នឿយ ធ្វើយ៉ាងណាដើម្បីការងារកូនក្តីយើងឲ្យបាន ពីព្រោះថាយើង គោលបំណងរបស់យើង យើងចង់ឲ្យដំណើរការកាត់សេចក្តីទៅមុខហើយ ហើយកុំឲ្យកូនក្តីយើងជាជនរងគ្រោះផងដែរ។ ឥឡូវនេះ <នៅថ្ងៃនេះ គេបានប្រាប់យើងថាមាន> “ឯកសារ<ចំនួន៥៤ គឺមាន>៥០០<ទំព័រ ប៉ុន្តែជាក់ស្តែងគឺមានតែ៩៤ទំព័រប៉ុណ្ណោះ> ដែលសំខាន់នោះ។” <នេះជាសម្តីរបស់សហព្រះរាជអាជ្ញា។ ខ្ញុំមានអារម្មណ៍ថានេះជាគោលជំហរខាងសហព្រះរាជអាជ្ញា ប៉ុន្តែនៅក្នុងខណៈពេលនេះ ខ្ញុំមិនទាន់បានចូលមើល>ឯកសារទាំងអស់នេះ<ផង។ ដោយសារឯកសារទាំងអស់នោះយកចេញពីសំណុំរឿងដែលកំពុងតែនៅបន្តដំណើរការស៊ើបអង្កេត គឺយើងត្រូវ>ចុះហត្ថលេខា<លើទម្រង់បែបបទមួយ ដើម្បីអាចចូលទៅមើល

ឯកសារទាំងអស់នោះបាន។>។

<>កាលថ្ងៃសុក្រ យើងអត់បានមកកន្លែងនេះទេ ហើយទើបតែមកដល់ទីនេះ<នៅថ្ងៃនេះ។ ដូច្នេះនៅថ្ងៃនេះ យើងចុះហត្ថលេខាទម្រង់បែបបទដើម្បីអាចចូលមើលឯកសារទាំងអស់នោះបាន។> ហើយឯកសារភាគច្រើនហ្នឹងអត់មានបកប្រែជាភាសាបារាំងទេ អ៊ីចឹង <ជាថ្មីម្តងទៀត> យើងសុំឲ្យពន្យារពេលដើម្បីឲ្យយើងអាចអានឯកសារទាំងអស់នេះបាន វិភាគឯកសារទាំងអស់នេះបាន ហើយធ្វើការជាមួយនឹង<>សហការីរបស់យើងដែលធ្វើការជាភាសាខ្មែរ <និងភាសាអង់គ្លេស>។ <នេះជាចំណុចមួយ។> ហើយស្រាប់តែ<នៅថ្ងៃ>នេះ គេនិយាយថា "យើងអាចបន្តដំណើរការនីតិវិធីដោយមិនមានបញ្ហាអ្វីទេ ព្រោះថាមិនប៉ះពាល់ដល់មេធាវីការពារក្តីនោះទេ <កុំបារម្ភ>។ <អង្គជំនុំជម្រះអាចបន្តដំណើរការសវនាការដូចធម្មតាបាន។"> បើអ៊ីចឹង ខ្ញុំសួរថាមានប្រយោជន៍អីឯកសារទាំង៥៤<នេះ បើយើងអាចដំណើរការនីតិវិធីដូចធម្មតានោះ? ខ្ញុំសួរអង្គជំនុំជម្រះ ប្រសិនបើឯកសារទាំងអស់នេះ ពុំមានចំណុចអ្វីសំខាន់ទេ គឺគួរតែដកឯកសារទាំងអស់នោះចេញទៅ ទុកមួយឡែកទៅ។ បើសិនជាឯកសារទាំងអស់នោះមានគោលបំណងជាក់លាក់មួយ បើសិនជាមានសារៈប្រយោជន៍នោះ ហើយបើសិនជា> ព្រះរាជអាជ្ញា<មានបំណង>ប្រើ<ប្រាស់>ឯកសារទាំង៥៤ហ្នឹង<នាពេលឥឡូវនេះ ឬក៏នាពេលក្រោយតាមសំណើសុំដាក់បញ្ចូលជាឯកសារភស្តុតាងស្របតាមវិធាន៨៧(៤) អ៊ីចឹងនោះ>សូមឲ្យទុកពេលវេលាឲ្យមេធាវីការពារក្តីមានពេលវិភាគឯកសារទាំងអស់ ធ្វើយ៉ាងណាឲ្យមានភាពស្មើគ្នានៃគូភាគី។ <នៅ>ថ្ងៃនេះ យើង<និយាយទាំងងងឹតងងល់>អ៊ីចឹង គឺយើងកំពុងតែនិយាយអំពីឯកសារទាំងអស់នេះ ដោយគ្រាន់តែបានមើលសេចក្តីរៀបរាប់នៅក្នុងឧបសម្ព័ន្ធឯកសារប៉ុណ្ណោះ។> យើងអត់<ដឹងអំពីខ្លឹមសារនៃឯកសារនោះទេ។ ខ្ញុំមិនអាចឆ្លើយប្រាប់អង្គជំនុំជម្រះថា បាន ឬមិនបាននោះទេ ប្រសិនបើយើងបន្តដំណើរការសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីតាមរបៀបបែបនេះ។> អ៊ីចឹង<ដំណោះស្រាយដែលស្រួលនោះ ជាថ្មីម្តងទៀត>គឺថា<ដក>ឯកសារទាំងអស់នេះ<ចេញពីសំណុំរឿងនេះ> ហើយ<ព្យាយាមកុំប្រើប្រាស់ឯកសារក្នុងសំណុំរឿង០០២ ដែលចេញមកពី>សំណុំរឿង០០៣, ០០៤ ដោយមិនទាន់នឹងចប់<នីតិវិធីស៊ើបអង្កេត។ ការស៊ើបអង្កេតកំពុងបន្ត ហើយយើងក៏មិនដឹងថាមានអ្វីកើតឡើងផងក្នុងដំណើរការហ្នឹង។ យើងមិនដឹងថា គេបានធ្វើសំណើអ្វីផង ជាសំណើដែលស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះមកធ្វើសក្ខីកម្មបញ្ជាក់។>

[០៩:៥៤:២០]

អ៊ីចឹងដូចមេធាវីរបស់លោក នួន ជា បាននិយាយអ៊ីចឹង<កាលពីពីរបីសប្ដាហ៍មុន នៅចំពោះមុខ អង្គជំនុំជម្រះ> គឺថាឯកសារនៃដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹងមានចំនួនច្រើន <គឺមានបំពេញឈ្មោះ ហ្នឹង>មិនអាចទុកចិត្តបាន។ <នៅថ្ងៃនេះ យើងមិនចង់ឲ្យមានការដាក់បញ្ចូលឯកសារទាំងអស់នោះក្នុង សំណុំរឿង ដោយមិនដឹងថា ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នោះ នឹងមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គ ជំនុំជម្រះបាននោះទេ។> អ៊ីចឹង <មានពីរចំណុច> បើសិនជា<ព្រះរាជអាជ្ញាមានហេតុផលជាមូលដ្ឋាន >ចង់<ឲ្យទទួលជាភស្តុតាង ឬចង់ឲ្យស្ដាប់សក្ខីកម្មទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ ព្រះរាជអាជ្ញា គួរដាក់សំណើមក ហើយត្រង់ចំណុចនេះ> យើងត្រូវតែពិភាក្សាគ្នាឲ្យបានត្រឹមត្រូវ តទល់គ្នា<។ ខ្ញុំ និយាយលឿនពេក គេស្ដាប់ខ្ញុំមិនយល់ទេ, ខ្ញុំនឹងព្យាយាមនិយាយឲ្យយឺតជាងហ្នឹង។ ដូច្នេះ ប្រហែលត្រូវ តទល់គ្នានៅត្រង់ចំណុចនេះ។> ព្រះអាជ្ញា<មានបំណងហៅបុគ្គលមួយចំនួនមកធ្វើសក្ខីកម្មនៅមុខអង្គ ជំនុំជម្រះ ហើយព្រះរាជអាជ្ញាដាក់សំណើមកសម្រាប់គោលបំណងកោះហៅហ្នឹង។ តែយ៉ាងណាក៏ ដោយ ក៏យើងលែងទទួលយកសក្ខីកម្ម ឬឯកសារជាលាយលក្ខណ៍អក្សរដ៏ច្រើនរាប់មិនអស់នេះហើយ ព្រោះយើងមិនដឹងច្បាស់អំពីឯកសារទាំងនោះ។ ចំណុចមួយដែលច្បាស់នោះ បើសិនណាអង្គជំនុំជម្រះ សម្រេចយកឯកសារទាំងនេះមកដាក់បង្ហាញចំពោះភាគីនោះ ហើយភាគីអាចប្រើប្រាស់ឯកសារនោះ បាន វាច្បាស់ណាស់ថា យើងមិនអាចស្ដាប់សក្ខីកម្មបានទេ ចំពោះសាក្សីណាក៏ដោយដែលមាន> ទាក់ទងទៅនឹងការដ្ឋានត្រពាំងថ្ម<។ ត្រង់នេះ យើងត្រូវឲ្យប្រាកដទាំងអស់គ្នា>។ អ៊ីចឹងយើងមិនអាច បន្តដំណើរការសវនាការដូច<ធម្មតា>បានទេ ពីព្រោះថាយើងហាក់ដូចជាមនុស្ស<ខ្វាក់>ទៅហើយ បើ ធៀបទៅនឹងព្រះរាជអាជ្ញានោះ។

មានចំណុចសំខាន់មួយទៀតដែលយើងត្រូវ<ត្រឡប់>និយាយគឺថា និយាយទាក់ទងទៅនឹងទម្ងន់ នៃ<កំណត់ហេតុស្ដាប់>ចម្លើយ<ដែលបានដាក់បញ្ចូលរួចមកហើយនៅក្នុងសំណុំរឿង តាមរយៈកិច្ច ដំណើរការនេះ និង>សំណើដាក់ឯកសាររបស់ព្រះរាជអាជ្ញាទាំងអស់នេះ<។ ជាថ្មីម្ដងទៀត> យើងខ្ញុំ សូមរំឭក<អង្គជំនុំជម្រះថា យើងកំពុងតែដោះស្រាយទៅលើសំណុំរឿងមួយ ដែលកំពុងតែនៅបន្តនីតិវិធី ស៊ើបអង្កេតនៅឡើយ ដែល>លោក ខៀវ សំផន គាត់មានសិទ្ធិរបស់គាត់ <ហើយឥឡូវនេះ ការស៊ើប អង្កេតនៅតែបន្តនៅឡើយ> ហើយយើងមិនចេះតែអាចយក<កំណត់ហេតុស្ដាប់>ចម្លើយ<ពី>សំណុំ រឿង០០៣, ០០៤ ដែលគេកំពុងតែស៊ើបអង្កេតនោះយកមកដាក់បញ្ចូលសំណុំរឿង ០០២ហ្នឹងរហូតទេ។ អ៊ីចឹងជម្រើសមានតែមួយទេ គឺថាបដិសេធ<ទាំងស្រុងនូវ>ឯកសារ<ថ្មីទាំងអស់>នេះចោល យើងបន្ត

សវនាការយើងធម្មតា។ បើសិនជាយកឯកសារទាំងអស់នេះមក<ដាក់ពិភាក្សាដេញដោល នោះយើងត្រូវការពេលវេលាដើម្បីពិនិត្យមើលឯកសារទាំងអស់នោះសិន ហើយចំពោះសវនាការរយៈពេលពីរថ្ងៃគិតរហូតមកដល់ថ្ងៃនេះ គឺវាមិនគ្រប់គ្រាន់នោះទេ ដូច្នេះ>មេធាវីការពារក្ដីយ៉ាងហោចណាស់ក៏<ត្រូវការពេល>មួយអាទិត្យ <បន្ថែមពីរថ្ងៃនៃសប្ដាហ៍នេះទៀត ពីព្រោះយើងយើងមិនមានបញ្ហាអ្វីនោះទេក្នុងការ>បន្តសវនាការ<ស្ដាប់សក្ខីកម្មសាក្សីពាក់ព័ន្ធនឹង>ព្រលានយន្តហោះកំពង់ឆ្នាំង <និងទំនប់>១ មករា។<តែកុំនិយាយថា ការដាក់បង្ហាញឯកសារនេះមិន>មានផលប៉ះពាល់ច្រើន<>មកលើ<ការងារត្រៀមរបស់>ភាគីការពារក្ដី<ឲ្យសោះ។ វាមិនពិតទេ ហើយនេះជាទស្សនៈខាងព្រះរាជអាជ្ញាតែប៉ុណ្ណោះ>។

[០៩:៥៧:៤២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ទី១ យើងខ្ញុំចង់ផ្ដល់នូវបច្ចុប្បន្នភាពពាក់ព័ន្ធទៅនឹងព័ត៌មានដែលខ្ញុំ<ទទួលបាន ទៅនឹង>សំណួររបស់លោកចៅក្រម ឡាវែន៍។ <ខ្ញុំគិតថា អ្វីដែលកើតឡើងនោះ គឺថា>មុននឹងយើង<បាន>ដាក់<បញ្ចូលឯកសារជាផ្លូវការ ហើយបានផ្ញើជូនសំណៅដំបូងនៃឧបសម្ព័ន្ធ អ៊ីចឹងទៅ គេអាចចាប់ផ្ដើមដំណើរការដាក់លេខ និងចាត់ចំណាត់ថ្នាក់>ឯកសារហ្នឹង<>។ ហើយអ្វីដែល<មាននៅក្នុងដៃរបស់លោកចៅក្រម មិនមែនជាសំណៅឧបសម្ព័ន្ធ ដែលបានដាក់ចូលនោះទេ តែជាសំណៅដំបូងវិញទេតើ។ ដូច្នេះ នេះជាហេតុផលដែលគេបានប្រាប់>ខ្ញុំ<ថា> លោក លោកស្រីចៅក្រម<មានសំណៅ>ឧបសម្ព័ន្ធ<ដែល>មិនមានលេខ ERN ទេ។

ទី២ ខ្ញុំសូមឆ្លើយទៅនឹងបញ្ហាថា <តើពេលណាទៅទើប>មេធាវីការការពារក្ដីអាចចាប់ផ្ដើមពិនិត្យមើល<ឯកសារទាំងនេះ>។ ឯកសារ<ទាំងអស់>នេះបានបញ្ជូនទៅពួកគាត់នៅពេលបាយថ្ងៃត្រង់<កាលពី>ថ្ងៃសុក្រ។ ក្រុម<មេធាវី>នួន ជា បាន<ឆ្លើយតបថា ពួកគេមិនចង់បានឯកសារទាំងអស់នេះទេ។ ពួកគេនឹងមិនចុះហត្ថលេខាដើម្បីទទួលយកឡើយ។ ពួកគេមិនចង់បានឯកសារទាំងនោះលុះតែមកទល់ពេលសម្រាកបាយថ្ងៃត្រង់នៅថ្ងៃច័ន្ទ ទើបគេចង់បានវិញ។ ដូចអ្វីដែលខ្ញុំនិយាយអ៊ីចឹង គឺខ្ញុំមិនពឹងផ្អែកទៅលើកិច្ចការងាររបស់អ្នកណាម្នាក់ឡើយ គឺ>ខ្ញុំបានពិនិត្យមើលឯកសារទាំងអស់នេះ

ដោយខ្លួនខ្ញុំផ្ទាល់នៅរសៀលថ្ងៃសុក្រកន្លងទៅ<ដើម្បីពិនិត្យមើលតើមានអ្វីខ្លះនៅក្នុងបាច់ឯកសារទាំងហ្នឹង>។ ពួកគាត់បានបដិសេធមិនទទួលយកឯកសារនេះទេ<កាលពេល>បាយថ្ងៃត្រង់<នៅថ្ងៃសុក្រ>។ <>ក្រុមការពារក្តី ខៀវ សំផន <មិនបានឆ្លើយតបមកទេ សូម្បីតែ>ឆ្លើយ<តប>អ៊ីម៉ែល <ដែលយើងផ្ញើចេញកាលពីថ្ងៃសុក្រប្រាប់ថាយើងផ្តល់ឯកសារទាំងនោះឲ្យពួកគេ ក៏ពួកគេមិនបានឆ្លើយមកផង។>

បញ្ហាទី២ ខ្ញុំចង់ជម្រាបជូនអង្គជំនុំជម្រះឲ្យបានច្បាស់ នេះមិនមែនជាសំណើសុំ<ឲ្យទទួលយកឯកសារទាំងអស់នេះដាក់ចូលក្នុងសំណុំរឿង>ទេ <នេះ>គឺជាការដាក់បង្ហាញឯកសារ។ ដូច្នេះ<ការដាក់បង្ហាញ>ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០៤នេះអាច<ឲ្យ>ភាគីទាំងអស់ ទាំងអង្គជំនុំជម្រះក៏ដូចជាភាគីដទៃអាចពិនិត្យមើលបាន។ <នេះ>មិនមែនជាចេតនារបស់យើងស្នើសុំឲ្យទទួលយកឯកសារទាំងអស់នេះ<ទេ។> អ្វីដែលខ្ញុំមើលឃើញ<ថាមានសក្តានុពលភាពដែលត្រូវទទួលយកធ្វើជា>ឯកសារ<នោះ ឧទាហរណ៍គឺអ្វីដែល>ទាក់ទងទៅនឹងសាក្សី<ដែលនឹង>មកផ្តល់សក្ខីកម្ម។ ដូច្នេះ ខ្ញុំគិតថា<មាន>ភាគីណាមួយ<ប្រហែលជាចង់>ប្រើប្រាស់ឯកសារនេះ។ <ជាការពិត គឺមានភាពរួមគ្នា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងកំណត់ហេតុស្តាប់ចម្លើយជនរងគ្រោះដ៏ច្រើន គឺពួកគាត់មិនបានមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនោះទេ ដោយយើងពុំបានស្នើសុំឲ្យទទួលយកឯកសារទាំងអស់នោះទេ។> ដូច្នេះ <នេះគឺជាហេតុផល>ដែលខ្ញុំយកមកបង្ហាញឯកសារទាំងអស់នេះ ដោយសារឯកសារទាំងអស់នេះមានរួចទៅហើយ ដើម្បីឲ្យភាគីពិនិត្យមើលថានេះ បុគ្គលនេះ <>គួរឲ្យចាប់អារម្មណ៍ណាស់សម្រាប់ភាគី។ <> ដូច្នេះខ្ញុំស្នើសុំឲ្យចូលខ្លួនមកចំពោះមុខតុលាការនៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងពេល<ណាមួយនោះ ដែលនឹងបន្តទៅដល់ឆ្នាំក្រោយទៀត។>។ ដូច្នេះ យើងខ្ញុំផ្តល់ជម្រើសទៅភាគីដទៃ។ <ឥឡូវនេះ> បើមេធាវីការពារក្តីមិនចង់ឲ្យយើងខ្ញុំបង្ហាញនូវឯកសារពាក់ព័ន្ធទៅនឹងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីទេ យើង<រីករាយនឹង>ដកខ្លួនចេញពីបន្ទុកនេះបាន ក៏ប៉ុន្តែយើង<ត្រូវ>ឲ្យមេធាវីការពារក្តី<បង្ហាញការ>លះបង់សិទ្ធិ<នេះ និងថ្លែងបញ្ជាក់ឲ្យបានច្បាស់លាស់>។ ដូច្នេះ <យើងបន្តទៅមុខទៀតបាន ជំនួសឲ្យអ្វី>ដែលយើងខ្ញុំបានធ្វើនៅនេះ គឺ <ការដាក់បង្ហាញ>កិច្ចសម្ភាសន៍ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី<ទាំងអស់នេះ។ យើងនឹងនៅតែបង្ហាញឯកសារណាដែលពាក់ព័ន្ធនឹងបុគ្គលដែលនឹងមកផ្តល់សក្ខីកម្មប៉ុណ្ណោះ។ ប្រសិនបើមានពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយ ដែល>ជាឯកសារដោះបន្ទុក <គឺយើងនឹងដាក់

បង្ហាញឲ្យភាគី។ បើសិនជាមានអ្វីដែលសំខាន់ពិសេសនោះ យើងនឹងដាក់បង្ហាញឲ្យភាគីផងដែរ។> អ្វីដែលខ្ញុំយើងខ្ញុំបញ្ជាក់ទៅនេះ គឺបញ្ជាក់ថា គឺជាការបង្ហាញនូវពាក្យសុំតាំងខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម។ <នេះគឺជាភាពត្រឹមត្រូវយុត្តិធម៌មួយ ក្នុងការដាក់បង្ហាញឯកសារទាំងអស់នេះ វា>មិនមែនជាសំណើសុំឲ្យទទួលឯកសារទាំងអស់នេះទេ នេះគឺជា <ចំណុចសំខាន់មួយក្នុងការបែងចែក>លក្ខណៈខុសគ្នា<នេះ>។

[១០:០១:៤១]

ចំណុចមួយចំនួនតូចទៀត កិច្ចសម្ភាសន៍របស់សហព្រះរាជអាជ្ញានៅក្នុងឆ្នាំ២០០៨ គឺថាការបង្ហាញឯកសារនេះ <>យើងបានធ្វើយូរមកហើយ<ក្នុងខណៈពេលដែលសមាជិកក្រុមយើងខ្លះមិនទាន់មក>។ ការដែលមិនបង្ហាញឯកសារទាំងអស់នេះ<ឲ្យបានមុននោះ> គឺថាវាមិនបានបង្ហាញនូវខ្លឹមសារដុំកំភួនណាមួយទៅការដ្ឋានទំនប់ត្រពាំងថ្មនោះទេ។ <អ្នកទាំងនោះ គឺជាអ្នកដែលនិយាយថា ពួកគេស្គាល់ទីតាំងនោះ ប៉ុន្តែក្រោយ ពួកគេនិយាយថាមិនមានព័ត៌មានអំពីទីតាំងនោះ។> ដូច្នេះ សេចក្ដីណែនាំរបស់យើង <ចំពោះអ្នកដែលយល់ខុសអំពីការដាក់បង្ហាញឯកសារទាំងអស់នេះ ប៉ុន្តែ>មិនបង្ហាញឯក-សារ<របស់អ្នកដែលបានលើកឡើង>ពាក់ព័ន្ធទៅនឹង<ទំនប់>ត្រពាំងថ្មទេ <ប៉ុន្តែមិនបានផ្ដល់ព័ត៌មានអ្វីនោះទេ>។ ដូច្នេះ ឯកសារឆ្នាំ២០០៨ ដូចដែលអង្គជំនុំជម្រះបានឃើញហើយ គឺ<អត់មានព័ត៌មានអ្វីច្រើននោះទេ។ ដូច្នេះ មិនគួរណាដែលចាំបាច់ដាក់បង្ហាញនូវឯកសារទាំងអស់នេះទេ។ ខ្ញុំយល់ឃើញថា ខ្ញុំបានឆ្លើយតបទៅនឹងសំណួរទាំងឡាយហើយ បើមានសំណួរអ្វីមួយខ្ញុំនឹងឆ្លើយជូន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមការបញ្ជាក់<ពីខាង>ការិយាល័យសហព្រះរាជអាជ្ញា។ តើឯកសារហ្នឹងនៅលេខប៉ុន្មាននៅ<ក្នុងបញ្ជី>ឧបសម្ព័ន្ធ<ឯកសារនេះ?> នៅក្នុងឯកសារ ២០០៨ ដែលលោកបាននិយាយថាប្រហែលជាមិនបានផ្ដល់ជូនទៅដល់ភាគីដោយសារតែវាមិនមានភាពពាក់ព័ន្ធនោះ? តើជាឯកសារទី១ គឺ D1.3.11.3 ហ្នឹងមែនទេ?

[១០:០៣:២៩]

**លោក ឌេល លីសាក់៖**

បាទ លោកចៅក្រម គឺយើងរៀបចំទៅតាមអក្ខរក្រម <ទៅតាម>ឈ្មោះរបស់បុគ្គលម្នាក់ៗ<។ បាទ, ឯកសារនេះមានឈ្មោះដំបូង។ វា>មិនមានអ្វីដែលថាមានភាពមិនត្រឹមត្រូវនៅក្នុងការបង្ហាញឯកសារនេះ។<វាងាយស្រួលទេ> ខ្ញុំបានអាននូវចម្លើយទាំងអស់នោះកាលពីថ្ងៃសុក្រកន្លងទៅនេះ។ សាក្សីបានឆ្លើយថា គាត់បានចូលរួមនៅក្នុងការលើកទំនប់ត្រពាំងថ្ម ហើយក្រោយមក ដោយសួរថាតើស្ថានភាពនៅទីនោះយ៉ាងម៉េច? <គាត់ឆ្លើយថា> "ខ្ញុំអត់បានចូលរួមធ្វើការទេ"<>។ ដូច្នេះ<ចំពោះរូបខ្ញុំ> បើសិន<ជាខ្ញុំបាននៅទីនេះ ពេលដែលដាក់បង្ហាញឯកសារហ្នឹង យើងនឹងមិនដាក់បង្ហាញឯកសារហ្នឹងទេ ពីព្រោះវាហាក់បីដូចជាពុំមានទម្ងន់ភស្តុតាងអ្វីសោះ។ នេះគឺជាចំណុចធម្មតាដែលខ្ញុំលើកឡើងអំពីឯកសារឆ្នាំ២០០៨នោះ។ មូលហេតុដែលឯកសារនេះមិនត្រូវបានដាក់បង្ហាញឲ្យបានមុននោះ គឺ> ដោយសារ<តែយើង>ពិនិត្យមើល<ឡើងវិញ>ឯកសារ<នេះ> ហើយ<យើងបានសម្រេចថា វា>មិនមានភាពជាប់ពាក់ព័ន្ធ<អ្វីធំដុំនោះ>ទេ។ <ក៏ប៉ុន្តែ នៅក្នុងដំណើរការដាក់បង្ហាញឯកសារទាំងអស់នេះ គឺវាស្ថិតនៅក្នុងបាច់ចម្រុះគ្នា។>

**ប្រធានអង្គជំនុំ៖**

ភាគីដទៃទៀតមានបញ្ហាអ្វីចង់បន្ថែមចុងក្រោយទេ? បាទ បើសិនជាមិនមានទេ គឺអង្គជំនុំជម្រះសុំ--

*(ចៅក្រមពិភាក្សាគ្នា)*

បាទ អរគុណចំពោះរាល់មតិយោបល់ដែលបានលើកឡើង ដែលពាក់ព័ន្ធនឹងបញ្ហានៃការស្នើសុំដាក់បង្ហាញនូវឯកសារពីសំណុំរឿង០០៤ មកធ្វើក្នុងសំណុំរឿង០០២/០២ របស់សហព្រះរាជអាជ្ញាដែលបានធ្វើសំណើដាក់មកអង្គជំនុំជម្រះកាលពីថ្ងៃទី២៤ ខែកក្កដា កន្លងទៅនេះ។ ហើយដើម្បីបានច្បាស់លាស់នេះគឺអង្គជំនុំជម្រះសុំប្រកាស សម្រាកត្រឹមនេះ រហូតដល់ម៉ោងដប់មួយខ្វះម្ភៃនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ម្យ៉ាងទៀតគឺ រយៈពេលវែងក្នុងការសម្រាកនេះដើម្បីអង្គជំនុំជម្រះពិភាក្សាសម្រេចលើបញ្ហានេះជាមុនសិន មុននឹងដំណើរការសវនាការទៅមុខទៀតនៅក្នុងថ្ងៃនេះ។

បាទ សម្រាកសិនចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:០៦ នាទី ដល់ម៉ោង ១១:០៤ នាទី)*

[១១:០៤:៣០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះ សូមជម្រាបជូនដល់ភាគី និងសាធារណជនឲ្យបានជ្រាបថា ដោយសារបញ្ហាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ កាលពីព្រឹកមិញនេះ ហើយនិងស្តាប់មតិយោបល់របស់ភាគី។ ពាក់ព័ន្ធនឹងបញ្ហានេះ ហើយអំឡុងពេលដែលអង្គជំនុំជម្រះសម្រាកប៉ុន្មាននាទីកន្លងមកនេះ អង្គជំនុំជម្រះមិនមានមូលដ្ឋានទាន់ លទ្ធភាពពេញលេញនៅក្នុងការធ្វើសេចក្តីឲ្យបានត្រឹមត្រូវទេ។ ដូច្នេះ អង្គជំនុំជម្រះត្រូវការពេលវេលាសមស្របសម្រាប់រៀបចំនូវសេចក្តីសម្រេចពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយ ដូច្នេះអង្គជំនុំជម្រះសម្រេចថា សវនាការនៅព្រឹកនេះ ផ្អាកត្រឹមនេះ ហើយសវនាការលើកបន្តធ្វើនៅរសៀលនេះ ដោយចាប់ផ្តើមពីម៉ោងមួយ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅរសៀលនេះឲ្យបានមុនម៉ោងមួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១១:០៥ នាទី ដល់ម៉ោង១៣:១០ នាទី)*

[១៣:១០:៤០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីតាមកាលវិភាគដែលបានគ្រោងទុក អង្គជំនុំជម្រះសម្រេចលើកាលវិភាគបន្ទាប់ពីមានការដាក់បង្ហាញឯកសារពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្មដូចខាងក្រោមនេះ។

នៅថ្ងៃនេះអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទក្នុងការធ្វើសវនាការលើអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម ហើយអង្គជំនុំជម្រះក៏បានកំណត់កាលបរិច្ឆេទនៃការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-220 នៅថ្ងៃនេះផងដែរ។ ប៉ុន្តែកាលពីថ្ងៃសុក្រ ទី២៤ ខែកក្កដា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញាអន្តរជាតិបានជូនដំណឹងអំពីការដាក់បង្ហាញឯកសារមួយចំនួនដែលពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ត្រពាំងថ្ម។ ក្រោយពីបានស្តាប់សារណារផ្ទាល់មាត់របស់ភាគីដែលបានធ្វើឡើងកាលពីព្រឹកមិញពាក់ព័ន្ធនឹងផលប៉ះពាល់ពីការដាក់បង្ហាញឯកសារទាំងនេះ អង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-220 នៅថ្ងៃនេះ ហើយបន្ទាប់មកនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-858។

ដើម្បីរក្សានូវការអនុវត្តពីមុនរបស់អង្គជំនុំជម្រះ ឯកសារសម្ភារៈទាំងឡាយដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញាអន្តរជាតិ មិនទាន់ត្រូវបានទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង០០២នៅឡើយទេ ដែលតម្រូវឲ្យភាគីដែលស្នើសុំដាក់សំណើដើម្បីបំពេញទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន៨៧ នៃវិធានផ្ទៃក្នុង។ សំណើសុំនេះមិនទាន់ត្រូវបានដាក់នៅឡើយទេ ហើយដំណាក់កាលនេះអង្គជំនុំជម្រះគ្រាន់តែធ្វើការកត់សម្គាល់អំពីការដាក់បង្ហាញឯកសារដែលភាគីអាចពិនិត្យមើលបានតែប៉ុណ្ណោះ។

[១៣:១២:៥៧]

ចំពោះផលប៉ះពាល់ដែលអាចកើតមានពីការដាក់ឯកសារទាំងនេះទៅលើកាលវិភាគសវនាការនោះដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-220 បានដំណើរមក អ.វ.ត.ក. ក្នុងរយៈចម្ងាយផ្លូវដ៏ឆ្ងាយ ដើម្បីមកផ្តល់សក្ខីកម្ម។ សាក្សី2-TCW-858 ក៏ត្រូវបាននាំមកដល់រាជធានីភ្នំពេញរួចហើយដែរ។ ការកំណត់កាលវិភាគសវនាការសម្រាប់ពួកគេឡើងវិញនឹងនាំឲ្យមានការលំបាកក្នុងការរៀបចំចាត់ចែង។ អង្គជំនុំជម្រះអាចនឹងកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីរូបនេះឡើងវិញនៅពេលណាមួយខាងមុខប្រសិនបើមានហេតុផលសមស្របបង្ហាញឲ្យឃើញថា ភាគីនានាទទួលរងព្យសនកម្មដោយការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-858 អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-866 ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ហើយបន្ទាប់អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-926 ពាក់ព័ន្ធនឹងអង្គហេតុការដ្ឋានទំនប់ ១មករា។ សាក្សីទាំងពីរនេះត្រូវបានសម្រេចជ្រើសរើសដោយអង្គជំនុំជម្រះ ប៉ុន្តែពុំទាន់មានឱកាសដើម្បីមកផ្តល់សក្ខីកម្មនៅ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ចំពោះមុខអង្គជំនុំជម្រះនៅឡើយ។ សក្ខីកម្មរបស់គេនឹងមិនប៉ះពាល់ដោយការដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះថ្មីៗនេះទេ។

[១៣:១៤:៤២]

សម្រាប់កាលវិភាគសវនាការនៅសប្តាហ៍ក្រោយ អង្គជំនុំជម្រះសម្រេចថា ភាគីត្រូវទទួលបានពេលវេលាសមស្របក្នុងការពិនិត្យមើលឯកសារដែលបានដាក់បង្ហាញមុននឹងបន្តសវនាការស្តាប់សក្ខីកម្មសាក្សីសម្រាប់អង្គហេតុការដ្ឋានទំនប់ត្រពាំងថ្មបន្តទៀត។

ដោយផ្អែកលើមូលដ្ឋាននេះ និងបន្ទាប់ពីពិចារណាទៅលើការដាក់បង្ហាញឯកសារ ដែលមានចំនួនដ៏ច្រើននៅដំណាក់កាលចុងក្រោយនេះ ហើយភាគីនានាមានភាពមមាញឹកក្នុងការសវនាការលើបណ្តឹងសាទុក្ខនៅដើមខែនេះផងនោះ អង្គជំនុំជម្រះនឹងកែសម្រួលកាលវិភាគសវនាការសម្រាប់សប្តាហ៍ក្រោយ ដោយពិចារណាផងដែរទៅលើអវត្តមានរបស់ចៅក្រមនៃអង្គជំនុំជម្រះចំនួនពីររូប បន្ទាប់ពីបញ្ចប់ស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-226 អង្គជំនុំជម្រះនឹងមិនធ្វើសវនាការនៅសប្តាហ៍ក្រោយនេះទេ។ នេះជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-CCP-220 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

បាទ អាចអញ្ជើញរួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ ដែលជួយដល់ អង្គុយក្បែរដើមបណ្តឹងរដ្ឋប្បវេណីក្នុងការស្តាប់ -- ផ្តល់សក្ខីកម្មនាពេលនេះផងដែរ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:១៧:២៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកដើមបណ្តឹងរដ្ឋប្បវេណី តើលោកឈ្មោះអ្វី?

**លោក សែន សុផុន៖**

**ឆ៖** ខ្ញុំបាទឈ្មោះ សែន សុផុន។

**ស៖** អរគុណកលោក សែន សុផុន។ តើលោកអាចប្រាប់អំពីថ្ងៃខែឆ្នាំកំណើតរបស់លោកបានដែរឬទេ តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ខ្ញុំបាទកើតថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៦០។

**ស៖** អរគុណ។ តើលោកមានទីកន្លែងកំណើតនៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទកើតនៅភូមិអូសទូក ឃុំកំពង់ព្រៀង ស្រុកសង្កែ ខេត្តបាត់ដំបង។

**ស៖** បាទ អគុណ។ ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំបាទរស់នៅភូមិផ្សារកណ្ដាល សង្កាត់ប៉ោយប៉ែត ស្រុកប៉ោយប៉ែត ខេត្តបន្ទាយមាន-ជ័យ។

**ស៖** បាទ អរគុណ។ តើលោកប្រកបមុខរបររកស៊ីអ្វីដែរសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំបាទធ្វើកម្មករ។

**ស៖** ឪពុករបស់លោកឈ្មោះអ្វី ហើយម្ដាយរបស់លោកគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ឪពុកខ្ញុំបាទឈ្មោះ សុខ យ៉ុន។ ម្ដាយខ្ញុំបាទឈ្មោះ សាញ់ សល់។

**ស៖** អរគុណលោក សុផុន ចុះប្រពន្ធរបស់លោកឈ្មោះអ្វី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធរបស់ខ្ញុំឈ្មោះ ឡុក ថាន។ ខ្ញុំមានកូនបួននាក់។

[១៣:១៩:៣២]

**ស៖** អរគុណលោក សែន សុផុន ហើយអង្គជំនុំជម្រះសូមជម្រាបថា នៅចុងក្រោយបង្អស់នៃការផ្ដល់សក្ខីកម្មរបស់លោក ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី លោកមានសិទ្ធិថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មដែលកើតមានចំពោះលោកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រសិនបើលោកមានបំណងធ្វើដូច្នេះ។ ហើយអង្គជំនុំជម្រះក៏សូមជម្រាបបញ្ជាក់ឡើងវិញថា ជម្រាបជូនភាគី និងសាធារណជនជ្រាបថា បុរសម្នាក់ដែលអង្គុយនៅជិតដើមបណ្ដឹងរដ្ឋប្បវេណីនោះ គឺឈ្មោះ សេង ហ៊ុនតាំង ដែលជាបុគ្គលិកនៃអង្គការ ធី.ភី.អូ ដែលអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់មានវត្តមាននៅអង្គុយក្បែរដើមបណ្ដឹងរដ្ឋប្បវេណីតាមសំណើសុំរបស់គាត់ ដែលគាត់គ្រាន់តែសម្រួលអារម្មណ៍ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើយ៉ាងណាឲ្យគាត់មានការស្ងប់អារម្មណ៍ ហើយនិងឆ្លើយតបទៅនឹងសំណួរផ្សេងៗពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះ។

ដោយអនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះមុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសូមបញ្ជាក់ថា សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី រួមទាំងសហ

ព្រះរាជអាជ្ញាមានរយៈពេលកន្លះថ្ងៃនៃថ្ងៃសវនាការក្នុងការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

សូមអញ្ជើញបាទ!

[១៣:២០:៥៨]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោក លោកស្រីចៅក្រម ភាគី ចំពោះដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន រហស្សនាម 2-TCCP-220 នេះមេធាវីនាំមុខសូមអនុញ្ញាតប្រគល់សិទ្ធិជូនលោកមេធាវី ហុង គឹមសួន ដើម្បីសាកសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញលោកមេធាវី ហុង គឹមសួន!

**លោក ហុង គឹមសួន៖**

ខ្ញុំបាទមេធាវី ហុង គឹមសួន សូមគោរពប្រធាន លោក លោកស្រីចៅក្រមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាទីគោរព។ ខ្ញុំសូមគោរពអង្គសវនាការ ព្រមទាំងប្រជាពលរដ្ឋទូទាំងក្នុងសាលសវនាការ និងទូទាំងប្រទេសដែលកំពុងតាមដានសវនាការនេះផងដែរបាទ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សួស្តីលោក សែន សុផុន! ខ្ញុំឈ្មោះ ហុង គឹមសួន ខ្ញុំសូមសាកសួរលោកទាក់ទងជាមួយនឹងដំណើរជីវិតរបស់លោកក្នុងចន្លោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មកដល់ថ្ងៃ០៦ មករា ឆ្នាំ១៩៧៩។ លោកអាចជម្រាបបានទេថា ជាខ្លីៗមុនថ្ងៃ១៧ មេសា ១៩៧៥ តើលោករស់នៅឯទីណា?

[១៣:២២:២៨]

**លោក សែន សុផុន៖**

**ឆ៖** មុនថ្ងៃ -- ១៩៧៥ ខ្ញុំរស់នៅក្រុងភ្នំពេញ នៅឡូត៍៣ សង្កាត់អូរឫស្សី។

**ស៖** សូមអរគុណ។ តើលោករស់នៅជាមួយនឹងអ្នកណាខ្លះ? ឧទាហរណ៍ជាក្រុមគ្រួសារ ឪពុកម្តាយ បងប្អូន ឬក៏រស់នៅម្នាក់ឯង?

**ឆ៖** ខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំ និងប្អូនខ្ញុំ។

**ស៖** តើនៅពេលនោះសមាជិកក្រុមគ្រួសាររបស់លោក ឪពុកម្តាយ បងប្អូនលោកមានសមាជិក

ប៉ុន្មាននាក់ដែរ?

**ឆ៖** សមាជិកខ្ញុំទាំងអស់មានប្រាំមួយនាក់។

**ស៖** សូមលោករៀបរាប់នរណាខ្លះបាទ?

[១៣:២៣:៣១]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប ក្បាលមីក្រូហ្វូនមិនទាន់ប្រតិបត្តិការទេ។

**លោក សែន សុផុន៖**

**ឆ៖** ឪពុកខ្ញុំពីរ ប្អូនខ្ញុំបី រូបខ្ញុំមួយទៀតបួន ទាំងអស់ប្រាំមួយនាក់បាទ។

**សួរដោយលោក ហុង គីមសួន៖**

**ស៖** សូមម្តងទៀត ឪពុកពីរយ៉ាងម៉េច? ឪពុក ឬម្តាយយ៉ាងម៉េច?

**ឆ៖** ឪពុកខ្ញុំនិងម្តាយខ្ញុំពីរនាក់ ប្អូនខ្ញុំបីនាក់ រូបខ្ញុំម្នាក់ទៀតបួននាក់បាទ។

**ស៖** បាទ សូមអរគុណ។ តើនៅថ្ងៃ១៧ ខែមេសា ១៩៧៥ ក្រុមគ្រួសាររបស់លោកមានឪពុកម្តាយ បងប្អូនរបស់លោកមានទៅរស់នៅទីកន្លែងណាផ្សេងពីទីលំនៅដែលលោករស់នៅដែរទេ?

**ឆ៖** សូមសួរម្តងទៀត ខ្ញុំចាប់អត់ទាន់។

**ស៖** បាទ សំណួរខ្ញុំសួរថា នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ តើក្រុមគ្រួសាររបស់លោកមានចាកចេញពីទីក្រុងភ្នំពេញទៅរស់នៅកន្លែងណាដែរឬទេ?

[១៣:២៥:០០]

**ឆ៖** ថ្ងៃ១៧ មេសា ៧៥ បានពួកខ្មែរក្រហមវាយចូលដល់ក្រុងភ្នំពេញ។ ខ្ញុំ និងឪពុកម្តាយខ្ញុំ និងប្អូនខ្ញុំក៏មានកងទ័ពខ្មែរក្រហមប្រាប់ឲ្យពួកខ្ញុំថា “នាំគ្នាចេញពីទីក្រុងភ្នំពេញឲ្យអស់ក្នុងរយៈពេលបីថ្ងៃ”។ ថ្ងៃនោះ ខ្ញុំក៏មិនទាន់បានចេញទេ ដល់ថ្ងៃទី១ ១៧ មេសា ៧៥, ៧៦ បានខ្ញុំចេញ។

**ស៖** សូមៗនិយាយម្តងទៀត។ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ លោកថា ខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ។ តើចាកចេញពីទីក្រុងភ្នំពេញទៅទីណាទេ? សំណួរខ្ញុំសួរអ៊ីចឹង។ តើចាកចេញនៅពេលណា?

**ឆ៖** ខ្ញុំបាទចាកចេញថ្ងៃទី១៦ មេសា។

**ស៖** សូមលោកបញ្ជាក់ឲ្យបានច្បាស់លាស់បន្តិចព្រោះលោកបានឆ្លើយសំណួរខ្ញុំទី១ ថា ថ្ងៃ១៧

ខែមេសា ឆ្នាំ ១៩៧៥ ត្រូវបានឃើញកងទ័ពខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ តែថ្ងៃនោះលោកថា មិនទាន់បានចេញទេ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើក្រោយថ្ងៃ១៧ ខែមេសា ១៩៧៥ តើក្រុមគ្រួសាររបស់លោកបានចាកចេញទៅរស់នៅកន្លែងណាទៀតដែរឬទេ?

**ឆ៖** ក្រុមគ្រួសាររបស់ខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញទៅរស់នៅខេត្តស្អាង ស្រុកស្អាង ភូមិព្រែកវាំង។

**ស៖** លោក មុននឹងឆ្លើយលោកសូមឱ្យច្បាស់សិន បើលោកអត់យល់ទេ សូមលោកសួរមកខ្ញុំណា។ ថាអត់យល់ទេ ដូចអម្បាញ់មិញនេះ។ ខ្ញុំចង់សួរតែបន្តិចទាក់ទងជាមួយនឹងដំណើរចេញពីទីក្រុងភ្នំពេញ អំមិញខ្ញុំសួរហើយសួរទៀត សួរថាដំណើរចាកចេញពីទីក្រុងភ្នំពេញនេះ តើពេលវេលា -- ការបញ្ជាក់របស់ខ្ញុំដោយសារលោកឆ្លើយទៅវាទាក់ទងជាមួយនឹងចម្លើយអំមិញថា ថ្ងៃ១៦ ខែមេសា។ ថ្ងៃ១៦ គឺវាមុនថ្ងៃ១៧។ អ៊ីចឹងខ្ញុំសួរឱ្យច្បាស់លាស់ម្ដងទៀតថា មុននឹងលោកចាកចេញពីទីក្រុងភ្នំពេញទៅនោះ តើលោកចាំបានទេ ថាថ្ងៃណាដែលចាកចេញពីទីក្រុងភ្នំពេញទៅបាទ?

[១៣:២៧:៥៤]

**ឆ៖** សូមទោសអំមិញ។ ថ្ងៃទី១៨ មេសា ខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញបាទ។

**ស៖** បាទសូមអរគុណ។ អំមិញលោកថាការចេញពីទីក្រុងភ្នំពេញទៅរស់នៅខាងស្រុកស្អាង ខេត្តកណ្ដាល។ លោកចាំបានទេ ថានៅឆ្នាំ នៅខែណា ឬឆ្នាំណាដែលលោកទៅដល់ស្រុកស្អាង ខេត្តកណ្ដាល?

**ឆ៖** ខ្ញុំទៅដល់ស្រុកស្អាង ខែ១មីនា អ៎! ខែឧសភា ច្រឡំ សូមទោស។

**ស៖** បាទ អ៊ីចឹងសូមជម្រាបលោកម្ដងទៀត សូមលោកពិចារណា ឬលោកស្ដាប់ឱ្យបានសំណួរខ្ញុំ។ ឥឡូវខ្ញុំសួរលោកបន្តទៀតចុះ នៅក្នុងឆ្នាំណា -- បាទ សូមលើកយកឯកសារពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់គាត់លេខ E3/4821 ជាភាសាខ្មែរ និងភាសាអង់គ្លេសដូចគ្នា។ ខ្ញុំសូមសួរទាក់ទងជាមួយនឹងការធ្វើចំណាក ការជម្លៀស ឬក៏ការផ្លាស់ទីលំនៅរបស់លោកនៅក្នុងឆ្នាំ១៩៧៦ តែម្ដង។ តើលោកនៅចាំបានទេ តើនៅក្នុងឆ្នាំ១៩៧៦ ក្រុមគ្រួសាររបស់លោកមានផ្លាស់ទីលំនៅទៅទីកន្លែងណាផ្សេងទៀតទេ?

**ឆ៖** បាទ បានផ្លាស់ពីភូមិព្រែកវាំង មករស់នៅខេត្តបាត់ដំបង។

**ស៖** បាទ សូមអរគុណ។ កន្លែងនេះសូមឱ្យលោកបញ្ជាក់ឱ្យបានច្បាស់បន្តិច តើការចាកចេញ

ពីភូមិព្រៃកវាំងនេះ ទៅបាត់ដំបងតើនរណាគេប្រាប់ឲ្យក្រុមគ្រួសាររបស់លោកចាកចេញទៅ?

**ឆ៖** បាទ មេភូមិបានប្រកាសប្រាប់ថា ឲ្យបងឯងចាកចេញពីនេះទៅ ទៅស្អាងព្រៃកតូចដើម្បីចាំបងប្អូនទាំងអស់ដែលគេទៅហ្នឹង គេឲ្យបងឯងវិលត្រឡប់ចូលទៅក្នុងទីក្រុងភ្នំពេញវិញ។

**ស៖** តើពេលហ្នឹងលោកមកតែម្នាក់ឯង ឬមកជាមួយនឹងក្រុមគ្រួសាររបស់លោក?

**ឆ៖** ខ្ញុំមកទាំងក្រុមគ្រួសារខ្ញុំទាំងអស់គ្នា ហើយអ្នកដែល ១៧ មេសា ទាំងអស់ក៏នាំគ្នាមកទាំងអស់គ្នាដែរ។

**ស៖** លោកអាចជម្រាបទៅដល់អង្គជំនុំជម្រះបានទេថា ការចាកចេញពីទីលំនៅចុងក្រោយនេះទៅខាងបាត់ដំបងនោះ តើទៅដល់ភូមិឃុំស្រុក ឬតំបន់ ឬភូមិភាគណាបានទេ?

**ឆ៖** មកដល់ខេត្តបាត់ដំបងនៅភូមិបត់ត្រង់ ស្រុកព្រះនេត្រព្រះ។

**ស៖** នៅតំបន់ប៉ុន្មាន? ឬក៏ភូមិភាគអីដែរ?

[១៣:៣១:៥៨]

**ឆ៖** តំបន់៥ បាទ។

**ស៖** ពេលនោះ លោកស្គាល់ឈ្មោះខេត្ត ឬក៏ភូមិភាគដែរទេ?

**ឆ៖** ខ្ញុំអត់ស្គាល់ទេ ខ្ញុំអត់ដឹងទេ មិនដឹងថា ស្រុកអីខេត្តអី ជិះឡានឆ្ងាយពេក។

**ស៖** អ៊ីចឹងខ្ញុំសូមសួររបៀបនៃការធ្វើដំណើររបស់លោកពីខាងព្រៃកវាំង មកខាងភូមិបត់ត្រង់ស្រុកព្រះនេត្រព្រះដែលលោកជម្រាបជូនអង្គសវនាការអម្បាញ់មិញ ថាតើការធ្វើដំណើរហ្នឹងមកដោយយ៉ាងម៉េចដែរ? ធ្វើដំណើរដើរ ឬក៏ជិះឡាន ជិះទូក កប៉ាល់ជាដើម?

**ឆ៖** បាទ ចេញពីភូមិព្រៃកវាំងមក នាំគ្នាលីកន្ទេល លីមុង ដើរកាត់វាលៗ ដីប្រហែលជា ៥ គីឡូដី បានមកដល់ស្រុកស្អាងព្រៃកតូច។

**ស៖** សូមបន្តទៀត សូមនិយាយរឿងរ៉ាវហ្នឹងបន្តទៀត។

**ឆ៖** មកដល់ ស្អាងព្រៃកតូចមានឡានប្រហែលជា ២០គ្រឿង នៅខាងមុខ ហើយក៏ហៅប្រជាពលរដ្ឋដែលមកទាំងអស់គ្នាមិនថា ខាងខ្ញុំ ឬខាងណាទេ ឲ្យឡើងឡានទាំងអស់គ្នា។ ឡើងឡានទាំងអស់បានពេញឡាន ហើយក៏គាត់បើកឡានហ្នឹងចាកចេញមក។ គាត់មករត់កាត់ភ្នំពេញ រត់កាត់ភ្នំពេញ ហើយបងប្អូនទាំងអស់គ្នាឆ្ងល់ "ហ៊ឺះ! គេយកយើងមកទីក្រុងភ្នំពេញ ហេតុម៉េចគេយកយើងទៅហួសភ្នំពេញអ៊ីចឹង?" ក៏នាំគ្នាឆ្ងល់ ចេះតែអ៊ូអរនៅក្នុងឡាន ថាឆ្ងល់ "គេកុហកយើងហើយ គេកុហកយើង

ទៀតហើយ"។ ស្រាប់តែឡានហួសចេញទៅ ឡានហួសចេញទៅផុតដល់ព្រែកក្តៅ។ ឡានខ្ញុំពីរដំបូង រត់ទៅ រត់មុនគេ រត់ដល់ព្រែកក្តៅក៏ឈប់ចាំឡានក្រោយ។ ឈប់ចាំប្រហែលជាពីរម៉ោង បានឃើញ ឡានក្រោយទាំង ១៨ឡាន ហ្នឹងទៅតាម ហើយឡើងថ្ងៃឡើងជ្រេ។ បានគេសួរថា "ហេតុម៉េចបានឡាន ហ្នឹងយូរម្ល៉េះ?" ថា "ហ៊ឺ! ឡានហ្នឹងរត់វាងក្រុងមិនឲ្យចូលក្រុងទេ ព្រោះទីក្រុងវាពិបាកមើលពេក" ព្រោះអីឡានខ្ញុំចូលទៅ ខ្ញុំឃើញទិដ្ឋភាពហ្នឹងមែន គឺថាអត់មានមនុស្សទេនៅក្នុងទីក្រុងភ្នំពេញ ឃើញ តែសំរាមពាសពេញនៅទីក្រុងទាំងអស់។ ហើយកងទ័ពយោធាដើរមួយៗ តាមទីក្រុងហ្នឹង។

**ស៖** សូមលោកនិយាយពីដំណើរលោកទៅដល់ក្រុងបាត់ដំបង តើវាមានផ្លាស់ការដឹកជញ្ជូន ឬក៏ទៅរហូតយ៉ាងម៉េចដែរបាទ?

[១៣:៣៥:០០]

**ឆ៖** ទៅដល់ក្រុងបាត់ដំបង ទៅឈប់នៅរ៉ាបាត់ដំបង ហើយឲ្យប្រជាពលរដ្ឋហ្នឹងឡើងជិះរទេះភ្លើង គេថាផ្លូវ -- ខាងទៅសិរីសោភ័ណទៅមិនបានទេ ផ្លូវនោះវាដាច់ស្ពានដាច់អស់ ក៏ឲ្យឡើងជិះរទេះភ្លើងទៅ។ ជិះរទេះភ្លើងទៅដល់សិរីសោភ័ណ ស្រាប់តែដល់សិរីសោភ័ណមាន ទៅដល់នោះចុះនាំគ្នាចុះអស់ គេក៏ឲ្យឃើញអាត្រាក់ទ័រប្រហែលជា១០គ្រឿងយកមកចាំទទួលអ្នកដែលដំណើរនោះ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរថយក្រោយបន្តិច ពេលដែលឡើងឡានចេញពីព្រែករាំងកាត់មកទីក្រុងភ្នំពេញរហូតដំណើរទៅដល់បាត់ដំបងនេះ តើមុននឹងឡើងឡានហ្នឹង គេខាងអង្គការ ឬក៏ខាងអ្នករៀបចំឲ្យធ្វើដំណើរហ្នឹង គេមានឲ្យយើងយកបាយ ឬក៏យកអង្ករចានឆ្នាំង ឬក៏គេចែកជាម្ហូបអាហារទៅតាមផ្លូវ តាមដំណើរហ្នឹងឲ្យយើងដែរទេ?

**ឆ៖** ខាងខ្ញុំ គេអត់មានចែកផង គេអត់មានចែកទេ អង្ករយកមកពីភូមិនោះមកបានប៉ុន្មាន ទៅប៉ុណ្ណឹងឯង។

**ស៖** បាទ សូមអរគុណ។ ចុះដំណើរតាមផ្លូវ ឡានមានឈប់ឲ្យខាងប្រជាពលរដ្ឋដែលធ្វើដំណើរហ្នឹងឈប់តាមផ្លូវបត់ជើងតូច បត់ជើងធំ ឬក៏ដាំបាយទឹកអីហូបដែរទេ?

**ឆ៖** បាទ ឡានឈប់ម្តង មកដល់ហួសកំពង់ឆ្នាំងមក ឈប់ម្តងហ្នឹងហើយទៅរហូតទាល់តែដល់បាត់ដំបងបាទ។

**ស៖** ដំណើរពីព្រែករាំងទៅដល់បាត់ដំបង ពីបាត់ដំបងទៅសិរីសោភ័ណ ហើយតពីសិរីសោភ័ណទៅដល់ភូមិរបស់លោកដែលលោកជម្រាបជូនអំមិញ ថាភូមិបត់ត្រង់ ស្រុកព្រះនេត្រព្រះ តំបន់៥។ តើ

ប្រាប់រយៈពេលប៉ុន្មានថ្ងៃ ប៉ុន្មានយប់បានទៅដល់ទីលំក្រោយៗគេនេះបាទ?

**ឆ៖** ប្រើពេលអស់មួយយប់ ពីរថ្ងៃបាទ។

**ស៖** បាទ តើក្រុមគ្រួសាររបស់លោករស់នៅភូមិបត់ត្រង់រហូត ឬយ៉ាងម៉េចបាទ?

**ឆ៖** គ្រួសាររបស់ខ្ញុំរស់នៅភូមិបត់ត្រង់រហូតមកបាទ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងឆ្នាំ១៩៧៦ដដែល ចំពោះរូបលោកផ្ទាល់រស់នៅក្នុងភូមិបត់ត្រង់ ស្រុកព្រះនេត្រព្រះដដែល ឬមានត្រូវចូលជាកងកុមារ កងយុវជន ឬកងមនុស្សចាស់ទៅធ្វើការកន្លែងផ្សេងដែរឬទេ?

[១៣:៣៨:២០]

**ឆ៖** ខ្ញុំទៅដល់មេប្រធានសហករណ៍គាត់ៗមិនទាន់ឡើងប្រធានសហករណ៍ទេ គាត់ជាមេភូមិ គាត់ប្រាប់ថាឲ្យខ្ញុំនេះទៅតាមអ្នកវ័យកណ្ដាល ទៅភ្ជួរស្រែ។

**ស៖** លោកជម្រាបបានទេ នៅក្នុងកងរបស់លោកៗជាៗ -- គេចាត់ទុកជាកងយុវជន ឬក៏កងមនុស្សចាស់?

**ឆ៖** កងមនុស្សចាស់ គេហៅវ័យកណ្ដាលៗ។

**ស៖** អ៊ីចឹងការងាររបស់លោកដែលទៅជាមួយកងមនុស្សចាស់ហ្នឹងធ្វើការងារភ្ជួរស្រែ ចម្ការដល់ឆ្នាំណា ឬក៏ដល់ពេលណាដែរ?

**ឆ៖** ភ្ជួរមួយឆ្នាំ ភ្ជួរដីដាំដំឡូង ភ្ជួរដាំដំឡូងចប់ ពេលដាំដំឡូង ខែប្រាំងឲ្យចុះទៅដាស់ដីដាំស្រូវ។

**ស៖** សូមសួរលោកអំពីរបបអាហារហូបចុកនៅក្នុងរដូវ -- នៅក្នុងពេលដែលលោកនៅកងជាមួយមនុស្សចាស់ភ្ជួរស្រែ ឬក៏ភ្ជួរចម្ការនោះ តើរបបសម្រាប់កងរបស់លោកហូបយ៉ាងម៉េចដែរ?

**ឆ៖** ការហូបចុកអត់គ្រប់គ្រាន់ទេ គ្នា ១៥នាក់បានអង្ករតែពីរកំប៉ុងទេដាំហូបបបរ។

**ស៖** ការកំណត់ធ្វើការងារនៃកងរបស់លោកធ្វើការពេលហ្នឹង តើគេឲ្យធ្វើការចែកពេលម៉ោងយ៉ាងម៉េចដែរ យើងចាំម៉ោងបានទេថា ព្រឹក ឬក៏ព្រលឹម ឬថ្ងៃត្រង់ ឬល្ងាច ឬព្រលប់អី អាចជម្រាបជូនអង្គសវនាការបានទេ?

**ឆ៖** ខ្ញុំគេឲ្យក្រោកពីម៉ោងពីរ ទាំងអស់គ្នាក្រោកពីម៉ោងពីរយកគោទៅលែងឲ្យស៊ីស្មៅ។ ពេលនោះស្រាងៗគ្រាន់តែមើលស្រមោលឃើញ ឲ្យចាប់ទឹមគោភ្ជួរ ដល់ថ្ងៃឡើងម៉ោងដប់មួយកន្លះទើបឲ្យឈប់ហូបបបរ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកធ្វើស្រែ ឬក៏ភ្ជួរស្រែចម្ការជាមួយកងមនុស្សចាស់ តើលោកមានដែលឃើញការចាប់ខ្លួនសមាជិកក្នុងកងរបស់លោក ឬក៏មានការបាត់ខ្លួនក្នុងកងរបស់លោកដែរឬទេ?

**ឆ៖** អត់មានឃើញទេ។

[១៣:៤១:២២]

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរលោកបន្ត ចូលមកដល់ឆ្នាំ១៩៧៧។ នៅពេល នៅក្នុងឆ្នាំ១៩៧៧ ក្នុងឯកសាររបស់លោក ក្នុង E3/4821ដដែល ទាក់ទងជាមួយការទៅធ្វើការងារជាកងចល័ត។ លោកអាចជម្រាបជូនអង្គសវនាការបានទេថា តើពេលនោះការទៅធ្វើការងារជាកងចល័តនោះនៅឯណា ឬក៏ស្រុកអី តំបន់អី ជាដើម អាចជម្រាបជូនបានទេ?

**ឆ៖** លោកប្រធានសហករណ៍ក៏ឲ្យខ្ញុំហ្នឹងនាំគ្នាយកចេញ ហៅគ្នាមកពីភ្ជួរអ្នកដែលក្មេងជំទង់ៗ ហៅមកពីកន្លែងភ្ជួរទាំងអស់ ដើម្បីរៀបក្រុមឡើងទៅជួយលើកអាងត្រពាំងថ្ម។

**ស៖** លោកនៅនឹកឃើញបានទេថា ការបញ្ជូនកងរបស់លោកក្រោយនេះទៅលើកទំនប់អាងត្រពាំងថ្មហ្នឹងនៅក្នុងខែណា? ឆ្នាំណា?

**ឆ៖** ឆ្នាំ១៩៧៧។

**ស៖** លោកចាំបានទេថា ទំនប់ត្រពាំងថ្មហ្នឹងស្ថិតនៅក្នុងស្រុកអី ឬក៏តំបន់អី?

**ឆ៖** ស្រុកភ្នំស្រុក តំបន់៥។

**ឆ៖** បាទ សូមអរគុណ។ ការងាររបស់លោកនៅក្នុងការលើកទំនប់អាងត្រពាំងថ្មនោះ តើគេឲ្យលោកធ្វើយ៉ាងម៉េចខ្លះ ការងារផ្ទាល់ខ្លួនរបស់លោក?

**ឆ៖** ឲ្យលើកក្នុងម្នាក់ ៣ម៉ែត្រគូប។

**ស៖** តើពេលវេលាធ្វើការងារនៅក្នុងការលើកទំនប់អាងត្រពាំងថ្មហ្នឹង តើលោក គេកំណត់ឲ្យធ្វើការយ៉ាងម៉េចដែរ ពេលព្រឹក ឬក៏ពេលថ្ងៃយ៉ាងម៉េចដែរ? ពីចន្លោះម៉ោងណាទៅម៉ោងណាជាដើម?

**ឆ៖** ព្រឹកម៉ោងបួន មេកងគោះរគាំងម៉ឺងៗ ដើម្បីឲ្យចេញរៀបចំទៅលើកដី។ ថ្ងៃត្រង់ម៉ោងដប់មួយកន្លះ ទើបឲ្យសម្រាកហូបបបរ។

**ស៖** ចុះពេលរសៀលលោកធ្វើការរហូតដល់ពេលណាទើបបានសម្រាក?

**ឆ៖** ពេលរសៀល ម៉ោងមួយចុះធ្វើ ធ្វើរហូតទាល់តែយប់ដល់ម៉ោងប្រាំបួន ម៉ោងដប់ ព្រោះថា

៣ម៉ែត្រគូបធ្វើមិនហើយទេ ធ្វើអត់ហើយគេអត់ឲ្យឈប់។

[១៣:៤៤:៥៤]

**ស៖** បាទ សូមអរគុណ។ លោកនៅចាំបានទេ នៅក្នុងពេលដែលលោកលើកទំនប់ត្រពាំងថ្ម ហ្នឹង វានៅចំណុចណានៃៗទំនប់ត្រពាំងថ្ម។ មានន័យថា បណ្ដោយទំនប់អ៊ីចឹងយើងនៅដើមទំនប់ ឬ កណ្ដាលទំនប់ ឬក៏ចុងទំនប់ជាដើម?

**ឆ៖** ខ្ញុំនៅចំណុចស្ពានរាប។

**ស៖** បាទ សូមអរគុណ។ សុំសួរលោកបន្តិចថា អំមិញលោកនិយាយអំពីការលើកទំនប់មួយថ្ងៃ គេឲ្យលោក ៣ម៉ែត្រគូប។ ជាទូទៅស្មើគ្នា ឬមួយអ្នកលើកតិចជាង ឬក៏ច្រើនជាងដែរ?

**ឆ៖** មានៗអ្នកខ្លះ ៣,៥ម៉ែត្រគូប អ្នកខ្លះ៤ម៉ែត្រគូប តាមតែគេនេះ។ ប៉ុន្តែក្រុមខាង មានតែ ក្រុមស្រួចទេដែលគេលើក៤ម៉ែត្រគូប តែពួកខ្ញុំលើកតែ៣ម៉ែត្រគូបប៉ុណ្ណោះ។

**ស៖** លោកអាចជម្រាបជូនបានទេ ម៉េចបានគេឲ្យលោកលើកទំនប់ ៣ម៉ែត្រគូប?

**ឆ៖** ព្រោះគេថាពួកខ្ញុំនេះកម្លាំងសមរភូមិក្រោយនៅឡើយ។

**ស៖** បាទ សូមអរគុណ។ អម្បាញ់មិញលោកថាចំណុចដែលលោកឈរជើងនៅទំនប់ត្រពាំងថ្ម គឺចំណុចស្ពានរាប។ តើលោកអាចជម្រាបជូនលម្អិតជាងហ្នឹងបានទេថា កន្លែងៗជីកដីដើម្បីរែកយកទៅ ចាក់ទំនប់ហ្នឹង គេលើកនៅជើងទំនប់ ឬក៏ឆ្ងាយពីទំនប់?

**ឆ៖** ឆ្ងាយពីទំនប់ប្រហែលជា ១៥ម៉ែត្រ។

**ស៖** បាទ សូមអរគុណ។ លោកមាននឹកឃើញទេថា តើកម្ពស់ទំនប់ហ្នឹងវាអាចជាកម្ពស់ ប្រហែលប៉ុន្មាន ឬក៏ខ្នងទំនប់ប្រវែងប៉ុន្មានជាដើម បាតទំបន់ជាដើម? អាចនៅចាំទេ កន្លែងហ្នឹង?

[១៣:៤៧:៣៥]

**ឆ៖** ទំនប់វាអត់ស្មើគ្នាទេ។ បើកន្លែងខ្ញុំនៅធ្វើហ្នឹង កន្លែងខ្ញុំហ្នឹងខ្នងលើ ៣០ម៉ែត្រ កម្ពស់ ១៥ ម៉ែត្រ បាតក្រោម ៥០ម៉ែត្រ។

**ស៖** តើចំណុចដែលលោកឈរជើងលើទំនប់ហ្នឹងកន្លែងៗដែលលោកថាមិនស្មើ តែខ្ញុំចង់ និយាយតែកន្លែងរបស់លោកទេ។ មានកងចល័តប្រុសស្រីច្រើនដែរទេ?

**ឆ៖** ច្រើនមិនថាកន្លែងខ្ញុំ កន្លែងណាទេ ហូរហែទៅម៉េចទាំងអស់ ឲ្យតែជើងទំនប់ទៅ ហូរហែ ទាំងអស់តែម្ដង។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរអំពីទីកន្លែងស្នាក់នៅ ឬក៏កន្លែងដេក។ តើកន្លែងដេកហ្នឹងគេមានរៀបចំជាផ្ទះសម្បែង ឬក៏មានទីជម្រកស្រួលបួលឲ្យកងចល័តរបស់លោកនៅដែរទេ?

**ឆ៖** ធ្វើរោងៗវែងទៅ នៅតាមក្រុមនៅចូលក្នុងរោងនោះឯង។ រោងនោះទាប ខិនក្បាលល្មមខិនបាន ហើយក្រោមអត់មានអីទេ យើងមានអីយើងក្រាលខ្លួនឯងដេកទៅ។

**ស៖** លោកនៅលើទំនប់ត្រពាំងថ្មហ្នឹង អស់រយៈពេលប្រហែលជាប៉ុន្មានថ្ងៃ ប៉ុន្មានខែ?

**ឆ៖** ខ្ញុំលើកហ្នឹងបានប្រហែលជាពីរខែប៉ុណ្ណោះ ព្រោះអីខ្ញុំមកក្រោយគេ ខ្ញុំលើកហើយគេថាដកក្រុមខ្ញុំចេញពីត្រពាំងថ្មឲ្យទៅបុកទំនប់ស្ពានស្រែងវិញ។

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមសួរកន្លែងហ្នឹងឲ្យៗបានច្រើនបន្តិច ព្រោះទាក់ទងជាមួយទំនប់ត្រពាំងថ្ម។ ក្រៅពីកន្លែងដេក តើចំពោះមានជំងឺឈឺថ្កាត់ជាដើម ពេលហ្នឹងតើមានពេទ្យជួយព្យាបាលឬក៏គេដើរចែកថ្នាំពេទ្យដែរទេ?

**ឆ៖** អត់មានថ្នាំពេទ្យ ថ្នាំអីទេ ឈឺដេកនៅក្នុងរោងនោះឯង ដេក សូម្បីតែបាយ ក៏អត់ចែកឲ្យហូបផង។

[១៣:៥០:១១]

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងនៅក្នុងអំឡុងពេលដែលថា ស្នាក់នៅធ្វើការនៅទំនប់ត្រពាំងថ្មដែលមានការចាប់ខ្លួនមនុស្សនៅក្នុងកងចល័ត ឬការយកមនុស្សទៅធ្វើទារុណកម្មជាដើម លោកដែលឃើញ ដែលដឹងដែរទេ?

**ឆ៖** ខ្ញុំអត់ឃើញ តែចេះតែបាត់មនុស្ស ក្រុមខ្ញុំយូរៗបាត់មួយៗ។

**ស៖** បាទ សូមអរគុណ។ ចុះចំពោះផ្នែកសម្លៀកបំពាក់ ទឹកសម្រាប់ងូត សម្រាប់ផឹកជាដើមខាងមេកងចល័តរបស់លោក គេបានចែកឲ្យគ្រប់គ្រាន់ដែរទេ?

**ឆ៖** ទឹកក៏ហូបអត់គ្រប់គ្រាន់ដែរ យកធុងសាំងពីរដាក់លើរទេះទៅដឹកទឹកពីបឹងយកមកឲ្យហូប។

**ស៖** លោកនៅចាំឈ្មោះមេកង មេកើយធំតូចរបស់លោកដែរឬទេនៅហ្នឹងទំនប់ត្រពាំងថ្មហ្នឹង?

**ឆ៖** ខ្ញុំនៅចាំបាន គាត់ឈ្មោះ តាវ៉ាល់។

**ស៖** តាវ៉ាល់ ហ្នឹងគាត់គ្រប់គ្រងកងរបស់លោកមួយកងហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់គ្រប់គ្រងមួយតំបន់៥ ហ្នឹង គេហៅ មេតាវ៉ាល់ មេធំៗ។

**ស៖** បាទ សូមអរគុណ។ នៅក្នុងអំឡុងពេលលោកកំពុងលើកទំនប់ត្រពាំងថ្មហ្នឹង តើដែលឃើញមានគណៈប្រតិភូក្នុងសម័យលោកលើកទំនប់ហ្នឹង គេទៅជាក្បួន ឬក៏ទៅជារបៀបជាអ្នកធំៗមានទៅទស្សនកិច្ច ដែលឃើញដែរទេ?

**ឆ៖** ខ្ញុំអត់ឃើញ អត់ឃើញទៅ។

[១៣:៥២:៤៩]

**ស៖** បាទ សូមអរគុណ។ អំមិញលោកបានជម្រាបថា លោកនៅក្នុងកងចល័តលើកទំនប់ត្រពាំងថ្មបានជាងពីរខែត្រូវដកចេញឲ្យទៅលើទំនប់ស្ពានស្រែង។ តើទំនប់ស្ពានស្រែង និងទំនប់ត្រពាំងថ្មហ្នឹង វានៅជិតគ្នា ឬចម្ងាយគ្នាប៉ុន្មានដែរ?

**ឆ៖** មិនឆ្ងាយពីគ្នាទេ វាតជិត ចង់តជាប់គ្នាទៅតែម្ដង។

**ស៖** សំណួរខ្ញុំ ខ្ញុំសូមសួរលោកទាក់ទងជាមួយនឹងការធ្វើការងារ លោកបានជម្រាបរួចហើយការហូបចុករួចហើយ តើអំពីការឈប់សម្រាកទាំងទំនប់ត្រពាំងថ្ម ឬក៏មកលើកទំនប់ស្ពានស្រែងជាដើមខាងមេកង ឬក៏មេធំនៅមុខសញ្ញាលើកទំនប់ហ្នឹង គេដែលឲ្យយើងឈប់សម្រាកទេ ក្នុងមួយខែប៉ុន្មានថ្ងៃ ឬមួយអាទិត្យប៉ុន្មានថ្ងៃជាដើម មានឲ្យឈប់បុណ្យទានអីទេ?

**ឆ៖** អត់មានឲ្យសម្រាក អត់មានពេលសម្រាកទេ គឺថាមានតែពេលធ្វើរហូត។ បុណ្យទាន ក៏គ្មានដឹងថាបុណ្យ ដឹងថា គេអត់មានបុណ្យទានទេ។

**ស៖** នៅក្នុងពេលធ្វើការនៅទំនប់ទាំងពីរនេះ តើលោកមានដែលមានឱកាសសុំច្បាប់គេមកលេងផ្ទះ ឬក៏មកជួបជុំឪពុកម្ដាយពេលណាដែរទេ?

**ឆ៖** ខ្ញុំសុំគេដែរ ប៉ុន្តែគេអត់ឲ្យមក។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសួរទាក់ទងជាមួយនឹងសម្លៀកបំពាក់ តើនៅក្នុងពេលលើកទំនប់ហ្នឹង គេមានដែលចែកជាសម្លៀកបំពាក់ ឬស្បែកជើង ឬក្រមាជាដើមឲ្យលោកដែរទេ?

**ឆ៖** បើនិយាយឲ្យចំទៅ ខ្ញុំចូលចល័តស្រុកនេះ គេបើកឲ្យតែមួយកំប្លេគត់តែប៉ុណ្ណោះ ក្រមាមួយ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំសូមសួរបន្តទៅទៀត នៅក្នុងឆ្នាំ១៩៧៨ នៅក្នុងឯកសារ E3/4821 ដដែល។ លោកនៅចាំបានទេថា ចេញពីការលើកទំនប់ត្រពាំងថ្ម ឬទំនប់ស្ពានស្រែង លោកមានបានទៅលើកទំនប់នៅឯណាទៀតដែរទេ?

**ឆ៖** អង្គាល់នោះ ខ្ញុំគេឲ្យចុះទៅជីកប្រឡាយទៀត ជីកប្រឡាយភ្នំលៀប គេហៅ "ប្រឡាយភ្នំលៀបៗ"។

[១៣:៥៦:២៨]

**សៈ** តើនៅប្រឡាយភ្នំលៀបហ្នឹងជាប្រឡាយ ឬជាទំនប់ដែរបាទ?

**ឆ៖** ជាប្រឡាយបាទ ជាប្រឡាយ។

**សៈ** បាទ អរគុណ។ របៀបនៃការធ្វើការងារនៅប្រឡាយភ្នំលៀប តើវាមានភាពខុសគ្នាពីការលើកទំនប់ត្រពាំងថ្មយ៉ាងម៉េចដែរ?

**ឆ៖** អត់ខុសគ្នាទេ របៀបរបបដែលលើកប្រឡាយ ដូចគ្នា៣ម៉ែត្រគូបដូចគ្នា បើលើកអត់ហើយអត់ឲ្យបាយហូបទេ។ ពួកខ្ញុំលើកមិនដែលហើយទេ ជួនកាលម៉ោងដប់ទើបបានបាយហូប ហើយមិនមានបាយទេហូបតែបបរមួយវែកៗប៉ុណ្ណោះ។

**សៈ** សុំសួរលោកបន្តិច ប្រឡាយទំនប់ពីត្រពាំងថ្មមកប្រឡាយភ្នំលៀបហ្នឹងចម្ងាយពីគ្នាប៉ុនណាដែរ?

**ឆ៖** ឆ្ងាយ ខ្ញុំចាំមិនបានទេ ឆ្ងាយណាស់ ដីមិនដឹងប៉ុន្មានគីឡូទេ ឆ្ងាយខ្លាំងពេក ខាងត្រពាំងថ្មមកភ្នំលៀបនេះ ខ្ញុំមិនអាចរាប់បាន។

**សៈ** បាទ សូមអរគុណ។ លោកអាចជម្រាបជូនលោកប្រធាន និងលោកចៅក្រមបានទេ អំពីមានអ្វីកើតឡើងចំពោះលោកនៅពេលដែលលោកលើកទំនប់អាង -- សូមទោស លើកទំនប់ភ្នំលៀបនេះបាទ លើកប្រឡាយទំនប់ភ្នំលៀបនេះ?

**ឆ៖** លើកប្រឡាយភ្នំលៀបនេះ ខ្ញុំលើកបានប្រហែលជាកន្លះខែ។ បានជាងកន្លះខែស្រាប់តែមានមនុស្សស្រីម្នាក់ ខ្ញុំទៅបើកបាយយប់ម៉ោងដប់ហើយ ខ្ញុំទៅបើកបាយ ស្រាប់តែគាត់ថា គាត់មកប្រាប់ខ្ញុំភ្លាម គាត់ថា "ពូផុន ពូឯងហ្នឹងណា ពូឯងគេយកទៅសម្លាប់ចោលហើយ" ខ្ញុំភ័យណាស់--

*(ដើមបណ្ដឹងរដ្ឋប្បវេណីយំ)*

[១៣:៥៩:៤១]

**សៈ** លោក សុផុន សូមលោកសម្រួលអារម្មណ៍បន្តិច ខ្ញុំសួរលោកបន្តិចទៀតទេ ព្រោះលោកប្រធានបានជម្រាបហើយ លោកនឹងមានពេលវេលាសម្រាប់ធ្វើការនិយាយថ្លែងទុក្ខសោករបស់លោកចុងក្រោយ។ នៅពេលដែលមានគេប្រាប់លោកអំពីគេប្រុងយកលោកទៅសម្លាប់នុ៎ង តើលោកធ្វើអ្វី? ឬក៏

លោកទៅណាទៀតដែរ?

**ឆ៖** ស្រីអែមហ្នឹងបានប្រាប់ខ្ញុំថា "ពូផុនអើយ" គេលួចប្រាប់តិចៗថា "ពូផុន គេយកពួងឯងទៅវាយចោល គេឲ្យមេកងប្រាប់ឈ្លបហើយៗ ពួងឯងរត់ចេញទៅ"។ ខ្ញុំក៏ គាត់គ្រាន់តែប្រាប់ខ្ញុំភ្លាម ខ្ញុំបានតែបាយយកតែបន្ទបាយ ខ្ញុំរត់គេចទាំងយប់ហ្នឹងឯង គេចសំដៅទៅមកលើ មកខាងលើ អត់មានទាន់ដឹងថាទៅណាទៅរួចទេ ធ្វើយ៉ាងម៉េចឲ្យតែផុតកន្លែងហ្នឹងសិន។

**ស៖** តើការ ពាក្យថា "គេចចេញឲ្យផុត" ហ្នឹង លោករត់គេចពីកងចល័តហ្នឹង ឬមួយក៏លោកមានបំណងទៅឯណាទៀត?

**ឆ៖** ខ្ញុំគិតថារត់ចេញឲ្យផុតពីកងចល័តហ្នឹង ខ្លាចគេយកទៅសម្លាប់ប៉ុណ្ណោះឯង ប៉ុន្តែបំណងអត់មានទៅឯណាទេ មិនដឹងថាទៅជ្រកកោននៅឯណា អត់ដឹងនៅឯណាទាំងអស់។ ខ្ញុំចេះតែដើរទៅធ្វើម៉េចឲ្យតែឆ្ងាយពីកន្លែងកងចល័តហ្នឹង។

**ស៖** លោកដើរទៅរកភូមិ ឃុំគេទៀត ឬក៏លោកទៅដល់កន្លែងណាចុងក្រោយនៃការទៅដល់ទីតាំងដែលលោកឈប់នោះ?

[១៤:០១:៣៨]

**ឆ៖** ខ្ញុំដើរខាងជើងភ្នំលៀប ដើររហូត ទៅខាងលិចហ្នឹងទៅៗៗចេះតែដើរទៅ ដើររហូតទៅដល់ៗព្រៃមាន់ ហ្នឹងដើរទាំងយប់ ដើរទៅដល់ព្រៃ យប់អត់ទាន់ដល់ព្រៃមាន់ទេ ស្រាប់តែខ្ញុំអស់កម្លាំងខ្ញុំក៏ដេកកណ្ដាលវាលហ្នឹងឯង។

**ស៖** ដំណើរលោកក្នុងពេលលោកគេចខ្លួនហ្នឹងទៅដល់ភូមិ ឃុំ ស្រុក ណាដែរ?

**ឆ៖** ខ្ញុំដើរទៅដល់ភូមិជ្រាប់។

**ស៖** បាទ អរគុណ។ ពីទំនប់ ពីប្រឡាយភ្នំលៀបទៅដល់ភូមិៗជ្រាប់លោកធ្វើដំណើរប៉ុន្មានថ្ងៃហើយបានអាហារឯណាហូប?

**ឆ៖** បើគិតទៅខ្ញុំៗដើរជាងមួយអាទិត្យ អត់មានបាយហូប។ ខ្ញុំទៅដល់ព្រៃមាន់ហ្នឹង ឃើញចម្ការដំឡូងគេ អាគល់ដំឡូងខ្លីៗដែលគេកាច់សល់នោះ ខ្ញុំក៏កាច់ៗៗៗបានច្រើនបាន ខ្ញុំដាក់នៅក្នុងកន្សែងយកមកដាក់ក្នុងកាមែល ឃើញត្រោកកណ្ដៀរគេៗអណ្ដូងនៅកៀន ខ្ញុំក៏ដាក់អាកាច់ អាគល់ដំឡូងហ្នឹងឯង អាកាច់ដែលកាច់បាក់នៅសល់ចុងបន្តិចៗហ្នឹង យកទៅខ្ញុំដាក់ដាំហ្នឹង ដាក់ដាំបានពីរបីកាមែល ទុកខ្ញុំថាទុកធ្វើដំណើរទៅទៀត ចេះតែដើរទៅអត់ទាន់ដឹងថាទៅណាទេ តែខ្ញុំដើរទៅៗដល់ភូមិជប់។

[១៤:០៣:៣២]

**ស៖** បាទសូមអរគុណ។ អំមិញលោកថាធ្វើដំណើរទៅដល់ភូមិជ្រាប់ តើលោកស្នាក់នៅនឹងភូមិជ្រាប់ ឬក៏លោកបន្តទៅណាទៀត?

**ឆ៖** និយាយពីទៅដល់ភូមិជ្រាប់ហ្នឹងខ្ញុំក៏ទៅដល់ស្រាប់តែ ទៅដល់ភូមិជ្រាប់ ខ្ញុំឃើញយាយមួយ យាយហ្នឹងគាត់យាយទ្រព្យ គាត់ឃើញខ្ញុំគាត់ថា “ហ៊ឺ! អាផុនអ្អែងៗទៅណាៗ?” គាត់ថាអ៊ីចឹងឯងស្រាប់តែខ្ញុំថា “អ៊ូ យាយ! ចុះយាយឯងមកនៅនេះពីអង្កាល់” គាត់ថា “អ៊ូ! អាផុនអើយ ទឹកលិចក្រោមអស់រលីងហើយ ទឹកលិចកន្លែងផ្ទះយើងនៅហ្នឹង ម៉ែឪអ្អែងៗ អត់ដឹងទេ?” ខ្ញុំថា “អត់ដឹងផង ថាម៉េចយាយ?” “ហ៊ឺះ! ឪអ្អែងគេយកទៅវាយចោល ម៉ែអ្អែងគេយកទៅវាយចោលអស់ គេយកទៅវាយអស់ហើយអាអើយ” គាត់និយាយអ៊ីចឹងថា “ចុះឥឡូវអ្អែងទៅនៅឯណា អ្អែងទៅណា?” ខ្ញុំក៏អត់ដឹងទៅឯណាទេ ខ្ញុំថា “យាយខ្ញុំអត់ដឹងទៅឯណាទេ បើម៉ែឪខ្ញុំស្លាប់អស់ហើយ”។ ខ្ញុំក៏អត់មានកងចូលទេយាយអើយ មិនដឹងចូលឯណាទេ មិនដឹងបានបាយឯណាហូបទេ។ គាត់ក៏ថា “ឥឡូវអ៊ីចេះ អ្អែងនេះទៅ បើឯងអត់ម៉ែឪ ម៉ែឪឯងងាប់អស់ហើយ កូនអញទាំងបីប្អូន ក៏គេយកទៅសម្លាប់ចោលអស់ហើយ អញៗដឹងព្រោះអីអញនៅជាមួយគាត់”។

**ស៖** បាទ សូមអរគុណ។ ទីកន្លែងដែលលោកទៅដល់ឈ្មោះភូមិជ្រាប់ -- ភ្នំជ្រាប់ចុះឯង ដែលជួបហ្នឹង យាយទ្រព្យហ្នឹង។ តើចម្ងាយពីភូមិក្រោយនេះ ភូមិដែលលោកទៅដល់ភូមិជ្រាប់ហ្នឹង ពីហ្នឹងទៅទំនប់ត្រពាំងថ្ម វាចម្ងាយឆ្ងាយពីគ្នា ឬក៏យ៉ាងម៉េចដែរ ចម្ងាយប៉ុន្មានលោកចាំបានទេ?

**ឆ៖** ខ្ញុំមិនដឹងគីឡូទេ បើខ្ញុំស្មានៗពីហ្នឹងទៅភ្នំជ្រាប់អី ទៅអាងត្រពាំងថ្ម ប្រហែលជា ម្ភៃប្លាយគីឡូដឹង បើទៅឆ្ងាយដែរ។

[១៤:០៦:១៧]

**ស៖** បាទ សូមអរគុណ។ លោកដឹងមូលហេតុ -- យាយទ្រព្យ មានបានប្រាប់លោកទេថា ឪពុកម្ដាយលោកហ្នឹង មូលហេតុអីទេដែលថា គាត់និយាយប្រាប់ថាត្រូវបានគេយកទៅសម្លាប់ចោល?

**ឆ៖** គេថា គេយកតែពុកខ្ញុំទៅសម្លាប់ទេ ព្រោះអីឪពុកខ្ញុំគាត់ជាប់ប្រវត្តិទាហាន គាត់ទាហានលន់នល់។ ដល់ពេលគេយកឪពុកខ្ញុំ ម្ដាយខ្ញុំគាត់ថា “បើយកឪពុក ក៏យកទាំងម្ដាយទៅ។ ទៅទាំងអស់គ្នាទៅទាំងកូនទាំងអី ព្រោះអីបើថាបើមិនអ៊ីចឹងទេ នៅក៏ពិបាកដែរ ទៅទាំងអស់គ្នា ទៅណាជុំគ្នាហ្នឹង”។ ប៉ុន្តែមិនមែនថា គេប្រាប់ថាយកទៅសម្លាប់ចោលទេ ថាយកជម្លៀសទៅឲ្យឆ្ងាយពីហ្នឹង កុំឲ្យនៅជិត

ហ្នឹងអី។ អ៊ីចឹងឯង ដល់ហើយគេយកទៅសម្លាប់ចោលទាំងអស់ហ្នឹងឯង។

**ស៖** បាទ សូមអរគុណ។ តើមានគេតាមទៅរកលោកទេ ដែលពេលជួបនឹងយាយទ្រព្យហើយនោះ ឬមួយក៏លោកធ្វើការងារអីបាននៅទីនោះ?

**ឆ៖** គេអត់តាមទេ តែខ្ញុំទៅដល់ យាយទ្រព្យ គាត់ប្រាប់ថា "ឥឡូវកូនឯង ធ្វើជាកូនម៉ែ" ហើយប្រាប់ថា "កូនឯងកាលនៅឯស្រុកភូមិនោះ កូនឯងឈឺ កូនឯងដេកពេទ្យ អត់មានកងមានក្រុមទេ បានអាចកូនឯង ចូលក្រុមកងនេះបាន។ គេកន្លែងកងនេះ គេហៅថាកងម៉េម៉ាយ កងស្ត្រីម៉េម៉ាយ គេនោះមានគ្នាចិតសិបប្លាយនាក់"។ គាត់និយាយអ៊ីចឹង គាត់ប្រាប់ឲ្យខ្ញុំប្រាប់តាមដំណើរទំនងនឹងទៅ គាត់ក៏នាំខ្ញុំទៅចូលកងហ្នឹង។ ចូលកងហ្នឹងក៏ប្រាប់មេកងៗ ហើយក៏មេកងគេថា "បើអ៊ីចឹងឲ្យវាចូលទៅ បើគ្នានៅឯណោះ គ្នាដេកពេទ្យ គ្មានអីនេះផង" ក៏គាត់ឲ្យខ្ញុំចូលកងហ្នឹងទៅ។ គាត់ឲ្យខ្ញុំចូលកងហ្នឹង គាត់ក៏ឲ្យខ្ញុំបាន៣ថ្ងៃប៉ុណ្ណោះឯង ខ្ញុំមិនទាន់ស្គាល់ក្រុមកង អីត្រឹមត្រូវផង ហើយវាវេទនាពេក ព្រោះអីបបររាវកក្លួក មួយវែកៗ អត់មានគ្រាប់អង្ករទេ គ្រាប់អង្ករពីរគ្រាប់ បីគ្រាប់ ម្នាក់ៗនៅកាប់ព្រៃហ្នឹងឯង នៅកាប់ ហើយខ្លួនអត់មានកម្លាំងទេ ដល់ក្បាលជង្គង់ធំៗណាស់។ ដើរល្វេតល្វតៗ ទោះបីតែខ្យល់ក៏ដួលរំលំដែរ ថាមើលទៅឃើញវេទនាពេក។ ដល់ពេលហ្នឹង មេកងក៏ប្រាប់ថា "ឥឡូវអ៊ីចេះ ផុន ឯង ហើយនិង អាអ៊ុត ហ្នឹងទៅរកត្រីឯក្រោមទៅ ដើម្បីយកមកដោះស្រាយជីវភាពពួកដែលអ្នកនៅ លើទាំងអស់គ្នាហ្នឹង" ខ្ញុំក៏បាននាំគ្នាពីរនាក់ទៅក្រោម។

[១៤:០៩:១០]

**ស៖** បាទ សូមអរគុណ។ នៅក្នុងកំណត់ហេតុ E3/4821ដដែល ដែលលោកបាននិយាយអំពីរឿងចុះទៅធ្វើការ ទៅរកត្រីនៅស្ទឹងកំបោរ។ កន្លែងនោះ តើមានអីកើតឡើង?

**ឆ៖** ខ្ញុំនៅរកនៅស្ទឹងកំបោរនោះ ខ្ញុំបង់សំណាញ់ កូនសំណាញ់តូចមួយ។ ខ្ញុំបង់សំណាញ់ពីរនាក់ អាអ៊ុត។ អាអ៊ុត គេអ្នកអុំទូកឲ្យខ្ញុំ ហើយខ្ញុំសំណាញ់រៀនមិនចង់ចេញបង់ផង បង់បែកតូចៗ ក៏ពេលនោះ ស្រាប់តែកំពុងបង់សំណាញ់ៗស្រាប់តែឮកាំភ្លើងមុខខ្ញុំហ្នឹងឯងមិនឆ្ងាយទេ ប៉ាំងៗ បីបួនគ្រាប់។ ស្រាប់តែ ហើយ អាអ៊ុត វាថានោះ អាប៉ិ មួយនោះ រត់ចុះទឹកហើយ រត់ហក់ទឹកហើយ។ ស្រាប់ដល់ហើយភ្លាមបាញ់គាត់ទៅ គាត់ស្លាប់នៅក្នុងទឹកហ្នឹងឯង ឡើងបីបួនថ្ងៃឡើងហើមស្ពឹង កន្លែងខ្ញុំបង់ត្រីហ្នឹង។

**ស៖** លោកដឹងអំពីមូលហេតុអីដែរទេ?

**ឆ៖** អត់ដឹងអំពីមូលហេតុដែលគេបាញ់សម្លាប់ចោលអត់ដឹងទេ ព្រោះអីខ្ញុំនៅបង់ត្រើងនេះ ខ្ញុំនៅឆ្ងាយពីគាត់។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ ខ្ញុំសូមសួរលោកបន្តិច តើនៅក្នុងការលើកទំនប់ត្រពាំងថ្មជាមួយនឹងលើកទំនប់ -- លើកប្រឡាយភ្នំល្អៀប តើនៅពេលហ្នឹង លោកមានបានចាំបានទេ ថាតើកងចល័ត តាវ៉ាល់ និងកងចល័តនៅភ្នំល្អៀប -- ប្រឡាយភ្នំល្អៀបហ្នឹង មេគ្រប់គ្រងតែមួយ ឬខុសគ្នា?

**ឆ៖** កងចល័តហ្នឹង មេគ្រប់គ្រងតែមួយទេ កងចល័ត តាវ៉ាល់ ទាំងពីរហ្នឹង ប៉ុន្តែគេចែកមុខសញ្ញាគ្នា ជួនកាលមួយក្រុមទៀតគេទៅជីកប្រឡាយ មួយក្រុមទៀតគេទៅលើកទំនប់ខាងនោះ គេចែកជា ដូចថាកងរយៗអ៊ីចឹង។

[១៤:១១:២៦]

**ស៖** តើមេកងនៅខាងទំនប់ភ្នំល្អៀបហ្នឹង ប្រឡាយភ្នំល្អៀបហ្នឹង លោកស្គាល់ឈ្មោះគេដែរទេ អ្នកគ្រប់គ្រងធំនៅហ្នឹង?

**ឆ៖** លើកក្រោយនេះមក គេហៅពួកនិរតីចូលៗ។ និរតីចូលហ្នឹងបាត់ឈ្មោះ តាវ៉ាល់ អត់ឮតាវ៉ាល់ទេ ឮឈ្មោះយាយថែមៗ វិញ មេៗធំ។

**ស៖** លោកដែលឃើញផ្ទាល់នឹងភ្នែកទេ តាវ៉ាល់ក៏ដោយ យាយថែមក៏ដោយ ពេលលើកទំនប់ហ្នឹងណា?

**ឆ៖** ខ្ញុំអត់ដែលឃើញទេ ទាំងតាវ៉ាល់ ទាំងយាយថែម អត់ដែលឃើញថាមុខគាត់យ៉ាងម៉េចផងប៉ុន្តែឮតែឈ្មោះ ឮតែគេហៅ ឮតែគេហៅថា “តាវ៉ាល់ៗ” “យាយថែមៗ” អត់ស្គាល់ទេ។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះ នៅក្នុងពេលនេះ ក្រោយពេលដែលលោកបានរួចរស់រៀនមានជីវិតមកវិញ តើលោកមានបាន -- និយាយរួមក្រោយពេលរបបខ្មែរក្រហមដួលរលំនៅក្នុងថ្ងៃ០៦ មករា ឆ្នាំ១៩៧៩ តទៅហ្នឹង លោកមានបានស្វែងរកឪពុកម្ដាយរបស់លោកម្ដងទៀតទេ ឬក៏ច្រើនដងទៀតទេ?

**ឆ៖** ខ្ញុំរកអស់ហើយអត់ៗជួបទេ គាត់ស្លាប់បាត់ហើយ ព្រោះអីរកខាងសៀមរាបក៏ខ្ញុំទៅរកខាងបាត់ដំបងនេះ ស្រុកដែលកំណើតកើតជានៅនេះក៏រកអត់ឃើញទេ គាត់ស្លាប់បាត់ហើយ ទាំងអស់។

**ស៖** អ៊ីចឹងតើចាប់ពីពេលការរស់រៀនមានជីវិតរបស់លោកឡើងវិញមកទល់សព្វថ្ងៃហ្នឹង នៅក្នុងអារម្មណ៍ ឬក៏នៅក្នុងដួងចិត្តរបស់លោក តើវាមានរសាយ ឬក៏មានអារម្មណ៍ភ្លេចរឿងរ៉ាវចាស់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយដែរឬនៅ?

**ឆ៖** នៅមានអារម្មណ៍ជិតជាប់នៅក្នុងខ្លួនរហូត គឺថាអត់ភ្លេចទេ កុំឲ្យតែរំឭកឡើង តែរំឭកអារឿងហ្នឹងឡើងចង់យំ ស្រក់ទឹកភ្នែករហូត បានអត់ចង់រំឭកឡើងទេ។

[១៤:១៤:១៨]

**ស៖** បាទ ឥឡូវនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងនាមលោកជាដើមបណ្ដឹងរដ្ឋប្បវេណី លោកមានសិទ្ធិទាមទារសំណងតាមផ្លូវច្បាប់។ តើលោកមានបំណងទាមទារសំណងនៅក្នុងនេះឲ្យតុលាការសម្រេចឲ្យលោកដែរទេ?

**ឆ៖** ទេ ឲ្យខ្ញុំទាមទារមែន ឲ្យតែធ្វើម៉េចឲ្យតុលាការវិនិច្ឆ័យមើលចុះ តើទង្វើដែលខ្មែរក្រហមអ្នកដឹកនាំខ្មែរក្រហមធ្វើអ៊ីចឹង ពូជខ្ញុំអស់ទាំងពូជ ដីធ្លីខ្ញុំអស់រលីង ផ្ទះសម្បែងខ្ញុំអស់រលីងអត់មានសល់ទេ តើឲ្យលោកតុលាការនោះជួយវិនិច្ឆ័យប៉ុណ្ណឹងបានហើយ។

**ស៖** តើលោកមានសំណួរអ្វីដែលចង់សួរទៅខាងជនត្រូវចោទដែរឬទេ? ក៏ប៉ុន្តែសំណួរនេះលោកមិនអាចសួរផ្ទាល់ទៅបានទេ គឺលោកត្រូវសួរតាមរយៈលោកប្រធានដឹកនាំអង្គសវនាការនេះ។ តើលោកអាចចាំពេលដែល តួនាទីលោក និយាយអំពីការឈឺចាប់ហើយ លោកអាចសួរសំណួរតាមរយៈលោកប្រធានបាន។ ខ្ញុំមានសំណួរត្រឹមនេះទេ ខ្ញុំសូមអរគុណលោក សែន សុផុន។

**លោក ហុង គឹមសួន៖**

បាទខ្ញុំសូមអរគុណ សូមបញ្ចប់ត្រឹមនេះលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

[១៤:១៦:១៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

ជាបឋមខ្ញុំបានសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពលោក លោកស្រីទាំងអស់ដែលមានវត្តមាននៅក្នុងអង្គសវនាការនាពេលនេះ។

**ស៖** ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ ហើយថ្ងៃនេះ ខ្ញុំមានសំណួរមួយ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ចំនួនចង់ឲ្យលោកសាក្សីជួយបំភ្លឺដល់អង្គសវនាការទាំងមូល។ សំណួរដំបូងរបស់ខ្ញុំគឺ ខ្ញុំចង់សួរថា តើការដែលលោកទៅធ្វើការនៅទំនប់អាងត្រពាំងថ្មនោះ តើលោកទៅដោយស្ម័គ្រចិត្ត ឬក៏គេតម្រូវឲ្យលោកទៅ?

**លោក សែន សុផុន៖**

**ផ៖** អត់ទេ ប្រធានសហករណ៍គេចាត់តាំងឲ្យទៅ។

**ស៖** តើលោកអាចបដិសេធមិនទៅបានដែរឬទេ?

**ផ៖** អត់បានទេ បើថាមិនទៅទេគេថា "ខ្មាំង" គេយកទៅសម្លាប់ចោលភ្លាម។

**ស៖** អ៊ីចឹង ដែលលោកមិនបដិសេធហ្នឹង ដោយសារលោកមិនហ៊ានបដិសេធ ឬក៏លោកមិនចង់បដិសេធ?

**ផ៖** មិនមែនទេ ខ្ញុំខ្លាចហ្នឹង ខ្ញុំខ្លាចស្លាប់។

[១៤:១៨:០២]

**ស៖** តើលោកមានធ្លាប់ដឹងថា មានអ្នកដែលបដិសេធមិនព្រមទៅធ្វើការនៅទំនប់អាងត្រពាំងថ្មនេះដែរឬទេ?

**ផ៖** អត់ដែល ប៉ុន្តែគេថាអង្គការចាត់តាំងត្រូវតែទៅ។

**ស៖** តើអ្នកណាគេអ្នកនិយាយសម្តីនេះប្រាប់លោក? លោកអាចប្រាប់បានទេ?

**ផ៖** ប្រធានសហករណ៍។

**ស៖** គាត់ឈ្មោះអីដែរ?

**ផ៖** គាត់ឈ្មោះ ពូផុន ស្រដៀងៗនឹងឈ្មោះខ្ញុំ។

**ស៖** អរគុណ។ លោកបានមានប្រសាសន៍អម្បាញ់មិញថា លោកទៅធ្វើការនៅទំនប់អាងត្រពាំងថ្មហ្នឹង នៅក្នុងឆ្នាំ១៩៧៧។ តើលោកអាចបញ្ជាក់បានទេទៅក្នុងខែណាដែរ?

**ផ៖** ខ្ញុំមិនចាំទេខែ គឺគ្មានខែ គ្មានថ្ងៃទេ ប៉ុន្តែខ្ញុំដឹងថានៅក្នុងចន្លោះ ៧៧ ហ្នឹងពាក់កណ្តាលឆ្នាំហ្នឹងឯង។

**លោក សេង លាង៖**

លោកប្រធាន បើលោកប្រធានអនុញ្ញាត ខ្ញុំសុំអានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីរំឭកការចងចាំខ្លះរបស់លោកសាក្សី។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសុំអានត្រង់ចំណុច ERN ឯកសារ E3/4821។ ERN ជាភាសាខ្មែរ 00523263, ERN ជាភាសារអង់គ្លេស 00916890, ហើយនិង ERN ជាភាសាបារាំង 00909833។ នៅក្នុងនោះលោកបានលើកឡើងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីថា "នៅក្នុងខែឧសភា ឆ្នាំ១៩៧៧ មេកងឈ្មោះ តាផុន បានហៅខ្ញុំឲ្យចូលទៅធ្វើការនៅកងចល័តព្រះនេត្រព្រះ ជាមួយឈ្មោះ វ៉ាត និងឈ្មោះអឿន និងអ្នកផ្សេងទៀត សរុបទាំងអស់១០នាក់"។ អ្វីដែលខ្ញុំអានប៉ុណ្ណេះ លោកអាចចាំបានទេថា តើលោកទៅធ្វើការនៅទំនប់អាងត្រពាំងថ្ម ក្នុងខែណាដែរ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១៤:២១:២៣]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដឹងថា សំណួរ<មួយនេះ ក៏ដូចជាឃ្លា>ដែលរៀបចំឡើងដោយសហព្រះរាជអាជ្ញា ត្រូវបានអង្គជំនុំជម្រះអនុញ្ញាតឲ្យប្រើប្រាស់ការរៀបចំសំណួរទាំងនេះជាច្រើនដងរួចមកហើយ។ <តែយ៉ាងណាក្តី> ខ្ញុំចង់បញ្ជាក់ជូនអង្គជំនុំជម្រះអំពីការអនុវត្តដែលត្រូវបានសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសវនាការលើបណ្តឹងសាទុក្ខនាពេលថ្មីៗនេះ។ <ក្នុងសវនាការនាពេលថ្មីហ្នឹង> តុលាការកំពូលបានបង្គាប់ឲ្យភាគីទាំងអស់ មិនឲ្យអានសម្រង់ចេញពីចម្លើយរបស់<ពួកគាត់>ផ្ទាល់ <ហើយបន្ទាប់មកសួរឲ្យបញ្ជាក់នោះទេ>។ <ឥឡូវនេះ ខ្ញុំដឹងថា វាមិនមែនជា>សេចក្តីសម្រេច<អ៊ីចឹងទេ។ ដូច្នេះក្នុងក្របខ័ណ្ឌនេះ យើងមិនត្រូវបានចងភ្ជាប់ដោយការអនុវត្តមួយនេះទេ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំគិតថាវាគឺជាការកត់សម្គាល់ដ៏ល្អប្រសើរក្នុងការ>រំឭកជូនអង្គជំនុំជម្រះថា <នេះគឺជាអ្វីដែល>យើង<តម្រូវឲ្យធ្វើនៅក្នុងសវនាការលើ>បណ្តឹងសាទុក្ខ។ ដូច្នេះខ្ញុំគិតថាយើងជួបស្ថានភាពថ្មីមួយ ហើយ>យើងខ្ញុំសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង <ពិចារណាឡើងវិញអំពី>ការអនុវត្តជាក់ស្តែងដែលត្រូវបានសម្រេចឡើងដោយតុលាការកំពូល<>ហើយហាមឃាត់មិនឲ្យ<សហព្រះរាជអាជ្ញា គ្រាន់តែអាននូវសម្រង់មួយ ហើយបន្ទាប់មកសួរឲ្យបញ្ជាក់បែបនោះទេ។។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៤:២៣:១០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ ដើម្បីឲ្យអង្គជំនុំជម្រះអាចសម្រេចលើបញ្ហានេះបាន -- ដើម្បីឲ្យអង្គជំនុំជម្រះអាចសម្រេចលើសំណើរបស់លោកនេះបាននេះ តើលោកអាចផ្តល់ប្រតិចារឹកសវនាការជាក់លាក់បានទេ គឺថាប្រតិចារឹកដែលបានបញ្ជាក់អំពីទម្លាប់អនុវត្តដែលលោកលើកឡើងនេះ<?>

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំ>មិនអាច<ចាំ>នៅពេលឥឡូវនេះបានទេលោកចៅក្រម ក៏ប៉ុន្តែ<វា>ជាសេចក្តីសម្រេចលាយលក្ខណ៍អក្សរ<មួយ។ វាមិនមែនជា>ការបង្គាប់នៅក្នុងពេលសវនាការលើបណ្តឹងសាទុក្ខ<នោះទេ តែវា>គឺជាសេចក្តីសម្រេចពាក់ព័ន្ធទៅនឹងការណែនាំ និងការអនុវត្តជាក់ស្តែងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅកាន់សាក្សី គឺឯកសារ F26។ ខ្ញុំមានអត្ថបទនេះជាភាសាបារាំង <ហើយ>ខ្ញុំ<រីករាយ>អានជាភាសាបារាំង<ជូន> បើអនុញ្ញាត។ ERN ជាភាសាបារាំង គឺ <01110269 សម្រាប់អ្នកបកប្រែក្នុង*ប៊ូត* សូមត្រៀម> ឥឡូវនេះខ្ញុំ<ខំប្រឹង>អានជាបារាំង<ដូចតទៅ>៖ "លើកលែងតែមានការបង្គាប់ផ្ទុយពីនេះរបស់អង្គជំនុំជម្រះ ការសួរសាក្សីគឺមិនត្រូវអានសម្រង់នូវចម្លើយមុនៗរបស់សាក្សីយកមកសួរគាត់ ហើយបន្ទាប់មកឲ្យគាត់បញ្ជាក់អះអាងទៅលើខ្លឹមសារនៃចម្លើយរបស់គាត់នោះទេ។ សក្ខីកម្មមុនៗអាចយកមកប្រើបាន <គឺ>ដើម្បីបង្ហាញអំពីភាពជឿជាក់បាន<របស់>សាក្សី ឬក៏សម្រាប់ផ្តល់ការបំភ្លឺទៅលើភាព<ផ្ទុយ>គ្នារវាងចម្លើយផ្សេងៗរបស់សាក្សី។"

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១៤:២៥:៤៤]

**លោក ចូសេហ្វ អេនទ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លី<ចំនួនពីរបី។> ទី១ គឺថានេះមិនមែនជាស្ថានភាពដែល<>មេធាវីការពារក្តីស្នើសុំ<បញ្ជាក់ចម្លើយនោះទេ។ នេះជា>ស្ថានភាព<>ដែល<គាត់>សួរសំណួរ ហើយសុំការអនុញ្ញាតពីលោកប្រធាន<ដើម្បីរំឭកការចងចាំរបស់សាក្សីប៉ុណ្ណោះ។ ដូច្នេះខ្ញុំចង់ធ្វើការបែងចែកឲ្យដាច់គ្នាត្រង់ចំណុចនេះ។ ចំណុចទី២ លើសនេះទៀតនោះ> ដូចដែលមេធាវី

ការពារក្ដីកត់សម្គាល់ហើយ ការអនុវត្ត<នៃការ>អាន<កំណត់ហេតុ ស្ដាប់ចម្លើយជូនដល់>សាក្សី<> និងដើមបណ្ដឹងរដ្ឋប្បវេណី<> គឺថាត្រូវបានអនុវត្តជាយូរមកហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ខ្ញុំ<គិតថា បើសិនជា>មេធាវីការពារក្ដី<>ស្នើសុំឲ្យអង្គជំនុំជម្រះកែប្រែទម្លាប់នៃការអនុវត្តនេះប្រាកដណាស់ វាគួរតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយអនុញ្ញាត>ឲ្យភាគីទាំងអស់<មានឱកាសក្នុងការ>ឆ្លើយតបទៅនឹងសំណើសុំ<នេះផង>។ <ចំណុចចុងក្រោយទី៣ ខ្ញុំសូមធ្វើការកត់សម្គាល់ថា>ដោយសារថា អង្គជំនុំជម្រះសាលាដំបូង<នេះ>មានឆន្ទានុសិទ្ធិយ៉ាងទូលំទូលាយនៅក្នុងការដឹកនាំ<រៀបចំ>កិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះតុលាការកំពូលបានជ្រើសរើសសម្រេចយករបៀបនៃការ<រៀបចំ>សវនាការរបស់ខ្លួនតាមរបៀប<នៃសវនាការភស្តុតាងលើបណ្ដឹងសាទុក្ខ ដែលវាមិនពាក់ព័ន្ធចាំបាច់អ្វីទៅនឹងរបៀបដែលអង្គជំនុំជម្រះសាលាដំបូងជ្រើសរើសក្នុងការ<រៀបចំ>សវនាការនោះទេ>។ សូមអរគុណ។

[១៤:២៧:១២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៤:២២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅចៅក្រមហ្សង់ម៉ាក ឡាវែន៍ ដើម្បីឆ្លើយតបទៅលើបញ្ហាដែលលើកឡើងដោយមេធាវីការពារក្ដីលោក នួន ជា គឺ លោក កូប៉េ អម្បាញ់មិញនេះ ចំពោះការតាំងសំណួររបស់សហព្រះរាជអាជ្ញារងជាតិ ដែលបានធ្វើនូវសំណួរចុងក្រោយចំពោះដើមបណ្ដឹងរដ្ឋប្បវេណី។ បាទ សូមអញ្ជើញ លោកចៅក្រមហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងយល់អំពីអនុសាសន៍របស់អង្គជំនុំជម្រះតុលាការកំពូល គឺដើម្បីចៀសវាងនូវការអនុវត្តជាទូទៅក្នុងពេលសួរសំណួរសាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីគឺ ដើម្បីចៀសវាងនូវការ<អាននូវចម្លើយ>ដដែលៗ< និងវែងអន្លាយចេញពីកំណត់ហេតុស្ដាប់ចម្លើយមុនៗ>របស់<បុគ្គល>ដែល<ត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ>។ ដូច្នេះ នេះជាការមិនសមស្របក្នុងការធ្វើការសួរនាំបែបនេះ ក៏ប៉ុន្តែ<ដោយហេតុផលមានកម្រិតណាមួយ>ដើម្បីរំឭកការចងចាំរបស់សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណី ឬដើម្បី<ធ្វើតេស្ត>បង្ហាញអំពីភាពជឿជាក់របស់

សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី គឺភាគីអាចយោងទៅលើចម្លើយពីមុនៗរបស់អ្នកដែលត្រូវមកផ្តល់ចម្លើយ។ ក៏ប៉ុន្តែត្រូវអានឲ្យបានច្បាស់ ឧទាហរណ៍ ដូចជាសំណួរចុងក្រោយរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគឺត្រូវធ្វើយ៉ាងម៉េចរៀបចំឡើងវិញ ដើម្បីឲ្យឃើញអំពីគោលបំណងច្បាស់លាស់នៃការដកស្រង់បែបនេះ។ ដូច្នេះ ខ្ញុំ<យល់ឃើញ>ថា អ្វីដែលលើកឡើងនេះ គឺច្បាស់សម្រាប់ទាំងអស់គ្នា គឺគោលបំណងនៃការដកស្រង់នេះ គឺធ្វើយ៉ាងម៉េចដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីថាតើ សួរគាត់ ថាតើគាត់ចាំឬទេនូវអ្វីដែលគាត់បានឆ្លើយពីមុន ហើយអាចសួរគាត់ថា តើវាត្រឹមត្រូវទៅនឹងអ្វីដែលគាត់បានចងចាំដែរឬទេ ចំពោះចម្លើយរបស់គាត់ពីមុននេះ។ ខ្ញុំគិតថានេះជាវិធីសាស្ត្រដែលយើងត្រូវអនុវត្តសម្រាប់នៅពេលអនាគត។

**លោក សេង លាង៖**

អរគុណចំពោះអនុសាសន៍លោកប្រធាន។ ខ្ញុំសូមរៀបចំសំណួរខ្ញុំឡើងវិញ។ ដោយសារថា ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានឆ្លើយថា គាត់ធ្លាប់នៅធ្វើការនៅអាងត្រពាំងថ្មក្នុងឆ្នាំ១៩៧៧ ប៉ុន្តែគាត់មិនបញ្ជាក់ពីខែទេ ហើយពេលដែលខ្ញុំថានៅខែណា? ដើមបណ្តឹងរដ្ឋប្បវេណីគាត់ដូចជាមានការមិនច្បាស់លាស់។ ដូច្នេះហើយបានជាខ្ញុំអាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះរំឭកការចងចាំរបស់គាត់ ដើម្បីឲ្យគាត់មានជំនឿក្នុងការឆ្លើយចម្លើយ។ ហើយប្រសិនជាអង្គជំនុំជម្រះតម្រូវឲ្យខ្ញុំរៀបសំណួរឡើងវិញ ខ្ញុំពេញចិត្តនឹងរៀបសំណួរនេះឡើងវិញដើម្បីលៃយ៉ាងណាឲ្យងាយស្រួលដល់ការយល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយកុំចៀសវាងភាពច្រំដែល។

**សួរដោយលោក សេង លាង៖**

**ស៖** ខ្ញុំសូមអានសម្រង់នេះម្តងទៀតគឺ “នៅក្នុងខែឧសភា (ខែ៥) ឆ្នាំ១៩៧៧ មេកង ឈ្មោះ ផុន – តាផុន បានហៅខ្ញុំឲ្យចូលទៅធ្វើការនៅកងចល័តស្រុកព្រះនេត្រព្រះ ជាមួយឈ្មោះ វ៉ាត (មិនដឹងរស់ ឬ ស្លាប់) ឈ្មោះ អឿន (ស្លាប់) និងអ្នកផ្សេងទៀត មិនចាំឈ្មោះ សរុបទាំងអស់១០នាក់”។ ដូច្នេះ ចម្លើយដែលលោកបានឆ្លើយនៅក្នុងកំណត់ហេតុនេះ តើលោកនៅរក្សាដដែល ឬក៏យ៉ាងណា?

ខ្ញុំសូមសួរថា អ្វីដែលខ្ញុំបានអានជូនលោកអម្បាញ់មិញនេះ គឺលោកមកធ្វើការនៅអាងត្រពាំងថ្មនៅក្នុងខែឧសភា ឆ្នាំ៧៧។ តើចម្លើយនេះ លោកនៅរក្សាដដែល ឬក៏លោកយល់យ៉ាងណាដែរ?

**លោក សែន សុផុន៖**

**ឆ៖** ខែឧសភា ឆ្នាំ៧៧។

[១៤:៣៩:២៦]

**ស៖** អរគុណលោក ហើយលោកក៏បានឆ្លើយដែលថា ជាមួយនឹងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីលោកថា បានធ្វើការនៅអាងត្រពាំងថ្មអស់រយៈពេលពីរខែ ហើយបានចាកចេញទៅស្ពានស្រែង។ អ៊ីចឹង តើពិតដែរទេ លោកនៅ -- អ្វីដែលខ្ញុំលើកឡើងនេះត្រឹមត្រូវដែរទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** លោកអាចប្រាប់បានទេ នៅពេលដែលលោកទៅដល់ក្នុងខែឧសភា ឆ្នាំ៧៧ហ្នឹង តើការដ្ឋានត្រពាំងថ្មហ្នឹង គេចាប់ផ្ដើមសាងសង់ហើយ ឬក៏យ៉ាងណា?

**ឆ៖** ជិតស្រេចហើយ ជិតសម្រេចហើយ គេឱ្យខ្ញុំទៅសម្រុកដល់សម្រេច។

**ស៖** អ៊ីចឹងមានន័យថា នៅពេលដែលលោកចាកចេញហ្នឹង ការសាងសង់ហ្នឹងអត់ទាន់បង្ហើយទេ ឬយ៉ាងណា?

**ឆ៖** មិនហើយ១០០ភាគរយទេ គឺនៅពង្រាបឱ្យស្មើ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ លោកសហព្រះរាជអាជ្ញារង។ បាទឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់រួមទាំងបុគ្គលិកអង្គការ ធី.ភី.អូ មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៤:៥៩ នាទី)*

[១៤:៥៩:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសធ្វើដំណើរការ ហើយនិងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា

ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណី។ សូមអញ្ជើញ!

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** មុននឹងពេលសម្រាកនេះ ខ្ញុំបានសួរបញ្ជាក់លោកសាក្សីថា គាត់បានទៅធ្វើការនៅស្ពានស្រែង តែខ្ញុំសូមឲ្យលោកសាក្សីជួយបញ្ជាក់មើលថា ការដ្ឋានស្ពានស្រែងហ្នឹង គឺជាការដ្ឋានអ្វី? ហើយវាមានទំនាក់ទំនងអ្វីជាមួយនឹងអាងត្រពាំងថ្ម?

**លោក សែន សុផុន៖**

**ឆ៖** ស្ពានស្រែង គឺលើកទំនប់ទប់បណ្តោយចាក់ពីត្រពាំងថ្មទៅ។

**ស៖** តើគោលដៅនៃការសាងសង់ស្ពានស្រែងហ្នឹងគឺក្នុងគោលដៅអីដែរ? លោកអាចប្រាប់បានទេ?

**ឆ៖** អត់ដឹង។

**ស៖** ឥឡូវ ត្រឡប់មកការដ្ឋានទំនប់ត្រពាំងថ្មវិញ។ តើលោកអាចប្រាប់បានទេមានមនុស្សប្រហែលប៉ុន្មាននាក់ដែលធ្វើការនៅការដ្ឋានទំនប់អាងត្រពាំងថ្មហ្នឹង?

**ឆ៖** រាប់ពាន់នាក់។

**ស៖** តើលោកអាចប្រាប់អំពីសមាសភាពអ្នកដែលចូលរួម កម្មករដែលចូលរួមលើកទំនប់អាងត្រពាំងថ្មហ្នឹងបន្តិចបានទេថា តើវាមានភេទយ៉ាងណាខ្លះ? ហើយវាមានអាយុពីប៉ុន្មានទៅប៉ុន្មាន តើលោកអាចប្រាប់បានទេ?

**ឆ៖** បាទ ពីអាយុ១៨ឆ្នាំ រហូតទៅដល់អាយុ៣០ជាង គេហៅក្រុមចល័ត។

[១៥:០១:៥៨]

**ស៖** តើអ្នកធ្វើការនៅទីនោះមានតែស្រី ឬក៏មានទាំងប្រុសទាំងស្រី?

**ឆ៖** មានទាំងប្រុសមានទាំងស្រី គេហៅ កងយុវនារី កងយុវជន។

**ស៖** តើធ្វើការនៅទីនោះកម្មករម្នាក់ៗមានសិទ្ធិក្នុងការជ្រើសរើសការងារដែលគេជ្រើសរើសការងារដែលគេចង់ធ្វើដែរឬទេ? ឬក៏ធ្វើការងារតាមការតម្រូវរបស់មេកងរបស់ខ្លួន?

**ឆ៖** អត់មានសិទ្ធិទាមទារ បើមេកងដាក់យ៉ាងណាឲ្យធ្វើយ៉ាងនោះ ត្រូវតែធ្វើតាម។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** បើមានអ្នកបដិសេធមិនព្រមធ្វើការងារនោះ តើមានអ្វីកើតឡើងចំពោះគេដែរឬទេ?

**ឆៈ** អត់បានដឹងដែរ មិនដែលឃើញ។

**សៈ** ក្នុងការឆ្លើយសំណួរជាមួយនឹងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី លោកបានជម្រាបថា គេតម្រូវឱ្យលោកលើកដីហ្នឹង រែកដីក្នុងមួយថ្ងៃ ៣ម៉ែត្រគូប ហើយលោកបាននិយាយទៀតថា "មានក្រុមខ្លះដល់ ៣,៥ម៉ែត្រគូប ហើយក្រុមខ្លះដែលជាក្រុមស្រួចរហូតដល់ ៤ម៉ែត្រគូប"។ តើលោកអាចបែងចែកទេរវាងថា តើហេតុអីបានជាក្រុមលោកគេឱ្យ ៣ម៉ែត្រគូប ហើយមានក្រុមមួយទៀត ៣,៥ម៉ែត្រគូប ហើយក្រុមមួយទៀតដែលជាក្រុមស្រួចហ្នឹង ៤,៥ម៉ែត្រគូប? លោកបញ្ជាក់មើលក្រុមមួយៗខុសគ្នាយ៉ាងដូចម្ដេច?

**ឆៈ** ក្រុមខ្ញុំ ក្រុមកម្លាំងអត់ពេញ។ ក្រុមគេ ក្រុមកម្លាំងពេញ បានគេដាក់កម្លាំងស្រួច។

**សៈ** ខុសគ្នាយ៉ាងដូចម្ដេចរវាងក្រុមដែលកម្លាំងពេញ និងក្រុមមិនកម្លាំងពេញហ្នឹង វាខុសគ្នាយ៉ាងម៉េចដែរ? អាចប្រាប់បានទេ? ឧទាហរណ៍ថា សមាជិកក្រុមហ្នឹងវា ដោយសារតែសមាជិកក្រុមហ្នឹងវាយ៉ាងម៉េចបានជាចាត់ទុកថាកម្លាំងអត់ពេញ? ហើយសមាជិកក្រុមវាយ៉ាងម៉េចបានជាចាត់ទុកថាកម្លាំងពេញ? លោកអាចប្រាប់បានទេ?

**ឆៈ** ព្រោះខ្ញុំទើបតែទៅ អ្នកសមរភូមិក្រោយ។ គេអ្នកសមរភូមិមុខ គេដើរទៅមុន។ ពួកខ្ញុំសមរភូមិក្រោយ នៅគេចាត់ទុកថាកម្លាំងតូចជាង។

[១៥:០៥:២៣]

**សៈ** លោកអាចប្រាប់បានទេ មានក្រុមណាដែលគេតម្រូវឱ្យលើកដីតិចជាង៣ម៉ែត្រគូបដែរឬទេ?

**ឆៈ** អត់។

**សៈ** អរគុណ។ ក្នុងការលើកដី៣ម៉ែត្រគូបក្នុងមួយថ្ងៃហ្នឹង តើគេផ្ដល់សម្ភារៈអីខ្លះ ឱ្យលោកក្នុងការលើកដីហ្នឹង?

**ឆៈ** មានតែចប ហើយនិងបង្គីប៉ុណ្ណោះ ហើយនិងខ្សែ និងដងរែក។

**សៈ** តើមានគ្រឿងចក្រដែរឬទេ ជាជំនួយដល់លោក?

**ឆៈ** អត់ទេ មានតែចបកាប់។

**សៈ** អ៊ីចឹង ក្នុង -- លោកចង់មានន័យថា ក្នុងរង្វង់៣ម៉ែត្រគូបហ្នឹង គឺលោកប្រើតែចប បង្គី និង

ដៃផ្ទាល់ ក្នុងការរែកកាប់ រែក និងជញ្ជូនដីហ្នឹង ឬយ៉ាងម៉េចដែរ?

**ឆ៖** បាទ រែកៗកាប់ រែកកាប់ដៃជួយកាយ កាយដាក់បង្គីឲ្យរែកៗ។

**ស៖** តើលោកអាចឆ្លើយតបតាមផែនការដែលគេឲ្យតម្រូវ៣ម៉ែត្រគូបហ្នឹង បានយ៉ាងដូចម្ដេចដែរ?

**ឆ៖** អត់យល់ ពាក្យហ្នឹងខ្ញុំអត់យល់។

**ស៖** ខ្ញុំសូមទោស ប្រហែលជាខ្ញុំសួរសំណួរវាស្មុគស្មាញពេក ខ្ញុំសូមសួរសំណួរមកអ៊ីចេះវិញ។ លោកបានជម្រាបថា គេឲ្យលោករែកដី៣ម៉ែត្រគូបក្នុងមួយថ្ងៃ។ នេះគឺជាផែនការដែលមេកងដាក់ឲ្យលោក។ ប្រសិនបើលោករែកមិនគ្រប់ផែនការ -- ខ្ញុំចង់សួរថា តើលោកធ្វើយ៉ាងម៉េចដើម្បីរែកឲ្យគ្រប់ផែនការដែលគេដាក់ឲ្យហ្នឹង?

**ឆ៖** បាទ ខ្ញុំរែកអត់គ្រប់ អត់រួច៣ម៉ែត្រគូប ខ្ញុំអត់បានបាយហូបទេ។ ខ្ញុំនៅរហូតទាល់តែម៉ោងដប់ បានគេរំសាយឲ្យទៅសម្រាក ម៉ោងដប់យប់។

**ស៖** លោកបាននិយាយមុននេះថា លោកចាប់ផ្ដើមធ្វើការនៅម៉ោងបួនព្រឹក ហើយពេលយប់ ធ្វើការរហូតដល់ម៉ោងប្រាំបួនទៅម៉ោងដប់។ តើការដែលពេលសម្រាករយៈពេលហ្នឹង គឺវាអាចឲ្យលោកមានកម្លាំងគ្រប់គ្រាន់ក្នុងការធ្វើការងារដែរឬទេ?

[១៥:០៨:៤៦]

**លោក គង់ សំអុន៖**

បាទ--

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី គង់ សំអុន។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ តាមខ្ញុំស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីកន្លងទៅនេះ គាត់បញ្ជាក់ថា ម៉ោងបួនព្រឹកហ្នឹង មេកងចាប់ផ្ដើមវាយអាគាំង មិនមែនជាម៉ោងដែលគាត់ត្រូវធ្វើការទេ។ បាទ សូមអរគុណ។

**សួរដោយលោក សេង លាង៖**

**ស៖** ឥឡូវខ្ញុំសូមសួរបញ្ជាក់លោកសាក្សីម្ដងថា ទៀតថា តើព្រលឹមឡើង លោកចាប់ផ្ដើមធ្វើ

ការនៅម៉ោងប៉ុន្មានដែរ?

**លោក សែន សុផុន៖**

**ឆ៖** ឲ្យតែភ្លឺមើលឃើញ កុំកាប់ត្រូវគ្នា គឺថាចាប់ផ្តើមឲ្យធ្វើតែម្តង។

**ស៖** តើលោកក្រោកពីដេក នៅពេលដែលមេកងវាយជួងនៅម៉ោងបួននៅភ្លឺហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** ម៉ោងបួនហ្នឹង តែវាយជួងហើយ បើអ្នកណាមិនក្រោកទេ យករំពាត់ដេញវាយពេញរោងហ្នឹងឯង។

[១៥:១០:០០]

**ស៖** ការសម្រាកពីម៉ោងដប់យប់ រហូតដល់ម៉ោងបួនភ្លឺក្រោកហ្នឹង តើលោកមានកម្លាំងគ្រប់គ្រាន់ក្នុងការលើកដី ៣ម៉ែត្រគូបក្នុងមួយថ្ងៃដែរ ឬយ៉ាងណា?

**ឆ៖** អត់មានទេ អត់មានកម្លាំងទេ អត់មានកម្លាំងធ្វើការទេ ប៉ុន្តែចេះតែទ្រាំ ធ្វើដោយបង្ខំចិត្ត។ ធ្វើបានប៉ុនណា យកប៉ុណ្ណោះ បើថាគេមិនឲ្យបាយស៊ី ក៏សុខចិត្តទ្រាំអត់ ចេះតែធ្វើទៅ ព្រោះអីគេឲ្យធ្វើ។

**ស៖** តាមដែលលោកនិយាយថា នៅក្នុងកងហ្នឹងមានទាំងបុរស មានទាំងស្ត្រី។ តើស្ត្រីក៏ត្រូវគេតម្រូវឲ្យរែកដី ៣ម៉ែត្រគូបដែរឬយ៉ាងណា?

**ឆ៖** រែកទាំងបុរស ទាំងស្ត្រី មិនថាស្ត្រី ៣ម៉ែត្រ -- ប្រុស ៣ម៉ែត្រគូប, ស្ត្រី ៣ម៉ែត្រគូប ៣ម៉ែត្រគូបស្មើគ្នាទូទៅទាំងអស់។

**ស៖** ក្នុងការឆ្លើយទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី លោកបានឆ្លើយថា លោករែកដីចម្ងាយ១៥ម៉ែត្រ។ តើលោកអាចប្រាប់បានទេថា តើក្នុងមួយអម្រែកៗហ្នឹង លោករែកហ្នឹងប្រហែលជាប៉ុន្មានគីឡូដែរ ដើម្បីមួយអម្រែកលោករែក១៥ម៉ែត្រ តើប្រហែលប៉ុន្មានគីឡូដែរ?

**ឆ៖** បើគិតទៅប្រហែលជា៣០គីឡូ ទៅ ៤០គីឡូ។

**ស៖** ជារៀងរាល់ថ្ងៃ តើនរណាគេជាអ្នកដើរពិនិត្យមើលថា តើការងារដែលដាក់ឲ្យហ្នឹង ឆ្លើយតបបានតាមផែនការដែលគេដាក់ឲ្យឬយ៉ាងណា? តើនរណាគេអ្នកដើរពិនិត្យមើលលទ្ធផលការងារដែលក្រុមរបស់លោកធ្វើក្នុងមួយថ្ងៃៗហ្នឹង?

**ឆ៖** មានតែមេកង មេកងវ៉ា។

[១៥:១២:១៧]

**ស៖** លោកបាននិយាយមុននេះថា លោកធ្វើការ បើមិនហើយ គឺមិនបានអាហារហូបទេ ដូច្នេះ

លោកត្រូវតែធ្វើដល់ម៉ោងដប់យប់ ហើយទៅយកអាហារ។ ចុះបើដល់ម៉ោងដប់ហើយ លោកធ្វើមិនហើយ តើលោកបានអាហារហូបដែរឬទេ?

**ឆ៖** ដល់ពេលម៉ោងដប់យប់ហើយ គេលើកលែងឲ្យ គេបើកអាហារឲ្យហូបហើយ។

**ស៖** តើលោកមានដែលឮករណីកម្មករណាមួយដែលខ្ជិលច្រអូសដែរឬទេ?

**ឆ៖** មានអ្នកខ្ជិល អ្នកខ្ជិលគេអត់ឲ្យបបរហូបទេ គេអត់ឲ្យហូប បើអ្នកឈឺបានគេឲ្យហូប។

**ស៖** តើលោកមានដែលឮថា គេមានវិធានការអីខ្លះចំពោះអ្នកដែលខ្ជិល ដូចជាគេដាក់នៅក្នុងក្រុមអីណាមួយ ឬក៏យ៉ាងម៉េចអី តើលោកមានដែលឮទេ?

**ឆ៖** អត់ទេ។ បើគាត់ខ្ជិល មេកងទៅវាយតែម្តង វាយបណ្តេញឲ្យចេញមកធ្វើការ។

**ស៖** លោកអាចប្រាប់បានទេ មុនហ្នឹងលោកឆ្លើយជាមួយដើមបណ្តឹងរដ្ឋប្បវេណីថា លោកបានសុំច្បាប់មកលេងផ្ទះដែរ ប៉ុន្តែគេមិនឲ្យលោកមក។ គេមានប្រាប់មូលហេតុអ្វី បានគេមិនឲ្យលោកមកដែរឬទេ?

**ឆ៖** គេមិនប្រាប់ពីមូលហេតុទេ គេអត់អនុញ្ញាតឲ្យ គេថាគេមិនអនុញ្ញាតឲ្យមកអ៊ីចឹងតែម្តង។

[១៥:១៥:១៣]

**ស៖** នៅក្នុងកងរបស់លោកហ្នឹង តើមានអ្នកណាម្នាក់ដែលនឹកផ្ទះ ហើយមិនត្រូវបានគេអនុញ្ញាតហើយលួចរត់មកលេងផ្ទះដែរឬទេ?

**ឆ៖** អត់មានទេ កន្លែងខ្ញុំអត់មានអ្នកលួចរត់ទេ។

**ស៖** គេអត់មកលេងផ្ទះហ្នឹងដោយដូចជាលោកអ៊ីចឹង ដែលលោកសុំច្បាប់គេហើយ គេមិនឲ្យទៅលេងផ្ទះហ្នឹងលោកមិនទៅ ដោយសារថាយ៉ាងម៉េចបានជាលោកមិនទៅ លោកអាចប្រាប់ម្តងទៀតបានទេ?

**ឆ៖** បាទ បើមិនហ៊ានទៅដោយសារអី ដោយសារខ្លាចស្លាប់ តែយើងរឹងទទឹងនឹងអង្គការគេយកទៅវ៉ៃចោល។

**ស៖** លោកដឹងរឿងនេះតាមនរណាដែរ?

**ឆ៖** មេកងគេប្រជុំ តែនេះគេចាប់ផ្តើមប្រជុំ។ គេប្រជុំថា តើអ្នកណាហ៊ានរឹងទទឹងនឹងអង្គការយកទៅវ៉ៃចោល។

**ស៖** តើនៅកន្លែងការដ្ឋានអាងត្រពាំងថ្មហ្នឹងមានឆ្នាំ ឬទាហានយាមនៅការដ្ឋានការងារហ្នឹង

ដែរឬទេ?

**ឆ៖** អត់មានទាហាន អត់មានអីទេ មានតែឈ្លប យូរៗដើរឃើញ ដើរម្នាក់ស្ពាយកាំភ្លើងមួយដើមដើរទៅ។

**ប្រធានអង្គជំនុំ៖**

សំឡេងរោទិ៍ស្អីគេ?

បាទ អញ្ជើញតទៅទៀត!

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** និយាយអំពីភាពធូន់ធ្ងរនៃការងារវិញ តើលោកមានធ្លាប់ឃើញ ឬក៏ឮថាមានមនុស្សដែលស្លាប់ដែលបណ្តាលមកពីការធ្វើការហួសកម្លាំង ឬក៏ដោយសារភាពអត់ឃ្លានដែរឬទេ?

[១៥:១៨:២៤]

**លោក សែន សុផុន៖**

**ឆ៖** ដោយសារអត់ឃ្លាន ខ្ញុំឃើញផ្ទាល់ភ្នែកដែលស្លាប់ ខ្ញុំឃើញផ្ទាល់ភ្នែក។ ខ្ញុំមិនទាន់មកកងចល័ត ខ្ញុំនៅក្នុងកងភ្នួរខ្ញុំ។ គ្នាអត់ គ្នាស្រែកសុំបាយមួយដុំមក "ខ្ញុំសុំបាយមួយដុំមកៗ" សុំទាល់តែស្លាប់ដាច់ខ្យល់បិតនៅមុខខ្ញុំអីចឹងឯង។

**ស៖** ចុះចំណែកអ្នកដែលធ្វើការហួសកម្លាំង ហើយស្លាប់មានដែរឬទេលោក?

**ឆ៖** ខ្ញុំមិនបានឃើញដែរ។

**ស៖** មុននេះ កាលពីផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី លោកបាននិយាយអំពីកន្លែងស្នាក់នៅ។ តើលោកអាចបញ្ជាក់ម្តងទៀតបានទេថា តើកន្លែងស្នាក់នៅលោកគេមានប្រគល់ដូចជាសម្ភារៈ ដូចជាៗមុង ដូចជាភួយ ដូចជាកន្ទេល ខ្នើយអីត្រឹមត្រូវឲ្យលោកស្នាក់នៅដែរឬទេ?

**ឆ៖** អត់មាន មុងអត់មាន ខ្នើយអត់មាន ភួយអត់មាន កន្លែងគ្រែងដេកក៏អត់មាន ដេកក្នុងដីអ្នកណាមានអីក្រាលដេកខ្លួនឯង បើមិនអីចឹងដើរយកចំបើងមកក្រាលដេកខ្លួនឯង។

**ស៖** នៅក្នុងអំឡុងពេលដែលលោកធ្វើការងារនៅពេលនោះ នៅពេលដែលលោកសម្រាកយប់

នោះតើដែលមានភ្លៀងធ្លាក់ដែរឬទេ?

[១៥:២០:៣០]

**ឆ៖** មានភ្លៀងធ្លាក់មកៗជួនកាល ដំបូលលិចអស់រងានាំគ្នាអង្គុយញាក់ ៗហើយព្រលឹមឡើងធ្វើការទៀត។

**ស៖** លោកចង់និយាយថានៅពេលដែលភ្លៀងធ្លាក់មកគឺ ក្រុមរបស់លោកទទឹកភ្លៀងជោក មិនអាចសម្រាកបានដែរបានទេ ឬយ៉ាងណា?

**ឆ៖** គេមិនឲ្យសម្រាកទេ គេឲ្យធ្វើការតែរហូត។

**ស៖** នៅកន្លែងធ្វើការរបស់លោកហ្នឹងមានបន្ទប់ទឹកនៅក្បែរនោះដែរឬទេ?

**ឆ៖** អត់មានបន្ទប់ទឹក បន្ទប់អីទេ មានតែដើមអញ្ចាញតូចៗដែលអង្គុយមួយផុតក្បាលប៉ុណ្ណោះឯង ជុះពេញវាល ពេញកាលនុំង។

**ស៖** មានសត្វល្អិតដូចជារុយ ដូចជាអីដែរៗឬទេ នៅពេលហ្នឹង?

**ឆ៖** បើនិយាយពីរុយវិញ រោមបបរឡើងជិតឈឹង។

**ស៖** តើនៅកន្លែងការដ្ឋានការងារហ្នឹង មានទឹកប្រើប្រាស់សម្រាប់ហូប និងសម្រាប់ងូតគ្រប់គ្រាន់ដែរឬទេ?

[១៥:២២:៤១]

**ឆ៖** អត់មានទេ ទឹកសម្រាប់តែគេយកមកដាក់រទេះ យកមកសម្រាប់តែដាំបាយឲ្យប៉ុណ្ណោះ បើយើងធ្វើការហើយ យើងទៅងូតខ្លួនឯង បើយើងធ្វើមិនហើយម៉ែត្រគូបទេ យើងមិនបានងូតទេ នៅហ្នឹងរហូត។

**ស៖** បើសិនជាអត់មានទឹកប្រើគ្រប់គ្រាន់ទេ តើទឹកគេដឹកជញ្ជូនមកពីកន្លែងណា ហើយមានចម្ងាយប៉ុន្មានពីកន្លែងធ្វើការលោក?

**ឆ៖** ឲ្យតែមានអូរ មានបឹងត្រង់ណា គេទៅដួសពីនោះយកមកហើយ។

**ស៖** តើទឹកដែលលោកប្រើប្រាស់សម្រាប់ហូបហ្នឹង មានការចម្រោះត្រឹមត្រូវទេ ឬក៏គ្មាន?

**ឆ៖** អត់មានទេ ទឹកល្អក់រំល់ មកហូបទៅ។

**ស៖** ប្រសិនបើគ្មានទឹកប្រើគ្រប់គ្រាន់ហើយ បន្ទប់ទឹកអត់មានទៀត ចុះចំពោះនារីៗនោះដែលគាត់មានបញ្ហាខាងសុខភាពដូចជា ការមករដូវ ឬអីយ៉ាងម៉េចហ្នឹង តើគាត់ដោះស្រាយយ៉ាងម៉េចទៅ?

**ផ៖** កន្លែងហ្នឹងខ្ញុំអត់ដែរ។

[១៥:២៤:២២]

**ស៖** ក្នុងការធ្វើការងារនៅអាងត្រពាំងថ្ម តើលោកធ្លាប់ធ្លាក់ខ្លួនឈឺដែរឬទេ?

**ផ៖** ខ្ញុំឈឺពីរដង។ ខ្ញុំគ្រុនពីរដង ឲ្យតែថ្នាំអាចម៍ទន្សាយខ្ញុំបានពីរគ្រាប់លេប។

**ស៖** ឈឺគ្រុន លោកបានថ្នាំអាចម៍ទន្សាយ ចុះចំណែកឯជំងឺផ្សេងៗទៀត គេឲ្យថ្នាំអីដែរ?

**ផ៖** ខ្ញុំអត់ដឹងដែរ ប៉ុន្តែអត់មានថ្នាំពេទ្យផង។

**ស៖** ចុះចំណែកពេទ្យដែលឲ្យថ្នាំទៅលោកនោះ តើពួកគេមានចំណេះដឹងជ្រៅជ្រះផ្នែកពេទ្យដែរឬទេ?

**ផ៖** អត់ដឹងថាចេះពេទ្យ ឬមិនចេះទេ ប៉ុន្តែថ្នាំអាចម៍ទន្សាយនោះ គេស្ងួនដុំៗមូលៗដូចអាចម៍ទន្សាយអ៊ីចឹង គេយកមកឲ្យលេប។

**ស៖** តើពេទ្យហ្នឹងគាត់មានវ័យប្រហែលប៉ុន្មានដែរ លោកអាចនិយាយ?

**ផ៖** វ័យអាយុប្រហែលជា២៣, ២២ ប៉ុណ្ណោះឯង។ គេហៅកងពេទ្យនារីគេនោះ កងពេទ្យយុវជន។

**ស៖** នៅពេលដែលលោកធ្វើការនៅអាងត្រពាំងថ្មហ្នឹង តើលោកធ្លាប់ឃើញមានគ្រោះថ្នាក់ណាមួយដែលកើតឡើងដោយសារការងារសាងសង់ទំនប់ហ្នឹងដែរឬទេ?

**ផ៖** មាន។ នៅកៀនខ្ញុំ វាកាប់ៗទៅ កាប់ខុសត្រូវក្បាលគ្នារយះក្បាលគ្នាមួយចំហៀង។

**ស៖** តើគេបញ្ជូនអ្នករបួសនោះទៅណាទៅ?

**ផ៖** អត់បញ្ជូនទេ គេឲ្យចូលរោងកន្លែងដែលយើងដេកហ្នឹង ឲ្យចូលរោងទៅ ពេទ្យនារីហ្នឹង គេយកថ្នាំក្រហមមកលាបឲ្យ។

**ស៖** តើនៅកន្លែង -- លោកមានចាំទេនៅថាៗនៅកន្លែងការដ្ឋានការងារលោក ឬកន្លែងលោកសម្រាកហ្នឹង មានឮមីក្រូគេចាក់ ឮអីដែរ ដែលឮអត់ទេ?

[១៥:២៧:៤២]

**ផ៖** មានៗមីក្រូគេចាក់តែមួយហ្នឹងឯង គេចាក់ចម្រៀងបទចម្រៀងគេហ្នឹង ១៧មេសា ឆ្នាំ៧៥ ហ្នឹងឯង ស្អីៗបទអីច្រើន តែខ្ញុំមិនចេះ ខ្ញុំអត់ចាំ។

**ស៖** ក្រៅពីបទចម្រៀង តើមានព័ត៌មានអីដែលអាចលោកស្តាប់បានពីហ្នឹងដែរឬទេ?

**ឆ៖** អត់មានព័ត៌មានអីទេក្រៅពីបទចម្រៀង បើគេមានការអី បានគេស្រែកហៅតាមមីក្រូឲ្យប្រជុំអី គេស្រែកហៅ។

**លោក សេង លាង៖**

លោកប្រធានខ្ញុំអស់សំណួរនេះហើយៗ ខ្ញុំសូមជូនវេទិកាទៅសហព្រះរាជអាជ្ញារងអន្តរជាតិ។ លោកសាក្សី ខ្ញុំសូមអរគុណលោកច្រើនដែលបានផ្តល់ការសហការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។

[១៥:២៨:៥២]

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរបន្តពីសហការីរបស់ខ្ញុំដែលសួរលោកពីខាងដើមនេះ។ លោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ តើនៅក្នុងកង<ចល័ត> របស់លោក មានគ្នាទាំងអស់ប៉ុន្មាននាក់ដែរធ្វើការនៅទំនប់ត្រពាំងថ្មហ្នឹង?

**លោក សែន សុផុន៖**

**ឆ៖** បើនិយាយកងៗមាន -- កងខ្ញុំមាន៧០នាក់ គេហៅថា "កងធំ" ហើយមានគេមានកងរយមានកងពាន់គេទៀត។

**ស៖** ហើយអ្នកណាជាអ្នកគ្រប់គ្រង<កងរយ>នោះ?

**ឆ៖** អត់ដឹងទេ គេដាក់តែអ៊ីចឹង ប៉ុន្តែគេមានកងគេ គ្នាគេដើរផ្សេងៗ សម្រាប់ដើរមើលទៅ គេឲ្យតែយើងកង ដូចថា ៧០ហ្នឹង ឲ្យអ្នកកងហ្នឹងទទួលការណ៍ត្រង់ហ្នឹងឲ្យពិតប្រាកដ ហើយគេអង្គុយគេចាំតែមើលយើង ៧០នាក់ហ្នឹង។

**ស៖** លោកនៅចាំឈ្មោះមេកងរបស់លោកទេ?

**ឆ៖** អត់ចាំទេ ភ្លេចបាត់អស់ហើយ។

**ស៖** ក្រៅពី តាវ៉ាល់ ដែលលោកបានលើកឈ្មោះគាត់ឡើងនេះ ហើយនិងមេក្រុមដែលមានចំនួន ១០នាក់ <ឈ្មោះ វ៉ា> តើមានអ្នកណាផ្សេងទៀតក្រៅពីពីរនាក់នេះ ដែលមានតួនាទីក្នុងការគ្រប់គ្រងនៅ

ឯទំនប់ត្រពាំងថ្មនោះដែរទេ?

**ឆ៖** មាន មានមេកងរយកងអី ប៉ុន្តែខ្ញុំអត់បានចាំឈ្មោះទេ។

**ស៖** លោកបានលើកឡើងពីខាងដើមថា ពេលដែលលោកនៅ<>ការដ្ឋានទំនប់ត្រពាំងថ្ម លោកនៅតំបន់៥។ លោកដឹងថា តំបន់៥ចំណុះឲ្យភូមិភាគណាដែរទេ?

**ឆ៖** ចំណុះភូមិភាគពាយ័ព្យ។

**ស៖** ហើយតើលោកស្គាល់ថា អ្នកណាជាអ្នកគ្រប់គ្រងភូមិភាគពាយ័ព្យដែរឬទេ?

**ឆ៖** អត់ដឹង ដឹងតាវ៉ាល់ ម្នាក់តែប៉ុណ្ណោះ។

**ស៖** តើនៅពេលដែលលោកនៅភូមិភាគពាយ័ព្យលោកមានដឹងថាមានអ្នកដែលមកពីភូមិភាគនិរតីមកទទួលគ្រប់គ្រងបន្តទេ?

**ឆ៖** បាទ ដឹង។ យាយថែម។

[១៥:៣២:៤៨]

**ស៖** ហើយលោកដឹងទេ តើអ្នកដែលមកពីភូមិភាគនិរតីហ្នឹងមកគ្រប់គ្រងនៅភូមិភាគពាយ័ព្យហ្នឹងនៅពេលណាដែរ? លោកនៅចាំពេលនោះទេ?

**ឆ៖** អត់សូវចាំដែរ ប៉ុន្តែខ្ញុំចាំតែប៉ុណ្ណោះ ប្រហែលជា៧៨ ឬមិនដឹងទេ។ នេះគ្រាន់តែខ្ញុំស្មានប៉ុន្តែ យាយថែម នេះឯងដែលមកចាប់ខាង តាវ៉ាល់ យកទៅវៃចោល ចាប់ម៉ែឪខ្ញុំយកទៅវៃចោលនេះពួកយាយថែម ហ្នឹងឯង។

**ស៖** ុ<តើ>លោកដឹង<ដោយរបៀបណាថា> តាវ៉ាល់ ហ្នឹងត្រូវបានគេចាប់ខ្លួន?

**ឆ៖** កងចល័តទាំងអស់និយាយគ្រប់មាត់ថា “អ៊ូ! តាវ៉ាល់ គេយកទៅវៃបាត់ហើយ ខាងនោះខាងនិរតីគេចូលមក។ គេថា “អ៊ូ! ខាងនិរតីហ្នឹងល្អណាស់ ស្អាតស្អំណាស់ គេធ្វើការអី គេថាហ្នឹង” គេនិយាយអ៊ីចឹង។ តែផ្ទុយទៅវិញ មិនបានប៉ុន្មានខែផង យាយថែម ធ្វើខ្លាំងជាង តាវ៉ាល់ ១០ដង។

**ស៖** តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេថា<>យាយថែម<ហ្នឹង គាត់>កាចសាហាវជាងអ្នកគ្រប់គ្រងមុនៗ<យ៉ាងម៉េចខ្លះទៅ>?

**ឆ៖** ខ្ញុំគ្រាន់តែដឹងថា យាយថែម ចូលមកនៅភ្លាម មនុស្សស្លាប់ច្រើនៗ បើពីអង្កាល់ តាវ៉ាល់ នៅអត់សូវស្លាប់ប៉ុន្មានទេ គ្រាន់តែច្រើនតែដាច់ពោះស្លាប់ ប៉ុន្តែយាយថែមមក ទាំងដាច់ពោះស្លាប់ ទាំងយកទៅវាយចោល។

[១៥:៣៥:០២]

**ស៖** <តើ>ស្ថានភាព<ជីវិត>ការងាររបស់លោក<ជាកម្មករហ្នឹង> វា<លំបាក, ល្អប្រសើរ ឬក៏>នៅតែដដែល ឬក៏យ៉ាងណានៅពេលដែលអ្នកមកពីភូមិភាគនិរតីមកគ្រប់គ្រងបន្តនោះ?

**ឆ៖** នៅដដែល ៣ម៉ែត្រគូប ក៏នៅ៣ម៉ែត្រគូបដដែល អត់បន្ធូរបន្ថយទេ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម តើគេអនុញ្ញាតឱ្យលោកហ្នឹង ហូបបាយប៉ុន្មានពេលក្នុងមួយថ្ងៃ?

**ឆ៖** ពេលមុនដំបូង មួយថ្ងៃបីពេល។ ដល់យូរទៅៗ ចុះទៅៗ នៅសល់តែបបរខាប់។

**ស៖** ក្រោយមកតើលោកនៅតែទទួលរបបអាហារបានបីពេលក្នុងមួយថ្ងៃដដែល ឬក៏យ៉ាងណា?

**ឆ៖** អត់បានទេ ដល់ពេលយូរទៅ អស់អង្ករទៅ យូរទៅនៅសល់តែមួយថ្ងៃ ពេលថ្ងៃត្រង់មួយពេលប៉ុណ្ណោះឯង ហើយនិងពេលល្ងាច។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថារយៈពេលក្រោយមកទៀត គឺថាលោកបានទទួលអាហារតែពីរដងទេក្នុងមួយថ្ងៃ គឺបាយថ្ងៃត្រង់ និងបាយល្ងាច។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** នៅពេលដែលលោករស់នៅព្រះនេត្រព្រះនោះ តើគេមានឱ្យលោកសរសេរប្រវត្តិរូបដែរឬទេ?

**ឆ៖** អត់មានប្រវត្តិរូប អត់មានសៀវភៅ អត់មានខ្មៅដៃ អត់មានទាំងអស់។

[១៥:៣៨:២០]

**ស៖** ពីខាងដើម លោកបានឆ្លើយថា លោកគេចាត់ទុកថា ជាប្រជាជន១៧មេសា តើលោកអាចជម្រាបជូនអង្គជំនុំជម្រះមើល៍ ប្រជាជន១៧មេសា ចង់មានន័យថាម៉េចដែរ?

**ឆ៖** ប្រជាជន១៧មេសា អ្នកដែលជម្លៀសចេញពីទីក្រុងភ្នំពេញមកនៅព្រះនេត្រព្រះនេះ។ អ្នកដែលនៅព្រះនេត្រព្រះ គេហៅថាប្រជាជនចាស់ អ្នកដែលជម្លៀសចេញមក គេហៅថាប្រជាជនថ្មី។

**ស៖** ហើយតើប្រជាជនដទៃទៀត ធ្វើម៉េចបានដឹងថា លោកគឺជាប្រជាជន១៧មេសា <ឬប្រជាជនថ្មី> មិនមែនជាប្រជាជនមូលដ្ឋានបាន?

**ឆ៖** ប្រជាជនថ្មី គ្រាន់តែនិយាយទៅគេដឹង ព្រោះអីប្រជាជនថ្មី អ្នកនោះនិយាយភាសា

កណ្ដាល។ បើអ្នកខាងនោះ គេនិយាយភាសារដឹនៗ។

**ស៖** ហើយតើអ្នកណាជាអ្នកចាត់ទុកលោកថា ជាប្រជាជន១៧មេសា ឬក៏ជាប្រជាជនថ្មីនេះ?

**ឆ៖** ប្រធានសហករណ៍ៗទុកជាប្រជាជនថ្មីថា ពួកខ្ញុំនេះទើបទៅដល់ជាថ្មី ហើយពួកខ្ញុំនេះហូបតែបបរទេ ពួកគេហូបបាយ។

**ស៖** តើមានមធ្យោបាយណាផ្សេងទៀត ឬថាតើប្រជាជនថ្មីហ្នឹងត្រូវបានគេប្រព្រឹត្តខុសៗគ្នាពីប្រជាជនមូលដ្ឋានតាមមធ្យោបាយផ្សេងទៀតក្រៅពីអ្វីលោកលើកឡើងទេ?

**ឆ៖** ខ្ញុំអត់យល់សំណួរហ្នឹង។

**ស៖** លោកទើបតែនិយាយថា ប្រជាជន១៧មេសា គឺហូបតែបបរទេ ឯប្រជាជនមូលដ្ឋានគឺមានសិទ្ធិហូបបាយ។ អ៊ីចឹងបានខ្ញុំសួរថា តើគេមានប្រព្រឹត្តតាមរូបភាពណាផ្សេងទៀត ខុសៗគ្នារវាង ១៧មេសា និងប្រជាជនមូលដ្ឋានដែរទេ?

[១៥:៤១:៣៣]

**ឆ៖** មាន អាហ្នឹងពួកគេខាងមូលដ្ឋាននោះ គេអត់សូវធ្វើការងារទេ គេសម្រាប់តែអ្នកប្រើពួក ១៧មេសា ហ្នឹងឯង។

**ស៖** តើមានប្រជាជនថ្មីច្រើនទេធ្វើការនៅឯការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង?

**ឆ៖** រាប់ពាន់នាក់។

**ស៖** តើគេតម្រូវឱ្យលោកចូលរួមក្នុងការប្រជុំណាមួយទេ នៅពេលដែលលោកធ្វើការនៅការដ្ឋានទំនប់ត្រពាំងថ្ម?

**ឆ៖** មាន ជួនកាលគេឱ្យ គេហៅទៅធ្វើអង្គមីទ្ទិងធំៗ គេនិយាយប្រជុំពីនេះ ពីនោះ គេប្រជុំឱ្យបំពាក់បំប៉នគោលជំហរ ឱ្យថាខំប្រឹងតស៊ូ ខំប្រឹងប្រយុទ្ធ លើកបី -- ប្ដេជ្ញាលើក ៣ម៉ែត្រគូបឱ្យបានសម្រេច។

**ស៖** តើនៅក្នុងអង្គប្រជុំនេះ អ្នកណាជាអ្នកឡើងនិយាយ?

**ឆ៖** មេកងធំ មេកងរយ មេកងពាន់គេអ៊ីចឹង ប៉ុន្តែគេនិយាយ គេមិនបានប្រាប់ឈ្មោះគេ "ខ្ញុំជាឈ្មោះនេះ ខ្ញុំដើម្បីឡើងទៅនិយាយអ៊ីចេះ" អត់មានទេ។

**ស៖** ហើយតើក្នុងកិច្ចប្រជុំនេះ គេមាននិយាយអ្វីក្រៅពីថា លោកត្រូវតែធ្វើការតាមផែនការកំណត់នេះដែរទេ មាននិយាយអីក្រៅពីរឿងហ្នឹងទេ?

**ឆ៖** និយាយ គេថាឲ្យតែធ្វើការនៅក្នុងផែនការអង្គការដែលកំណត់ឲ្យតែប៉ុណ្ណោះឯង។

[១៥:៤៤:១៧]

**ស៖** តើលោកមានបានដឹងថា ប្រជាជនណាម្នាក់ត្រូវគេចាត់ទុកថាជាប្រជាជនវៀតណាម ឬក៏ជាប្រជាជនដែលជាប់ឈាមជ័រវៀតណាម នៅឯការដ្ឋានទំនប់ត្រពាំងថ្មហ្នឹងដែរទេ?

**ឆ៖** កន្លែងខ្ញុំអត់ឮ អត់បានឮគេនិយាយ។

**ស៖** តើមានដឹងថា មាន<>ប្រជាជនចាមធ្វើការនៅឯការដ្ឋានទំនប់ត្រពាំងថ្មដែរទេ?

**ឆ៖** មាន ជួនកាលចាមនៅជាមួយគ្នា ក៏គេចេះតែថា "អេ្ហ! ឡិនមិនស៊ីសាច់ជ្រូកទេ" គេចេះតែនិយាយបង្អាប់គាត់អ៊ីចឹងដែរ។

**ស៖** តាមការកត់សម្គាល់របស់លោក តើប្រជាជនចាមត្រូវបានគេប្រព្រឹត្តខុសពីពលករដទៃទៀតដែរឬទេនៅឯការដ្ឋានទំនប់ត្រពាំងថ្មហ្នឹង?

**ឆ៖** នៅកន្លែងខ្ញុំអត់មានអ៊ីចឹងទេ ខ្លាចកន្លែងផ្សេងមិនដឹង។

**ស៖** លោកបានលើកឡើងពីខាងដើមថា លោកបានដឹងថាមានមនុស្សបាត់ខ្លួន។ តើលោកមានលោកដឹងថាមានមនុស្សបាត់ខ្លួនពីកងរបស់លោក ឬក៏អ្នកបាត់ខ្លួនហ្នឹងគឺ<ជាកម្មករពីក្រុមធំដែរឬទេ>?

**ឆ៖** កងខ្ញុំបាត់ ក្រុមខ្ញុំបាត់ អាអឿន ក៏បាត់គេយកទៅសម្លាប់ចោល។

**ស៖** តើលោកបានឃើញគេយក អឿន ទៅបាត់ហ្នឹងដោយផ្ទាល់ភ្នែក ឬក៏យ៉ាងណា?

**ឆ៖** អត់មានឃើញផ្ទាល់ភ្នែកទេ ស្រាប់តែបាត់ឈឹងៗ។

[១៥:៤៧:១៨]

**ស៖** ចុះបើអ៊ីចឹង ហេតុដូចម្ដេចបានជាលោកហ៊ានសន្និដ្ឋានថា លោកហ្នឹងត្រូវបានគេសម្លាប់ចោលហើយ ក្រោយពីពេលបាត់ខ្លួនទៅ?

**ឆ៖** ដូចខ្ញុំនិយាយពីមុនថា គេហៅខ្ញុំយកខ្សែបង្កីអ៊ីចឹង ទៅយកខ្សែបង្កី ឈ្លបវា -- ឲ្យឈ្លបយកខ្សែបង្កីឲ្យខ្ញុំ ប្រធានកងខ្ញុំហ្នឹងឲ្យឈ្លបថាអ៊ីចឹង ហើយដើម្បីឲ្យយកខ្ញុំទៅចោល យកខ្ញុំទៅសម្លាប់ចោលហ្នឹង បានខ្ញុំលួចរត់។ ដូចខ្ញុំបានប្រាប់មេធាវីខាងដើម។

**ស៖** ហើយតើលោកមានដឹងថា មានអ្នកដទៃទៀតបាត់ខ្លួនក្រៅពី អឿន នេះដែរទេ?

**ឆ៖** មានច្រើន ប៉ុន្តែខ្ញុំអត់បានចាំឈ្មោះគេច្បាស់ទេ គេបាត់ ចេះតែបាត់បន្តិចម្តង បាត់ច្រើន។

**ស៖** ចាប់ពីពេលដែលលោកត្រូវបានគេបណ្ដេញចេញពីទីក្រុងភ្នំពេញ រហូតដល់ដើមខែមករា

ឆ្នាំ១៩៧៩។ តើលោកមាន -- នៅពេលនុ៎ងលោកមានដែលបានដឹងពីការរៀបការណាមួយដែរទេ?

**ឆ៖** មាន ដឹង។ រឿងរៀបការគេចាប់ឲ្យការ គេហៅយុវជន-នារីហ្នឹង មិនបានស្រឡាញ់គ្នាទេ គ្រាន់តែគេចាត់មក គេថា គ្រាន់តែប្រុសថានោះស្រឡាញ់ជាមួយស្រីនោះ គេហៅមកគេរៀបការឲ្យគ្នា ម្តង ម្តង១០គូ, ២០គូ។

**ស៖** ហើយការរៀបការដែលលោកលើកឡើងនេះ តើគេរៀបចំការរៀបការហ្នឹងនៅពេល <លោក>នៅកណ្តាល ឬក៏នៅព្រះនេត្រព្រះ ឬក៏នៅទាំងពីរកន្លែងនេះ?

[១៥:៤៩:៥៩]

**ឆ៖** ខ្ញុំនៅស្ពានស្រែង នៅលើកទំនប់ស្ពានស្រែង គេរៀបការ គេឲ្យស្រីប្រាំ ប្រុសប្រាំ។ ហ្នឹង កន្លែងខ្ញុំរៀបការអ៊ីចឹង គេឲ្យមកអង្គុយទល់មុខគ្នា ឲ្យស្រីប្តេជ្ញាចិត្តថាយកបុរសនេះ ហើយបុរសនោះ ប្តេជ្ញាឲ្យយកស្ត្រីនេះ។ គេនិយាយអ៊ីចឹងឯង ពួកខ្ញុំដែលមិនបានរៀបការក៏នៅអង្គុយធ្វើជាតំណាងគេទៅ។

**ស៖** ហើយលោកដឹងទេអ្នកណាជាអ្នកផ្គូផ្គងបុរសនិងស្ត្រីឲ្យក្លាយទៅជាគូស្រករហ្នឹងគ្នា?

**ឆ៖** មេកងៗអស់ហ្នឹងឯង។

**ស៖** ហើយតើមានអ្វីកើតឡើងក្រោយពីការរៀបការហ្នឹងបញ្ចប់ទៅ?

**ឆ៖** ខ្ញុំអត់បានដឹងដែររៀបការហើយ អត់ដឹងថាកើតឡើងរឿងអី អត់ដឹងដែរ។

**ស៖** សូមអរគុណលោកដើមបណ្តឹងរដ្ឋប្បវេណី។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ។

[១៥:៥១:៤១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយឥឡូវនេះពេលវេលាក៏សមស្របនឹងសម្រាកហើយដែរ សល់ពេលវេលាតិចតួចប៉ុណ្ណោះ។ បាទ ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី២៨ ខែកក្កដា ឆ្នាំ២០១៥ ដែលចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ហើយនិងផ្តើមស្តាប់សក្ខីកម្ម សាក្សីដែលមានរហស្សនាម 2-TCW-858 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណចំពោះលោក សែន សុផុន ដំណើរការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក សែន សុផុន វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញចុះ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណចំពោះលោក សេង ហ៊ុនតាំង បុគ្គលិកអង្គការ ធី.ភី.អូ អង្គជំនុំជម្រះអញ្ជើញលោកមកបន្តចូលរួមអង្គុយអមជាជំនួយស្មារតីដល់ដើមបណ្តឹងរដ្ឋប្បវេណីនេះ នៅក្នុងអំឡុងពេលសវនាការនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់មកចូលរួមសវនាការនៅថ្ងៃស្អែកវិញឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៦ នាទី)*